# ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ
# នៃរាជបណ្ឌិត្យសភាកម្ពុជា



## ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក វ៉ាប៊ុន
## សមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា

លេខាធិការដ្ឋានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ

ឆ្នាំ២០២៤

# ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ
# នៃរាជបណ្ឌិត្យសភាកម្ពុជា

## ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក វ៉ាប៊ុន
## សមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា

លេខាធិការដ្ឋានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ

ឆ្នាំ២០២៤

**រៀបរៀងឯកសារដោយ៖**

*លេខាធិការដ្ឋានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា និងខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ និងជាប្រធានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ*

© លេខាធិការដ្ឋានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា ២០២៤

# បុព្វកថា

នាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០ ជាកាលប្បវត្តិប្រកបដោយនក្ខត្តឫក្ស ដ៏ឧត្តម ដែលឥស្សរជនខ្មែរម្នាក់ គឺឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** ក្នុងកាលវេលាដែលឯកឧត្តមស្ថិតក្នុងតួនាទីជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទបានទទួលការតែងតាំងពីព្រះមហាក្សត្រដែលបានព្រះរាជទានព្រះរាជក្រឹត្យលេខ នស/រកត/០៧២០/៧៥៩ ជាសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា មានគោរមងាវិទ្យាសាស្ត្រ ជា«បណ្ឌិតសភាចារ្យ»តាមសំណើសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ព្រះរាជទានដ៏ថ្លៃថ្លានេះបានបង្ហាញពីសក្តិភាពយ៉ាងច្បាស់ពីចក្ខុវិស័យក្នុងការរួមចំណែកអភិវឌ្ឍកម្លាំងធនធានបញ្ញារបស់ជាតិ ដោយផ្អែកលើគុណសម្បត្តិ គុណបំណាច់ចំពោះជាតិ ព្រមទាំងគុណវុឌ្ឍិជាច្រើននៅក្នុងវិស័យសិក្សាធិការ និងស្រាវជ្រាវវិទ្យាសាស្ត្រ។ ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ជាធនធានឆ្នើមមួយរូប បានរួមចំណែកក្នុងការងារអភិវឌ្ឍប្រទេសតាំងពីសម័យកាលដែលប្រទេសជាតិទើបរួចផុតពីសម័យសង្គ្រាមនៅក្នុងស្ថានភាពដ៏លំបាកលំបិនមកម្ល៉េះ ជាពិសេសក្នុងការងារធ្វើផែនការ ការងារពាណិជ្ជកម្ម ធុរកិច្ច ដែលជាការអភិវឌ្ឍជំនាញក្នុងវិស័យសេដ្ឋកិច្ច និងបន្តការសិក្សារហូតទទួលបានសញ្ញាប័ត្រថ្នាក់បណ្ឌិត ឯកទេសវិទ្យាសាស្ត្រសេដ្ឋកិច្ច។

គោរមងារ«បណ្ឌិតសភាចារ្យ»នេះ ជាគោរមងារវិទ្យាសាស្ត្រសម្រាប់សមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជាដែលជាឥស្សរជន ជាបញ្ញវន្តជាតិមានសញ្ញាប័ត្របណ្ឌិតសម្រេចបានរបកគំហើញក្នុងវិស័យវិទ្យាសាស្ត្រឬសម្រេចបាននូវស្នាដៃនវានុវត្តន៍បច្ចេកទេស ឬ បច្ចេកវិទ្យាដែលផ្តល់គុណ

ប្រយោជន៍ធំធេងដល់សង្គមជាតិ និងមានបទពិសោធន៍ការងារយ៉ាងតិច ១០ឆ្នាំក្រោយទទួលបានសញ្ញាប័ត្របណ្ឌិតឬមានគុណសម្បត្តិធំធេងក្នុងការរៀបចំការងារនិងដឹកនាំគោលនយោបាយអភិវឌ្ឍន៍សង្គមជាតិ។ គិតចាប់ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០២៤ នេះ រាជបណ្ឌិត្យសភាកម្ពុជាមានសមាជិកពេញសិទ្ធិសរុបចំនួន៣០នាក់ក្នុងនោះមានស្ត្រីចំនួន៣នាក់។

សៀវភៅនេះ រៀបចំឡើងដោយរួមបញ្ចូលនូវសារតាររបស់ស្ថាប័ន អំពីគោរមងារ សមាជិកបណ្ឌិតសភា ឯកសណ្ឋានបណ្ឌិតសភាចារ្យ និងខ្លឹមសារជាពិសេសអំពីគុណកថា ជីវប្រវត្តិ ស្នាដៃ សកម្មភាព និងសមិទ្ធផលការងារសំខាន់ៗក្នុងវិស័យសិក្សាធិការនិងជូនជាតិមាតុភូមិជាទីស្រឡាញ់នៃយើងរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន**។

រាជបណ្ឌិត្យសភាកម្ពុជារក្សា និងតម្កល់ទុកនូវសៀវភៅដ៏មានតម្លៃនេះទុកជាតឹកតាងប្រវត្តិសាស្ត្រពីសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា។

រាជបណ្ឌិត្យសភាកម្ពុជា ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៤

# មាតិកា


បុព្វកថា ........................................................................ i

ផ្នែកទី១ អំពីរាជបណ្ឌិត្យសភាកម្ពុជា ............................................ ១

១- សាវតារសង្ខេប ........................................................................ ១

២- រូបសញ្ញានៃរាជបណ្ឌិត្យសភាកម្ពុជា ........................................ ១០

៣- ប្រវត្តិពាក្យ «បណ្ឌិត្យសភា» ( ACADEMY ) ............................ ១៤

៣.១- ការរះឡើងនៃសង្គមបណ្ឌិត្យសភា ........................................ ២១

៣.២- អត្ថន័យបច្ចេកសព្ទ «បណ្ឌិតសភាចារ្យ»

( Academician/Fellow ) ........................................................ ២២

៣.៣- សញ្ញាប័ត្រកិត្តិយស ............................................................ ២៧

៤- ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ ................................................. ២៨

៥- គោរមងារនៃរាជបណ្ឌិត្យសភាកម្ពុជា ....................................... ៣០

៥.១- គោរមងារវិទ្យាសាស្ត្រ ........................................................... ៣០

៥.២- គោរមងារកិត្តិយស ............................................................... ៣១

៥.៣- សមាជិកបណ្ឌិតសភានៃរាជបណ្ឌិត្យសភាកម្ពុជា. ................ ៣៣

៦- អាវបណ្ឌិតសភាចារ្យ ............................................................. ៣៩

៦.១- អំពីទម្រង់អាវបណ្ឌិតសភាចារ្យ ........................................ ៣៩

៦.២- ខ្លឹមសារនៃអាវបណ្ឌិតសភាចារ្យ ........................................ ៤១

ផ្នែកទី២ គុណកថា ប្រវត្តិរូប សកម្មភាពការងារ និងសមិទ្ធផលបម្រើជាតិ
មាតុភូមិរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន ........................ ៤៤
១- គុណកថា...................................................................... ៤៤
២- ជីវប្រវត្តិសង្ខេប ............................................................ ៧៤
ក- ប្រវត្តិការសិក្សា.................................................................៧៤
ខ- ប្រវត្តិការងារ .....................................................................៧៥
គ- មុខងារ និងតំណែងផ្សេងទៀត .......................................... ៧៧
ឃ- ភាសា ........................................................................... ៧៧
ង- គ្រឿងឥស្សរិយយស ...................................................... ៧៧
៣- សកម្មភាពការងារនិងសមិទ្ធផលបម្រើជាតិ .............................៧៨
សញ្ញាប័ត្រ លិខិតបញ្ជាក់ ទទួលបានក្នុងវិស័យអប់រំ .....................១១៥
ឧបសម្ព័ន្ធ ព្រះរាជក្រឹត្យតែងតាំងជាសមាជិកពេញសិទ្ធិ ................ ១១៧
បទចម្រៀង : រាជបណ្ឌិត្យសភាកម្ពុជា....................................... ១១៩

## ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន

## *ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងជាប្រធានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ*



ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ជាថ្នាក់ដឹកនាំមានបទពិសោធន៍ការងារសម្បូរបែប។ ឯកឧត្តមបានចាប់ផ្តើមការងារដំបូងបំផុតជាគ្រូបង្រៀនបឋមសិក្សាឆ្នាំ១៩៦៩-ឆ្នាំ១៩៧០ សាស្ត្រាចារ្យរូបវិទ្យានិងគីមី នៅឆ្នាំ១៩៧២ និងបន្ទាប់មកជាអនុប្រធាន និងប្រធាននាយកដ្ឋានផែនការទូទៅពីឆ្នាំ១៩៨១ ដល់ឆ្នាំ១៩៨៥ និងជាអនុរដ្ឋមន្ត្រីក្រសួងផែនការ ពីឆ្នាំ១៩៨៦ ដល់ឆ្នាំ១៩៨៨។ ឯកឧត្តមធ្លាប់បំពេញការងារជានាយករងខុទ្ទកាល័យនៃគណៈកម្មាធិការកណ្តាលនៃគណបក្សប្រជាជនកម្ពុជាចាប់ពីឆ្នាំ១៩៨៨ ដល់ឆ្នាំ១៩៩០ និងជាអនុរដ្ឋមន្ត្រីនៃក្រសួងពាណិជ្ជកម្មពីឆ្នាំ១៩៩០ ដល់ឆ្នាំ១៩៩៣។

នៅកំលុងប្រាំឆ្នាំបន្ទាប់ រហូតដល់ឆ្នាំ១៩៩៨ **ឯកឧត្តម** ជាប្រធានគណៈកម្មការហិរញ្ញវត្ថុ និងធនាគារនៃរដ្ឋសភាជាតិ និងជារដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរហូតដល់ឆ្នាំ២០០៨។ ក្រោយមក **ឯកឧត្តម** បានក្លាយជាទីប្រឹក្សាជាន់ខ្ពស់របស់សម្តេច

នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រហូតដល់ឆ្នាំ២០១៣។

ពីឆ្នាំ២០១៣ ដល់ ២០១៦ **ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន** បំពេញការងារជារដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបន្តជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រហូតដល់ឆ្នាំ២០២៣។

នៅក្នុងអាណត្តិជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ **ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន** ទទួលការតែងតាំងជាសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៧២០/៧៥៩ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០ មានគោរមងារវិទ្យាសាស្ត្រជា «បណ្ឌិតសភាចារ្យ»។

នាថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ នៅដើមអាណត្តិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** ទទួលបានការតែងតាំងជា **ទេសរដ្ឋមន្ត្រី** ទទួលបន្ទុកបេសកកម្មពិសេស ជា**ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ** និងជា**ប្រធានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ** និងបន្តទទួលខុសត្រូវក្នុងមុខងារនេះរហូតដល់ពេលបច្ចុប្បន្ននេះ។ បច្ចុប្បន្ននេះ **ឯកឧត្តមបណ្ឌិតសភាចារ្យ** ជាសមាជិកនៃគណៈ-មេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

# ផ្នែកទី១
# អំពីរាជបណ្ឌិត្យសភាកម្ពុជា

## ១- សាវតារសង្ខេប

នៅឆ្នាំ១៩៦៥ ព្រះរាជក្រម លេខ ២៦១ ប.វ. និងព្រះរាជក្រឹត្យលេខ៤៩៩ ប.វ. ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៦៥ «រាជបណ្ឌិតសភា» ត្រូវបានបង្កើតឡើងស្ថិតនៅក្រោមកិច្ចដឹកនាំរបស់ក្រុមប្រឹក្សាភិបាលមួយដែលមាននាយករដ្ឋមន្ត្រីជាប្រធាន រដ្ឋមន្ត្រីក្រសួងអប់រំជាតិ ជាអនុប្រធាន និងសមាជិក២នាក់ តែងតាំងពីប្រមុខរដ្ឋក្នុងបញ្ជីបញ្ជូនពីរាជរដ្ឋាភិបាល ចាងហ្វាងសាកលវិទ្យាល័យនានា ជាសមាជិក ប្រធានរាជបណ្ឌិតសភាជាសមាជិក និងលេខាអចិន្ត្រៃយ៍នៃរាជបណ្ឌិតសភាជាសមាជិកថ្លែងការណ៍។ ប៉ុន្តែដោយសារសង្គ្រាមស៊ីវិលចាប់ពីឆ្នាំ១៩៧០ ស្ថាប័នជាន់ខ្ពស់ដែលទើបបង្កើតឡើងនេះ មិនអាចដំណើរការបានដោយកាត់ផ្តាច់រាល់ការខិតខំអស់រយៈពេលជិត៣០ឆ្នាំ។

នៅរវាងខែមករា កុម្ភៈ ឆ្នាំ១៩៩៧ ក្នុងពេលទៅចូលរួមសន្និសីទប្រចាំឆ្នាំលើកទី៨ នៃសម្ព័ន្ធនិស្សិតខ្មែរនៅសហរដ្ឋអាម៉េរិក លោកបណ្ឌិត **ស៊ន សំណាង** និងលោក **ស៊ន សូផាត** បានរៀបចំបង្កើតនូវ«គណៈ-កម្មាធិការផ្ទៀងផ្ទាត់ប្រវត្តិសាស្ត្រខ្មែរ» នៅទីក្រុងស្តុកតុន សហរដ្ឋអាម៉េរិក ដែលក្រោយមកបានប្តូរឈ្មោះទៅជា «បណ្ឌិតសភាប្រវត្តិសាស្ត្រខ្មែរ» នៅខែមីនា ឆ្នាំ១៩៩៧ ក្រោយពីបានឯកភាពតាមមតិយោបល់របស់លោកបណ្ឌិត **ករុល ផេខ**។ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៨ លោកបណ្ឌិត **ស៊ន សំណាង** បានដឹកនាំសាស្ត្រាចារ្យប្រវត្តិសាស្ត្រ

ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ចូលជួបនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ដើម្បីស្នើសុំការគាំទ្រក្នុងការបង្កើតបណ្ឌិតសភាប្រវត្តិសាស្ត្រនេះ។ ឆ្នាំ១៩៩៩ ជាឆ្នាំនៃដំណើរផ្លាស់ប្តូរជាប្រវត្តិសាស្ត្រមួយទៀត ដោយបានគិតពីដំណើរការស្ថាប័នដែលបានកាត់ផ្តាច់ពីអតីតកាលអស់រយៈកាលជិត៣០ឆ្នាំ គឺការបង្កើតស្ថាប័នស្រាវជ្រាវជាន់ខ្ពស់ «រាជបណ្ឌិតសភា» នេះឡើងមកវិញ តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០៥៩៩/៩៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៩ ឡាយព្រះហស្តដោយព្រះករុណាព្រះបាទ **នរោត្តម សីហនុ** នៅក្រុងសៀមរាប តាមសំណើរបស់នាយករដ្ឋមន្ត្រី **ហ៊ុន សែន**។ ដូច្នេះ «រាជបណ្ឌិតសភា» ត្រូវបានបង្កើត និងដាក់ឱ្យដំណើរការជាប្រក្រតីឡើងវិញ។ រហូតដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ «រាជបណ្ឌិតសភា» បានប្តូរឈ្មោះទៅជា «រាជបណ្ឌិតសភាកម្ពុជា» ដោយព្រះរាជក្រឹត្យ លេខ នសរកត/១២៩៩/២២០ ស្តីពីការបញ្ចូលវិទ្យាស្ថានភាសាជាតិមកជាមួយរាជបណ្ឌិតសភាកម្ពុជា និងការផ្លាស់ប្តូរឈ្មោះរាជបណ្ឌិតសភា មកជារាជបណ្ឌិតសភាកម្ពុជា និងដោយអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់រាជបណ្ឌិតសភាកម្ពុជា ដែលពេលនោះស្ថាប័ននេះស្ថិតនៅក្រោមអាណាព្យាបាលរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានឯកឧត្តមបណ្ឌិត **សុខ អាន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

ក្នុងដំណាក់កាលដែលកម្ពុជាចាកផុតពីសង្គ្រាមស៊ីវិល និងទទួលបាននូវសន្តិភាពពេញលេញតាមរយៈនយោបាយឈ្នះ-ឈ្នះ របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រាជបណ្ឌិតសភាកម្ពុជាបានក្លាយទៅជាស្ថាប័នស្រាវជ្រាវ និង

បណ្ដុះបណ្ដាលជាន់ខ្ពស់ដ៏ធំមួយរបស់ជាតិ ស្របតាមតម្រូវការចាំបាច់របស់ប្រទេសជាតិ ដែលត្រូវការប្រមូលផ្ដុំធនធានបញ្ញាសម្រាប់រួមចំណែករៀបចំនិងបណ្ដុះបណ្ដាលធនធានមនុស្សខ្មែរ[១]។

ដើម្បីជាកិច្ចឆ្លើយតបនឹងកំណើតរាជបណ្ឌិត្យសភាកម្ពុជា នាថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៩ **នាយករដ្ឋមន្ត្រី ហ៊ុន សែន**[២] បានគូសបញ្ជាក់នាឱកាសសម្ពោធស្ថាប័នស្រាវជ្រាវជាន់ខ្ពស់នេះ ថា៖

*«... ខ្ញុំជឿថា ពិធីសម្ពោធរាជបណ្ឌិតសភានៅថ្ងៃនេះ គឺជាការបើកសករាជថ្មីមួយទៀតនៃការអភិវឌ្ឍធនធានមនុស្សរបស់កម្ពុជា។*

*បទពិសោធន៍នៃប្រទេសជិតខាងជាច្រើនបានបង្ហាញឱ្យឃើញថា ការអភិវឌ្ឍធនធានមនុស្ស គឺជាគន្លឹះដ៏សំខាន់នៅក្នុងការកាត់បន្ថយភាពក្រីក្រនិងការលើកតម្កើងជីវភាពរបស់ប្រជាជន ហើយកិច្ចការនេះ រឹតតែមានសារសំខាន់ពិសេសខ្លាំងណាស់ទៅទៀតសម្រាប់កម្ពុជា ដោយសារថាប្រទេសជាតិយើងកំពុងតែខិតខំ*

---

[១] «រាជបណ្ឌិត្យសភាកម្ពុជា : សកម្មភាព សមិទ្ធផល ២០ឆ្នាំ (១៩៩៩-២០១៩)» ដែលចងក្រងឡើងវិញ ដើម្បីចូលរួមអបអរសាទរពិធីសម្ពោធអគារតេជោទេវី ចែកសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ បណ្ឌិត និងរំឭកខួប២០ឆ្នាំនៃការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិងជាប្រធានកិត្តិយសក្រុមប្រឹក្សាបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា។

[២] ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៧ **ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី** បានប្រោសព្រះរាជទាន គោរម្យងារជា សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**, នាថ្ងៃទី៦ ខែមេសា ឆ្នាំ២០១០ សម្ដេចតេជោត្រូវបានតែងតាំងជាសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា មានគោរមងារជា«បណ្ឌិតសភាចារ្យ» ហើយនាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ សម្ដេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** ត្រូវបានតែងតាំងជា«បណ្ឌិតសភាចារ្យស្ថាបនិក» នៃរាជបណ្ឌិត្យសភាកម្ពុជា។

តស៊ូ ដើម្បីជម្នះនូវមត៌កប្រវត្តិសាស្ត្រដ៏ឈឺចាប់ដែលបន្សល់ទុក ដោយរបបប្រល័យពូជសាសន៍ និងសង្គ្រាមអូសបន្លាយនៅក្នុងអតីតកាលថ្មីៗ របស់ខ្លួន។

...នៅចំពោះមុខអរុណោទ័យនៃសហស្សវត្សរ៍ថ្មី ពិភពលោកកំពុងតែធ្វើដំណើរយ៉ាងលឿនទៅមុខ នៅក្នុងចរន្តសាកលូបនីយកម្មឆ្ពោះទៅកាន់ប្រព័ន្ធសេដ្ឋកិច្ចថ្មីមួយដែលគ្មានព្រំដែន និងគ្មានឧបសគ្គសម្រាប់ចរាចរនៃទំនិញ សេវាមូលធន និងកម្លាំងពលកម្ម ដែលមានចរិតជាសេដ្ឋកិច្ចឌីជីថល ( Digitalized Economy ) ដោយពឹងផ្អែកលើចំណេះដឹង ( Knowledge-based Economy )។ នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចថ្មីនេះមូលធនបញ្ញានឹងដើរតួនាទីគន្លឹះក្នុងការកំណត់សមត្ថភាពដណ្តើមឈ្នះរបស់ជាតិនីមួយៗ។

... ខ្ញុំមានមហិច្ឆតាចង់ប្រែក្លាយទសវត្សរ៍ទី១នៃសហស្សវត្សរ៍ថ្មីឱ្យទៅជាទសវត្សរ៍នៃកំណើនសេដ្ឋកិច្ច ទសវត្សរ៍នៃការប្រយុទ្ធនឹងភាពក្រីក្រតោកយ៉ាក ដើម្បីវឌ្ឍនភាពសង្គម និងវិបុលភាពសម្រាប់កម្ពុជានោះ គឺសង្គ្រាមនៃការពង្រឹងវប្បធម៌សន្តិភាពនិងការប្រយុទ្ធដើម្បីការអភិវឌ្ឍដោយចីរភាព និងសមធម៌ដែលខ្ញុំជឿថានឹងជួយឱ្យយើងអាចលើកស្ទួយឡើងវិញបាននូវព្រលឹង និងអត្តសញ្ញាណជាតិ និងទ្រទ្រង់នូវប្រជាជាតិមួយដែលធ្លាប់តែរឹងមាំ និងមាន នមោទកភាពឱ្យងើបមកកាន់សភាពដើមរបស់ខ្លួនឡើងវិញ។ នៅក្នុងរយៈពេលពី ២០ទៅ៣០ឆ្នាំខាងមុខ ខ្ញុំចង់ឃើញប្រទេសកម្ពុជាក្លាយទៅជាប្រទេសមួយដែលមានកម្រិតរីកចម្រើនប្រហាក់ប្រហែលនឹងបណ្តាប្រទេសជឿនលឿននានាដែលនៅជិតខាងនៅក្នុងតំបន់ ហើយប្រជាជនកម្ពុជាគ្រប់រូបនឹងមាន

ជីវភាពរស់នៅសមរម្យថ្លៃថ្នូរស្ថិតនៅក្នុងវឌ្ឍនភាព វិបុលភាព និងសុភមង្គល។

ខ្ញុំយល់ថា យើងមានមូលហេតុគ្រប់គ្រាន់សម្រាប់ស្មារតីសុទិដ្ឋិនិយមនិងក្តីសង្ឃឹមថា យើងនឹងបានទទួលជ័យជម្នះ នៅក្នុងសង្គ្រាមដ៏លំបាកនេះ។ ក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះ យើងសម្រេចបាននូវសមិទ្ធផលដ៏ច្រើនបើប្រៀបធៀបនឹងប្រទេសឯទៀត ដែលត្រូវចំណាយពេលវេលាអស់រាប់ទសវត្សរ៍ ដើម្បីឈានពីស្ថានភាពដែលយើងបានជួបប្រទះកាលពីប៉ុន្មានឆ្នាំ ឬប៉ុន្មានខែមុននឹងមកដល់ស្ថានភាពនាពេលបច្ចុប្បន្ននេះ។ ជាការពិតណាស់ យើងនឹងត្រូវជួបប្រទះជាមួយបញ្ហាប្រឈម និងឧបសគ្គជាច្រើនទៀតនាពេលខាងមុខ ហើយត្រូវធ្វើដំណើរទៅមុខឱ្យបានឆាប់រហ័សដោយត្រូវលោតផ្លោះដំណាក់កាលជាច្រើនថែមទៀត។ ក៏ប៉ុន្តែសមិទ្ធផលដែលយើងទទួលបានធ្វើឱ្យខ្ញុំមានជំនឿថាកម្ពុជានឹងឆ្លងកាត់រាល់ឧបសគ្គ និងការលំបាកទាំងឡាយនាពេលអនាគត។ ផ្លូវដែលកម្ពុជាត្រូវដើរនៅវែងអន្លាយ ហើយលំបាកណាស់។ តែអស់លោកអ្នកប្រាកដជាយល់ស្របនឹងខ្ញុំថា សង្គមមួយដែលបានរស់ឡើងវិញពីអន្លង់មហន្តរាយ ហើយធ្វើដំណើរឆ្លងកាត់កំណាត់ផ្លូវដ៏វែងក្នុងរយៈពេលខ្លីបែបនេះ គឺមិនមែនជាការសាមញ្ញធម្មតានោះទេ។ នេះគឺជាសញ្ញាដែលបង្ហាញឱ្យឃើញពីសក្តានុពលភាពដ៏ធំធេងសម្រាប់អនាគតនៃកម្ពុជាយើង។

ទោះបីជាយ៉ាងណាក៏ដោយក៏ខ្ញុំដឹងយ៉ាងច្បាស់ថានេះគឺជាសមរភូមិប្រយុទ្ធធំណាស់សម្រាប់យើងទាំងអស់គ្នា។ គន្លឹះសំខាន់បំផុតសម្រាប់ជ័យជម្នះក្នុងរយៈពេលវែងនៅក្នុងសង្គ្រាមនេះ គឺការ

អភិវឌ្ឍធនធានមនុស្សប្រកបដោយចីរភាព ពិសេសរាជបណ្ឌិត្យ-សភាកម្ពុជា ត្រូវដើរតួនាទីស្នូលយ៉ាងសំខាន់នៅក្នុងកិច្ចការនេះ។

ខ្ញុំសង្ឃឹមថា ក្រោយពីសម្ពោធជាផ្លូវការនៅថ្ងៃនេះ រាជ-បណ្ឌិត្យសភាកម្ពុជា នឹងរៀបចំបានរចនាសម្ព័ន្ធគ្រឹះសម្រាប់ប្រែក្លាយខ្លួនឱ្យទៅជាមជ្ឈមណ្ឌលសម្រាប់យុទ្ធសាស្ត្រនៃការអភិវឌ្ឍធនធានមនុស្ស ជាឃ្លាំងនៃចំណេះវិជ្ជាជាន់ខ្ពស់ ជាទីកន្លែងប្រមូលផ្តុំនូវបញ្ញាញាណរបស់ជាតិ និងជាស្ថាប័ននៃការបណ្តុះបណ្តាលជាន់ខ្ពស់ក្នុងកម្រិតជាតិ និងអន្តរជាតិសម្រាប់ប្រទេសកម្ពុជា និងសម្រាប់បណ្តាប្រទេសក្នុងតំបន់និងលើសកលលោកផងដែរ។

រាជបណ្ឌិត្យសភាកម្ពុជាបានចុះកិច្ចសហប្រតិបត្តិការជាមួយប្រទេសអាស៊ានជាច្រើន និងប្រទេសអឺរ៉ុបមួយចំនួនទៀត។ រាជ-បណ្ឌិត្យសភាកម្ពុជា-អាស៊ាននៅចុងឆ្នាំ២០១២ គឺចុះនៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។ ចំណែកប្រទេសភូមានិងឡាវមិនទាន់បង្កើតបណ្ឌិត្យសភាវិទ្យាសាស្ត្រនេះទេ ហើយក៏មិនទាន់ចុះកិច្ចសហប្រតិបត្តិការបណ្ឌិត្យសភាវិទ្យាសាស្ត្រដែរ។ រាជបណ្ឌិត្យសភា-កម្ពុជាបានចុះកិច្ចសហប្រតិបត្តិការចំនួន៣បណ្ឌិត្យសភា ប្រទេសចិន (ទី១- ទីក្រុងប៉េកាំង, ទី២- ទីក្រុងសៀងហៃ, ទី៣- ខេត្តជាំងស៊ីសាកលវិទ្យាល័យជីវជាំង), ទី៤- បណ្ឌិត្យសភាប្រទេសវៀតណាមខាងជើង, ទី៥-បណ្ឌិត្យសភាប្រទេសវៀតណាមខាងត្បូង, ទី៦- បណ្ឌិត្យសភាកូរ៉េខាងត្បូង, ទី៧- បណ្ឌិត្យសភាម៉ាឡេស៊ី, ទី៨- បណ្ឌិត្យសភាសូវៀត, ទី៩- បណ្ឌិត្យសភាឥណ្ឌូនេស៊ី, ទី១០- ចុះជាមួយប្រទេសកូរ៉េចំនួន៤បណ្ឌិត្យសភា និងទី១១- ចុះជាមួយប្រទេសឡាវ ជាងនេះទៅទៀតក៏បានផ្ញើសមាគមវប្បធម៌

*ជាមួយថៃ និងត្រៀមចុះជាមួយប្រទេសដទៃទៀតជាបន្តបន្ទាប់។ ទាំងនេះ គឺបានទទួលសិទ្ធិប្រទានពីរាជរដ្ឋាភិបាលទាំងអស់។*

*ក្នុងន័យនេះ ខ្ញុំសូមអំពាវនាវដល់គ្រប់ស្ថាប័នជាតិនិងដៃគូអន្តរជាតិទាំងអស់ សូមឱ្យជួយផ្តល់ការឧបត្ថម្ភគាំទ្រដល់រាជបណ្ឌិត្យសភាកម្ពុជា ដើម្បីឱ្យស្ថាប័ននេះអាចសម្រេចបានជោគជ័យនូវបេសកកម្មដ៏ឧត្តុង្គឧត្តមក្នុងការរួមចំណែកអភិវឌ្ឍន៍មូលធនបញ្ញា និងការប្រមូលផ្តុំបញ្ញាញាណរបស់ជាតិ ដើម្បីបុព្វហេតុនៃអនាគតដ៏ភ្លឺស្វាងរបស់កម្ពុជា»។*

សូមបញ្ជាក់ថា នៅឆ្នាំ១៩៩៩ រាជបណ្ឌិតសភាកម្ពុជាមានវិទ្យាស្ថានឧបសម្ព័ន្ធសំខាន់ចំនួន៥គឺ (១) វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ, (២) វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម, (៣) វិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម, (៤) វិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និង(៥) វិទ្យាស្ថានភាសាជាតិ។ សូមបញ្ជាក់ថា វិទ្យាស្ថានភាសាជាតិ បានបង្កើតដំបូងនៅឆ្នាំ១៩៩៦ ក្រោមគំនិតផ្តួចផ្តើមរបស់លោកបណ្ឌិត **ឡុខ សៀម** ហើយស្ថិតក្រោមរចនាសម្ព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងដំណាក់កាលដំបូង វិទ្យាស្ថានភាសាជាតិ មានឈ្មោះថា «វិទ្យាស្ថានជាតិភាសាខ្មែរ»។ រហូតដល់ឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យ លេខ៤៥ អនក្រ.បក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៩៨ បង្កើត **វិទ្យាស្ថានភាសាជាតិ** ជាគ្រឹះស្ថានសាធារណរដ្ឋបាលដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា និងស្ថិតក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លុះក្រោយមក វិទ្យាស្ថានភាសាជាតិបានបញ្ចូលមកស្ថិត

នៅជាមួយរាជបណ្ឌិត្យសភាកម្ពុជា តាមរយៈព្រះរាជក្រឹត្យលេខនស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩។

ចាប់ពីឆ្នាំ២០០០ វិទ្យាស្ថាន និងអង្គភាពឧបសម្ព័ន្ធជាច្រើនបានបង្កើតឡើងមាន មជ្ឈមណ្ឌលស្រាវជ្រាវអាស៊ី ឆ្នាំ២០០៤, វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា ឆ្នាំ២០០៥, គណៈកម្មាធិការជាតិភាសាខ្មែរ[៣] ឆ្នាំ២០០៧, វិទ្យាស្ថានខុងជឺនៃរាជបណ្ឌិតសភាកម្ពុជា ឆ្នាំ២០០៩។

នៅឆ្នាំ២០១១ គណៈកម្មាធិការជាតិភាសាខ្មែរបានប្តូរឈ្មោះទៅជា «ក្រុមប្រឹក្សាជាតិភាសាខ្មែរ» មានទីតាំងនៅក្នុងរាជបណ្ឌិត្យសភាកម្ពុជា រហូតដល់ឆ្នាំ២០១៧ ក្រុមប្រឹក្សាជាតិភាសាខ្មែរបានផ្ទេរស្ថិតក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់រាជបណ្ឌិត្យសភាកម្ពុជា ដោយព្រះរាជ-ក្រឹត្យលេខ នស/រកត/០៨១៧/៦៤១ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧។

ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជាតេជោសែនឫស្សីត្រឹប បានបង្កើតឡើងនៅឆ្នាំ២០១៤។ នៅឆ្នាំ២០២០ វិទ្យាស្ថានសិក្សាចិនត្រូវបង្កើតឡើងជាវិទ្យាស្ថានឧបសម្ព័ន្ធ។ វិទ្យាស្ថានគរុកោសល្យភាសាចិនក្នុងតំបន់ជាអង្គភាពចំណុះអគ្គលេខាធិការដ្ឋាននៃរាជបណ្ឌិត្យសភាកម្ពុជា។

តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/១២១៩/១៩៦២ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល រាជបណ្ឌិត្យសភាកម្ពុជាមានភារកិច្ច ដូចតទៅ៖

---

[៣] «គណៈកម្មាធិការជាតិភាសាខ្មែរ» បង្កើតដោយអនុក្រឹត្យលេខ ១៨ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៧ រហូតដល់ឆ្នាំ២០១១ គណៈកម្មាធិការនេះ បានប្រែឈ្មោះជា«ក្រុមប្រឹក្សាជាតិភាសាខ្មែរ» ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ជាអង្គភាពស្វយ័ត និងមានទីតាំងនៅរាជបណ្ឌិត្យសភាកម្ពុជា។

១- គ្រប់គ្រងនិងពង្រីកការស្រាវជ្រាវវិទ្យាសាស្ត្រលើគ្រប់វិស័យ។
២- ធ្វើកិច្ចសហប្រតិបត្តិការផ្នែកស្រាវជ្រាវជាមួយក្រសួងស្ថាប័ន អង្គការជាតិ និងអន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍនានាដែលមានគោលបំណងដូចគ្នា។
៣- រៀបចំវេទិកាវិទ្យាសាស្ត្រលើគ្រប់វិស័យ ដើម្បីផ្តល់ធាតុចូលក្នុងការរួមចំណែកអភិវឌ្ឍប្រទេស។
៤- បណ្តុះបណ្តាលដើម្បីអភិវឌ្ឍធនធានមនុស្សលើគ្រប់វិស័យ។
៥- ប្រមូល ចងក្រង បោះពុម្ពផ្សាយ និងតម្កល់ឯកសារ ស្នាដៃស្រាវជ្រាវ និងរបកគំហើញនានា។
៦- ប្រមូលកម្លាំងបញ្ញាញាណរបស់ជាតិ និងអន្តរជាតិ ដើម្បីជំរុញការអភិវឌ្ឍប្រទេស។
៧- លើកសំណើជូនគ្រឿងឥស្សរិយយសឬគោរមងារវិទ្យាសាស្ត្រដល់ឥស្សរជនឆ្នើមជាតិ និងអន្តរជាតិ។
៨- អភិរក្ស និងអភិវឌ្ឍការប្រើភាសានិងអក្សរខ្មែរប្រកបដោយនិរន្តរភាព ព្រមទាំងរក្សាបាននូវអត្តសញ្ញាណជាតិខ្មែរ។
៩- ស្រាវជ្រាវ អភិរក្ស និងអភិវឌ្ឍធនធានធម្មជាតិនិងវប្បធម៌។
១០- ចូលរួមចំណែក និងធ្វើកិច្ចសហប្រតិបត្តិការក្នុងការការពារកម្មសិទ្ធិបញ្ញាខាងផ្នែកវិទ្យាសាស្ត្រគ្រប់វិស័យ។
១១- ពិនិត្យនិងវាយតម្លៃស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រជាន់ខ្ពស់។
១២- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលទីស្តីការគណៈរដ្ឋមន្ត្រី និងរាជរដ្ឋាភិបាលប្រគល់ជូន។

យោងអនុក្រឹត្យ លេខ១២៤ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃរាជបណ្ឌិត្យសភាកម្ពុជា ស្ថាប័នស្រាវជ្រាវជាតិនេះ មានរចនាសម្ព័ន្ធ ដូចខាងក្រោម៖

១- អគ្គលេខាធិការដ្ឋាននៃរាជបណ្ឌិត្យសភាកម្ពុជា

២- វិទ្យាស្ថានចំនួន៧ គឺ វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម, វិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកទេស, វិទ្យាស្ថានភាសាជាតិ, វិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម, វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា និងវិទ្យាស្ថានសិក្សាចិន។

៣- អង្គភាពឧបសម្ព័ន្ធចំនួន២ គឺក្រុមប្រឹក្សាជាតិភាសាខ្មែរ និងឧទ្យានរាជបណ្ឌិត្យសភាកម្ពុជាតេជោសែនឫស្សីត្រឹប។

៤- អង្គភាពសវនកម្មផ្ទៃក្នុង។

៥- លេខាធិការដ្ឋានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ។

## ២- រូបសញ្ញានៃរាជបណ្ឌិត្យសភាកម្ពុជា

យោងតាមសេចក្តីសម្រេចលេខ១០ សសរ. ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ ស្តីពីសញ្ញារាជបណ្ឌិត្យសភាកម្ពុជា នៃទីស្តីការគណៈរដ្ឋមន្ត្រីបានបង្ហាញថា សញ្ញារាជបណ្ឌិត្យសភាកម្ពុជា មានទម្រង់ជារង្វង់មូលមានខ្សែពីរជាន់ និងរូបខាងក្នុងមានទម្រង់ជាត្រីកោណ ដែលមាន៖

- រូបជើងពានមាស ទ្ររូបសាស្ត្រា ដោយមានចារឹកអក្សរកាត់ឈ្មោះរាជបណ្ឌិត្យសភាកម្ពុជា គឺ «រ ប ស ក»
- រូបសារ នៅចន្លោះរូបសាស្ត្រា និងរូបចុងស្លាបប៉ាកា ហើយនៅក្នុងរូបសារមានរូបសញ្ញា ឱម

- នៅលើរូបសារ មានរូបសញ្ញា ចុងស្លាបប៉ាកា និង អដ្ឋង្គិកាមគ្គ (ត្រាសាទិស) ដែលហ៊ុមព័ទ្ធដោយរូបពន្លឺឆព្វណ្ណរង្សី មានចំនួន១៦
- នៅក្នុងរង្វង់អមរូបខាងក្នុងទម្រង់ជាត្រីកោណមានរូបជើងពាន សាស្ត្រា សារ ឱម ចុងស្លាបប៉ាកា អដ្ឋង្គិកាមគ្គ និង ឆព្វណ្ណរង្សី មានរូប ចង្វាយក្បាច់អង្គរ ដែលតភ្ជាប់គ្នាពីទម្រជើងពាន
- នៅក្រោមរូបចង្វាយក្បាច់អង្គរ មានចារឹកអក្សរខ្មែរថា «រាជបណ្ឌិត្យសភាកម្ពុជា»។






រីឯខ្លឹមសារសញ្ញារាជបណ្ឌិត្យសភាកម្ពុជា មានអត្ថន័យដូចខាងក្រោម៖

- ទម្រង់ វដ្តជំម្វូល ក្នុងន័យទូទៅ តំណាងពិភពលោក ឬចក្រវាល ព្រះអាទិត្យ និងវិទ្យាសាស្ត្រ
- ទម្រង់ ត្រីកោណ នៃរូបខាងក្នុងមានន័យថា សមាធិលំនឹង និងអំណាច

– រូប **ដើមពានមាស** ជាទម្រង់ក្នុងន័យការផ្ដល់នូវកិត្តិយស។

– រូប **សាស្ត្រា** ជាឃ្លាំងវិជ្ជា គឺជាគម្ពីរឯកសារដែលកត់ត្រានូវព្រឹត្តិការណ៍ ប្រវត្តិ ប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនា និងខ្លឹមសារការស្រាវជ្រាវ។ ខ្មែរនិយមតម្កល់សាស្ត្រានៅតាមវត្តអារាម ដោយតំណាងព្រះត្រៃបិដក ចំនួន១១០ក្បាល មានអរិយសច្ចទាំង៤គឺ

- អរិយសច្ចទី១ : **ទុក្ខអរិយសច្ច** គឺទុក្ខមានពិតដែលកើតមានដល់មនុស្សគ្រប់រូប ហើយពុំអាចជៀសផុតបានឡើយតែខុសគ្នាត្រង់ អ្នកខ្លះមានទុក្ខតិច អ្នកខ្លះមានទុក្ខច្រើន។
- អរិយសច្ចទី២ : **សមុទយអរិយសច្ច** គឺទុក្ខដែលកើតឡើងមកពីហេតុ ហេតុដែលនាំឱ្យមានទុក្ខ គឺ តណ្ហា និង អវិជ្ជា។
- អរិយសច្ចទី៣ : **និរោធអរិយសច្ច** គឺការរួចស្រឡះការរំលត់ទុក្ខ គឺពិតជាមានពិត។
- អរិយសច្ចទី៤ : **មគ្គអរិយសច្ច** គឺជាផ្លូវឬមធ្យោបាយឬមាគ៌ានាំឱ្យផុតទុក្ខ។ **មគ្គអរិយសច្ច ឬ អដ្ឋង្គិកាមគ្គ** មាន៨ គឺ

  ១- សម្មាទិដ្ឋិ សេចក្ដីយល់ឃើញត្រូវ។
  ២- សម្មាសង្កប្ប ការត្រិះរិះត្រូវ តម្រិះត្រូវ។
  ៣- សម្មាវាចា សម្ដីត្រូវ។

៤- សម្មាកម្មន្ត ការងារត្រូវ។
៥- សម្មាអាជីវ ការចិញ្ចឹមជីវិតត្រូវ។
៦- សម្មាវាយាម ការព្យាយាមត្រូវ។
៧- សម្មាសតិ ស្មារតីត្រូវ ការរឭកត្រូវ។
៨- សម្មាសមាធិ សមាធិត្រូវ។

– រូប សារ ជាដងខ្លួននិងព័ត៌មានដែលជាឯកសារផ្សព្វផ្សាយនូវច្បាប់ គតិយុត្តិ ឬដំណឹងផ្សេងៗ

– រូប ឱម ក្នុងន័យជា វិញ្ញាណ ព្រលឹង កំណើត (មន-ខ្មែរ)។ ក្នុងន័យទី១ ឱម ជាពាក្យសង្ខេបជាបទសន្ធិនៃអក្សរពាគ្គ គឺ អ ឧ ម ដែលជាត្រៃសរណៈរបស់ពួកព្រាហ្មណ៍ មានន័យថា អ គឺព្រះវិស្ណុ ឧ គឺព្រះឥសូរ និង ម គឺព្រះព្រហ្ម។ ចំពោះពុទ្ធសាសនិកនិកាយថេរវាទចាត់ទុកឱម ជារតនត្រ័យសង្ខេបមានន័យថា អ គឺអរហំសម្មាសម្ពុទ្ធ ឧ គឺឧត្តមធម៌ និង ម គឺមហាសង្ឃ (ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ) នៅកម្ពុជា។ ពុទ្ធសាសនិកនិកាយមហាយានចាត់ទុក ឱម ជាស្រទាប់ផ្កាឈូក។ រីឯនៅប្រទេសនេប៉ាល់គេថា ឱម ជាតំណាងផែនដីនិងតំណក់ទឹក។

– រូប ស្វាបចាំកា ជាក្បាល គំនិត និងសំណេរ សម្រាប់គូសវាសខាងគំនិតកត់ត្រានូវខ្លឹមសារ ព្រឹត្តិការណ៍ ឬហេតុការណ៍នានាដែលកើតឡើង។

- រូប **ពន្លឺពណ៌ធព្វណ្ណរង្សី** ជារស្មីពន្លឺ ៦ពណ៌ គឺខៀវ លឿង ក្រហម ស ហង្សបាទ ផ្លេក (ពន្លឺពេជ្រ) ចេញពីចុង ស្លាបប៉ាកាដោយមានកាំរស្មីចំនួន១៦ ដែលតំណាងចំណេះ ដឹងព្រះសីវៈជាថាមពល និងសមត្ថភាព។
- រូប **ចង្វាយក្បាច់អង្គរ** ដែលតភ្ជាប់គ្នាទ្រជើងពាន គឺ តំណាងអត្តសញ្ញាណថ្កុំថ្កើងនៃវប្បធម៌សិល្បៈខ្មែរតំណាង អត្តសញ្ញាណជាតិខ្មែរ។

ក្នុងន័យរួម **រាជបណ្ឌិត្យសភាកម្ពុជា** ជាធនាគារខួរក្បាល ដែលប្រមូលផ្តុំដោយបញ្ញវន្តជាន់ខ្ពស់ ផ្តល់កិត្តិយសលើការងារស្រាវជ្រាវ ការចងក្រង និងការបោះពុម្ពផ្សាយប្រកបដោយគតិបណ្ឌិតក្នុងការត្រិះរិះ ពិចារណាគ្រប់ជ្រុងជ្រោយ មានចំណេះដឹង និងសមត្ថភាពខាងជំនាញ វិទ្យាសាស្ត្រ ហើយរក្សានូវតម្លៃខាងវប្បធម៌ សិល្បៈ សាសនា និងភាសា របស់ខ្លួនដែលជាព្រលឹងនៃអត្តសញ្ញាណជាតិខ្មែរ។ ជាងនេះទៅទៀត រាជបណ្ឌិត្យសភាកម្ពុជា លើកទឹកចិត្តនិងផ្តល់នូវកិត្តិយសដល់បណ្ដា ឥស្សរជនជាតិ និងអន្តរជាតិដែលមានគុណបំណាច់ចំពោះជាតិមាតុភូមិ កម្ពុជា និងមានចំណេះដឹងផ្នែកវិទ្យាសាស្ត្រចាប់ពីថ្នាក់បរិញ្ញាបត្រជាន់ ខ្ពស់ (Master Degree)ឡើងទៅ។

## ៣- ប្រវត្តិពាក្យ «បណ្ឌិត្យសភា» (ACADEMY)

ពាក្យ "Academia" ឬ "Academe" ឬ "Academy" គឺជាពាក្យ ដែលមានន័យតែមួយសំដៅទៅលើក្រុមឬសង្គមនិស្សិត ព្រមទាំងអ្នក ប្រាជ្ញ និងបញ្ញវន្តដែលបំពេញការងារក្នុងការពង្រឹងពង្រីកការស្រាវជ្រាវ កម្រិតឧត្តមសិក្សាឡើងទៅ។ ប្រភពពាក្យគឺកើតចេញមកពីទីក្រុងអាថែន

(Athens) បុរាណថា "Akademeia" ដោយសន្មតយកទីកន្លែងមួយទុកជាកន្លែងជួបជុំពិភាក្សាគ្នា។ នៅកន្លែងនោះ ទស្សនវិទូ ប្លាតូ (Plato) ប្រើជាកន្លែងសិក្សាស្រាវជ្រាវជាមួយបណ្ដាសិស្សរបស់គាត់។ ពាក្យ "Academia" ផ្ដោតទៅលើភាពលូតលាស់របស់ពុទ្ធិផ្នែកវប្បធម៌ ផ្នែកវិទ្យាសាស្ត្រ និងបានឆ្លងកាត់គ្រប់ជ្រុងជ្រោយ។ នៅសតវត្សរ៍ទី១៧ ប្រទេសបារាំងនិងអង់គ្លេស មានបញ្ញវន្តផ្នែកសាសនាមួយចំនួនបានផ្សព្វផ្សាយពាក្យនេះក្នុងន័យបញ្ជាក់ពីកម្រិតឧត្តមសិក្សាក្នុងវិទ្យាស្ថាន។ ប្រទេសអង់គ្លេសបានជ្រើសរើសនិងអនុវត្តទ្រង់ទ្រាយ "Academy" មកប្រើប្រាស់។ ចំណែកឯប្រទេសបារាំងបានយកពាក្យ "Instituter" មកប្រើប្រាស់ ហើយនិងគ្រប់គ្រង "Academy" នេះផ្សេងៗគ្នា។

### ប្រទេសអង់គ្លេស

នៅប្រទេសអង់គ្លេសមានបណ្ឌិត្យសភាជាតិ គឺ

- បណ្ឌិត្យសភាវិទ្យាសាស្ត្រសុខាភិបាល (the Academy of Medical Sciences)
- បណ្ឌិត្យសភាប្រ៊ិដធិស (British Academy) បណ្ឌិត្យសភាផ្នែកមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម
- បណ្ឌិត្យសភាវិស្វកម្ម (the Royal Academy of Engineering)
- បណ្ឌិត្យសភាវិទ្យាសាស្ត្រ នៃសង្គមរាជវង្ស (the Royal Society's Scientific Academy of the UK)។

ប្រវត្តិផ្នែកវិទ្យាសាស្ត្រដែលចាប់ផ្ដើមពីឆ្នាំ១៦៦០ នៅប្រទេសអង់គ្លេសមានការចងក្រងប្រព័ន្ធជាមួយបណ្ឌិត្យសភា *សង្គមរាជវង្ស*។ ក្រុមបញ្ញវន្តប្រទេសអង់គ្លេស មានកំណើតផ្ដើមចេញពីកន្លែងមួយឈ្មោះ

Invisible College ដែលក្រុមទស្សនវិទូបានផ្តួចផ្តើមជួបគ្នា ចាប់ពីពាក់កណ្តាល ឆ្នាំ១៦៤០ ដើម្បីពិភាក្សាពីគោលគំនិតរបស់លោក ហ្វ្រង់ស៊ីស បាកុង (Francis Bacon) ដែលជាទស្សនវិទូអង់គ្លេស និងជាឥស្សរជនក្នុងជួររាជរដ្ឋាភិបាល អ្នកវិទ្យាសាស្ត្រ មេធាវី យុត្តិសាស្ត្រវិទូ អ្នកបង្រៀនផ្នែកច្បាប់ និងជាអ្នកនិពន្ធ។

*សង្គមរាជវង្ស* បានបង្កើតឡើងនាថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៦៦០ ដោយមានបញ្ញវន្ត១២នាក់បានជួបជុំគ្នានៅសាកលវិទ្យាល័យហ្គ្រេសហាំ (Gresham College) គឺនៅក្រោយពេលសាស្ត្រាចារ្យ គ្រីស្តូហ្វ័រ វ្រិន (Christopher Wren) បានបង្រៀនអំពីតារាសាស្ត្រ ហើយបានបើកវិទ្យាល័យមួយដើម្បីផ្សព្វផ្សាយវិជ្ជាមួយហៅថា"Physico Mathematical Experimental Learning"។ ក្រុមបញ្ញវន្តបានជួបជុំគ្នាជាញឹកញាប់ដើម្បីធ្វើពិសោធន៍ ពិភាក្សា ពិនិត្យលទ្ធផល និងធ្វើការងារផ្សេងៗទាក់ទងនឹងវិទ្យាសាស្ត្រ។ លោក រ៉ូប៊ើត ម៉ូរីយ៍ (Robert Morey) ជាអ្នកនាំពាក្យទៅទូលស្តេចឆាលទី២ (Charles II) អំពីកិច្ចការពិសោធន៍នេះនិងសុំការគាំទ្រពីទ្រង់។ នៅឆ្នាំ១៦៦១ *សង្គមរាជវង្ស* បានចេញជារូបរាងឡើង។ រហូតមកដល់ ឆ្នាំ១៦៦៣ ក្រឹត្យ Royal Charter មួយទៀតបានកំណត់ឈ្មោះជាថ្មីថា *សង្គមរាជវង្សទីក្រុងឡុងដ៍សម្រាប់សុវឌ្ឍិកម្មចំណេះដឹងជាតិ* (The Royal Society of London for Improving National Knowledge)។

*សង្គមរាជវង្ស* មានភាពជឿនលឿនក្នុងការងាររៀបចំឯកសារនៅក្នុងបណ្ណាល័យដោយបោះពុម្ពសៀវភៅដំបូងបង្អស់នៅឆ្នាំ១៦៦១។ នៅឆ្នាំ១៦៦៦ *សង្គមរាជវង្ស* ក៏ត្រូវភ្លើងឆេះ។ នៅឆ្នាំ១៧១០ ក្រោយអាណត្តិលោកប្រធានាធិបតី អ៊ីសាក់ ញូវតុន(Isaac Newton) អគារថ្មីមួយបានសាងសង់ឡើងសម្រាប់*សង្គមរាជវង្ស*នេះ។ *សង្គមរាជវង្ស* បាន

បោះពុម្ពផ្សាយសៀវភៅមួយចំនួនទៀត។ នៅគ្រាដំបូង ការជ្រើសរើសបេក្ខភាព«Fellows″ ឬ ‟Academicians» របស់*សង្គមរាជវង្ស* គឺធ្វើឡើងទៅតាមច្បាប់ទម្លាប់ និងមិនទាន់មានភាពច្បាស់លាស់អំពីកម្រិតវប្បធម៌នៅឡើយទេ ដោយសារ ‟Fellows″ ទាំងនោះមិនមែនជាអ្នកវិទ្យាសាស្ត្រទាំងអស់គ្នានោះ។ ប៉ុន្តែរហូតដល់ឆ្នាំ១៧៣១ ច្បាប់ថ្មីបានចែងតម្រូវឱ្យបេក្ខជនដាក់សំណើ ហើយលើកឡើងពីបេក្ខជនថ្មីៗផ្សេងៗទៀតនិងដោយមានការគាំទ្រពីសមាជិកចាស់ៗផងដែរ។ នៅឆ្នាំ១៧៨០ *សង្គមរាជវង្ស* បានប្តូរទីកន្លែងម្តងទៀត ដោយបានទទួលការគាំទ្រឧបត្ថម្ភពីលោក ចូសិបហ្វ៍ ប៊ែង (Sir Joseph Bank) ប្រធានាធិបតីប្រទេសអង់គ្លេស។ ការគាំទ្រនេះបានចាប់ផ្តើមតាំងពីឆ្នាំ១៧៧៨មកម្ល៉េះក្នុងនោះគឺយកចិត្តទុកដាក់ទៅលើការងារស្រាវជ្រាវ និងកិច្ចសហការរវាងក្រុមអ្នកវិទ្យាសាស្ត្រនឹងសង្គមអភិជនដែលចាប់អារម្មណ៍ចំពោះការងារស្រាវជ្រាវបានផ្តត់ផ្តង់ផ្នែកហិរញ្ញវត្ថុផងដែរ។ លុះដល់ឆ្នាំ១៨៤៧ *សង្គមរាជវង្ស* បានចែងពីលក្ខខណ្ឌច្បាប់សម្រាប់កំណត់សមត្ថភាពរបស់ Fellows ដោយកម្រូវឱ្យមានស្នាដៃជាចាំបាច់ក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រមុននឹងទទួលងារជា Fellows។ ស្នាដៃតាមឯកទេសផ្សេងៗទាំងនេះធ្វើឱ្យ *សង្គមរាជវង្ស* ក្លាយទៅជា «សង្គមវិទ្យាសាស្ត្រ» ពិតប្រាកដមួយ។ នៅឆ្នាំ១៨៥០ រដ្ឋាភិបាលប្រទេសអង់គ្លេសបានចាប់ផ្តើមឧបត្ថម្ភលើគម្រោងស្រាវជ្រាវ និងសម្ភារៈផ្សេងៗសម្រាប់ការស្រាវជ្រាវ។ នេះជាការកត់សម្គាល់ពីភាពរីកចម្រើនរវាងរដ្ឋនឹងក្រុមអ្នកវិទ្យាសាស្ត្រ។ ប៉ុន្តែទោះបីជាយ៉ាងណា ក្រុមអ្នកវិទ្យាសាស្ត្រនេះ រក្សាសិទ្ធិនិងឯករាជ្យភាពក្នុងការងារស្រាវជ្រាវរបស់ខ្លួន។ នៅឆ្នាំ១៨៥៧ *សង្គមរាជវង្ស* បានប្តូរទីតាំងម្តងទៀត ប៉ុន្តែរហូតឆ្នាំ១៩៦៧ *សង្គមរាជវង្ស* បានស្ថិតនៅវិមាន Carlton House Terrace រហូតមកដល់សព្វថ្ងៃ។

## ប្រទេសបារាំង

នៅប្រទេសបារាំង មានវិទ្យាស្ថានបារាំង (Institut de France) ជាស្ថាប័នជាន់ខ្ពស់មួយបានបង្កើតឡើងនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ១៧៩៥ ដែលសព្វថ្ងៃស្ថិតក្រោមបន្ទុក និងការគ្រប់គ្រងរបស់អធិការបតីឈ្មោះ ហ្គាប្រ៊ីអែល ដឺប្រូគ្លី (Gabriel de Broglie) ប្រវត្តិវិទូបារាំង កើតថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៣១ អាយុ ៨៣ឆ្នាំ បានជ្រើសរើសចូលក្នុង Academy of Ethics និងវិទ្យាសាស្ត្រនយោបាយនៅឆ្នាំ១៧៩៧។ បន្ទាប់មកទៀត លោកបានចូលទៅក្នុងបណ្ឌិត្យសភាបារាំង (France Academy) នៅឆ្នាំ២០០១ ហើយគាត់បានជាប់ឈ្មោះ ជាអធិការបតីនៃស្ថាប័នមួយនេះ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥។ ចក្ខុវិស័យវិទ្យាស្ថានបារាំង គឺ៖

- ជំរុញឱ្យកាន់តែប្រសើរឡើងនូវសិល្បៈនិងវិទ្យាសាស្ត្រ ដែលមានដំណើរស្របនឹងមូលដ្ឋានគ្រឹះរបស់ក្រុមពហុ ចរិយាធម៌
- គ្រប់គ្រងហិរញ្ញវត្ថុ វិភាគទាន "Legecie" និងមូលនីធិដែលបានសហការជាមួយគ្នាជាយូរមកហើយដើម្បីបន្តការអនុវត្តអ្វីៗដែលចម្បង។

វិទ្យាស្ថានបារាំង (Institut de France) គ្រប់គ្រងបណ្ឌិត្យសភាចំនួនប្រាំ៖

- បណ្ឌិត្យសភាភាសាបារាំង (Académie Française) បង្កើតនៅឆ្នាំ១៦៣៥
- បណ្ឌិត្យសភាសីលាចារឹកនិងអក្សរសាស្ត្រ (Académie des Inscription et Belle Lettres) បង្កើតនៅឆ្នាំ១៦៦៣
- បណ្ឌិត្យសភាវិទ្យាសាស្ត្រ (Académie des Sciences) បង្កើតនៅឆ្នាំ១៦៦៦

- បណ្ឌិត្យសភាវិចិត្រសិល្បៈ (Académie des Beaux Arts) បង្កើតនៅឆ្នាំ១៦៤៨
- បណ្ឌិត្យសភាវិទ្យាសាស្ត្រនយោបាយ និងសីលធម៌ (Académie des Sciences Morales et Politique) បង្កើតឆ្នាំ១៧៩៥។

បណ្ឌិត្យសភាវិទ្យាសាស្ត្រ (Académie des Sciences) ជាសង្គមវិទ្យាសាស្ត្រដែលបានបង្កើតឡើងនៅឆ្នាំ១៦៦៦ ដោយស្ដេចល្វីទី១៤ (Louis XIV) ក្រោយការស្នើរបស់លោក ហ្សង់បាប់ទីស្ដ កុលប៊ែរត៍ (Jean-Baptiste Colbert)។ នេះគឺជាជំហានចម្បងផ្នែកវិទ្យាសាស្ត្រផ្ដើមការអភិវឌ្ឍនៅអឺរ៉ុបនៅសតវត្សរ៍ទី១៧-១៨។ ជាដំបូងលោក កុលប៊ែរត៍ នាំគ្នាជួបជុំដោយមានមនុស្សមួយចំនួននៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៦៦៦ នៅបណ្ណាល័យរបស់ស្ដេចល្វីទី១៤ (Louis XIV)។ ក្រោយមកពួកគេជួបជុំគ្នា២ដងក្នុងមួយសប្ដាហ៍។ ក្នុងរយៈពេល៣០ឆ្នាំដំបូង បណ្ឌិត្យសភានេះ មានលំនាំសាមញ្ញមិនទាន់មានច្បាប់ និងលក្ខខណ្ឌត្រឹមត្រូវទេ ផ្ទុយពី *សង្គមរាជវង្ស* (The Royal Society) នៅប្រទេសអង់គ្លេសដែលរដ្ឋបានគាំទ្រ។ បណ្ឌិត្យសភានេះ រក្សាភាពអព្យាក្រឹត្យមិនលាយឡំជាមួយនយោបាយ សាសនា និងសង្គម។

នៅថ្ងៃទី២០ ខែមករា ឆ្នាំ១៦៩៩ ស្ដេចល្វីទី១៤ បានចេញច្បាប់ឱ្យបណ្ឌិត្យសភានេះទទួលឈ្មោះថា «រាជបណ្ឌិត្យសភាវិទ្យាសាស្ត្រ» (Académie Royale des Sciences) មានទីតាំងនៅទីក្រុងប៉ារីស៍ នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៧៩៣។ ការប្រជុំថ្នាក់ជាតិមួយបានធ្វើឡើងដើម្បីរំលាយបណ្ឌិត្យសភានៅទូទាំងប្រទេស។ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៧៩៥ វិទ្យាស្ថានវិទ្យាសាស្ត្រនិងសិល្បៈជាតិ (National Institute of Sciences and Arts) បានកកើតឡើង ហើយបញ្ចូលបណ្ឌិត្យសភាទាំងអស់ (ដូចជាវិទ្យាសាស្ត្រ អក្សរសាស្ត្រ និងសិល្បៈ) មករួមតែមួយវិញ ក្នុងនោះមាន

បណ្ឌិត្យសភាបារាំង (Académie Francaise) និងបណ្ឌិត្យសភាវិទ្យាសាស្ត្រ (Académie des Sciences) ផងដែរ។ ចំណែកសមាជិកបណ្ឌិត្យសភាដែលបានរំលាយចោលទៅនោះ ភាគច្រើនបានបញ្ចូលឱ្យធ្វើការងារវិញ ហើយសមាជិកបណ្ឌិត្យសភាក៏មិនចាំបាច់ត្រូវតែជាអ្នកវិទ្យាសាស្ត្រទេ។

នៅឆ្នាំ១៧៩៨ ស្តេចបារាំង ព្រះនាម **ណាប៉ូឡេអុង បូណាប៉ាត** (Napoleon Bonaparte) បានជាប់ជាសមាជិកភាព និងត្រូវបញ្ចូលឈ្មោះជាសមាជិកបណ្ឌិត្យសភា។ នៅឆ្នាំ១៨១៦ បណ្ឌិត្យសភានេះបានប្តូរឈ្មោះជា«រាជបណ្ឌិត្យសភាវិទ្យាសាស្ត្រ» (Académie Royale des Sciences) និងមានឯករាជ្យភាពរបស់ខ្លួន ដោយមានការគាំទ្រពីថ្នាក់ដឹកនាំប្រទេសនៅពេលបញ្ចូលទៅក្នុងវិទ្យាស្ថានបារាំង (Institut de France)។ ក្រោយមក «រាជបណ្ឌិត្យសភាវិទ្យាសាស្ត្រ» (Académie Royale des Sciences) ក៏បានប្តូរមកជា «បណ្ឌិត្យសភាវិទ្យាសាស្ត្រ» (Académie des Sciences) ដូចដើមវិញ។ ក្នុងរយៈពេលនោះ បណ្ឌិត្យសភាបានទទួលការឧបត្ថម្ភនឹងការទទួលខុសត្រូវពីក្រសួងអប់រំសាធារណៈ (Instruction de Public) និងចាប់ផ្តើមគ្រប់គ្រងនិងពិនិត្យច្បាប់ប៉ាតង់បារាំងនៅអំឡុងសតវត្សរ៍ទី១៨ ក្នុងនាមជាអ្នកទំនាក់ទំនងរវាងចំណេះដឹងផ្សេងៗទៅនឹងវិស័យសាធារណៈ។ លទ្ធផលនេះបានធ្វើឱ្យបណ្ឌិតសភាចារ្យ (Academiciens) ត្រួតត្រាលើសកម្មភាពនានា រួមទាំងផ្នែកបច្ចេកវិទ្យា។ បណ្ឌិត្យសភានេះបានបន្តធ្វើសកម្មភាពជាប់រហូតមកដោយបានបោះពុម្ពផ្សាយដំណឹងផ្សេងៗនៅក្រោមឈ្មោះ "Compte Rendu de l'Académie des Sciences" (១៨៣៥-១៨៦៥)។ សព្វថ្ងៃនេះ បណ្ឌិត្យសភាវិទ្យាសាស្ត្រ ជាស្ថាប័នមួយក្នុងចំណោមបណ្ឌិត្យសភាទាំងប្រាំ ដែលបានទទួលការឧបត្ថម្ភពីវិទ្យាស្ថានបារាំង

( Institut de France )។ សមាជិកបណ្ឌិត្យសភាទទួលបានការជ្រើសតាំង និងមានសុពលភាពអស់មួយជីវិត។ បច្ចុប្បន្នបណ្ឌិត្យសភានេះមានសមាជិកពេញសិទ្ធិ ១៥០នាក់ សមាជិកឆ្លើយឆ្លង ៣០០នាក់ និងសមាជិកសមាគមិកបរទេស ១២០នាក់។ ក្រុមនេះចែកជាពីរក្រុមច្បាស់លាស់តាមឯកទេសវិទ្យាសាស្ត្រ គណិតវិទ្យា រូបវិទ្យា និងជំនាញពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ គីមីវិទ្យា ជីវវិទ្យា ភូមិវិទ្យា និងវិទ្យាសាស្ត្រសុខាភិបាលព្រមទាំងជំនាញពាក់ព័ន្ធ។

### សហរដ្ឋអាម៉េរិក

សហរដ្ឋអាម៉េរិកវិញ មានបណ្ឌិត្យសភាមានកិត្តិនាមល្បីឈ្មោះជាច្រើនមានមុខងារផ្ដល់ប្រឹក្សាដល់ស្ថាប័នរដ្ឋាភិបាលលើព្រឹត្តិការណ៍សំខាន់ៗដូចជា បណ្ឌិត្យសភាជាតិវិទ្យាសាស្ត្រ ( National Academy of Sciences ) បណ្ឌិត្យសភាជាតិវិស្វកម្ម ( National Academy of Engineering ) វិទ្យាស្ថានវេជ្ជសាស្ត្រ ( Institute of Medicine )។

## ៣.១- ការរះឡើងនៃសង្គមបណ្ឌិត្យសភា

សង្គមបញ្ញវន្តបានកើតមានឡើងដើម្បីសិក្សាស្រាវជ្រាវធ្វើបង្ហាញពីទស្សនៈ ការពិភាក្សា និងការប្ដូរយោបល់គ្នាទៅវិញទៅមក។ ក្រោយមកបញ្ញវន្តទាំងនេះបានរៀបចំជារចនាសម្ព័ន្ធមួយ ដោយមានការទទួលស្គាល់តាមផ្លូវច្បាប់។ សមាជិកនីមួយៗត្រូវឱ្យមានការជ្រើសរើសតាមកម្រិតចាំបាច់ ដោយមានការទទួលយល់ព្រមទទួលស្គាល់ពីសមាជិកពេញសិទ្ធិនៃបណ្ឌិត្យសភា។

ក្រុមបញ្ញវន្តនៅប្រទេសបារាំង មានឈ្មោះថា *បណ្ឌិត្យសភាបារាំង* ( Académie Française ) បានសិក្សាពិនិត្យអំពីអ្វីៗទាំងអស់ទាក់ទងនឹងភាសាបារាំង។ ក្រុមនេះបានបង្កើតឡើងក្នុងឆ្នាំ១៦៣៥ ដោយលោក

កាឌីណាល់ រីស្សែលល្យើ ( Cardinal Richelieu ) ដែលជានាយកផ្នែកសាសនាកាតូលិករបស់ស្ដេចល្វីទី៨ ( Louis XIII )។ ស្ថាប័នមួយឈ្មោះថាបណ្ឌិត្យសភាវិទ្យាសាស្ត្របារាំង ( Académie Française de Sciences ) ក៏បានបង្កើតឡើងនៅឆ្នាំ១៦៦៦។ បណ្ឌិត្យសភានេះបានផ្អាកបញ្ឈប់ដំណើរការនៅពេលបដិវត្តន៍បារាំងនៅឆ្នាំ១៧៩៣ និងបើកទ្វារដំណើរការឡើងវិញនៅឆ្នាំ១៨០៣ ដោយស្ដេចណាប៉ូឡេអុង បូណាប៉ាត ( Nappléon Bonaparte )។

*សង្គមរាជវង្ស* នៅប្រទេសអង់គ្លេសបានចាប់ផ្ដើមដំណើរការឡើងនៅឆ្នាំ១៦៦០ ជាបណ្ឌិត្យសភាមុនគេបង្អស់ផ្នែកវិទ្យាសាស្ត្រ។ បន្ដមកនៅឆ្នាំ១៧៨០ នៅសហរដ្ឋអាម៉េរិក មានឥស្សរជនជាបញ្ញវន្ដឆ្នើមៗមួយក្រុមបានធ្វើបដិវត្តនៅក្នុងប្រទេស។ ជាធម្មតា សង្គមបណ្ឌិត្យសភា ( Academic Society ) បានបោះពុម្ពផ្សព្វផ្សាយនូវអ្វីៗដែលទាក់ទងនឹងការស្រាវជ្រាវកម្រិតខ្ពស់ ហើយក៏ជាប្រភពផ្ដល់ការផ្គត់ផ្គង់ និងឧបត្ថម្ភដល់ការស្រាវជ្រាវដែលចាំបាច់ផ្សេងៗ។ មកទល់ពេលបច្ចុប្បន្ននេះ សមាជិកភាពរបស់សង្គមបណ្ឌិត្យសភានៅតែរក្សានូវលក្ខខណ្ឌចាំបាច់អំពីកម្រិតសមត្ថភាពខ្ពស់សម្រាប់ការជ្រើសរើសសមាជិកភាព។

## ៣.២- អត្ថន័យបច្ចេកសព្ទ «បណ្ឌិតសភាចារ្យ» ( Academician/Fellow )

ពាក្យថា “Academician” មានអត្ថន័យដូចគ្នានឹងពាក្យ “Fellow” ដែរ គឺសំដៅដល់បញ្ញាញាណជាន់ខ្ពស់ដែលបានសិក្សាសម្រេចស្នាដៃក្នុងការស្រាវជ្រាវ ព្រមទាំងមានសណ្ដាប់ធ្នាប់នៅក្នុងការងារជាអ្នកស្រាវជ្រាវនៃបណ្ឌិត្យសភា។ នៅក្នុងសង្គមវិទ្យា គេបានបែងចែកអត្ថន័យ

របស់ពាក្យ "Academia" មាន៤យ៉ាង តាមបរិបទប្រវត្តិសាស្រ្ត និងការអភិវឌ្ឍ៖

- Ancient Academia
- Early Academia
- Academia Societies
- Modern Universities

ការបែងចែកនេះ បានឆ្លុះបញ្ចាំងពីសង្គមដែលមានបញ្ញវន្តយល់ដឹងពីការវិវឌ្ឍរបស់ពិភពលោកនៅសតវត្សនីមួយៗ ហើយអ្វីៗតែងបាន និងកំពុងផ្លាស់ប្តូរប្រែប្រួលជាដរាប រួមទាំងបរិស្ថានធម្មជាតិ ចំណេះដឹងភូមិសាស្ត្រ នយោបាយ និងសេដ្ឋកិច្ច។

នៅទ្វីបអឺរ៉ុប "Academia" បានកើតឡើងតាំងពីសម័យបុរាណ ក្នុងលក្ខណៈជា "Trivium" ដោយយកចិត្តទុកដាក់លើការស្រាវជ្រាវវេយ្យាករណ៍ ហោរាសាស្រ្ត និងតក្កវិទ្យា។ លក្ខណៈមួយទៀតគឺ "Quadrivium" ដោយយកចិត្តទុកដាក់ទៅលើការស្រាវជ្រាវក្នុងវិស័យគណិតវិទ្យា ធរណីមាត្រ បទភ្លេង និងតារាសាស្រ្ត។ ចំណែកនៅសហរដ្ឋអាម៉េរិកវិញ "Academia" បានកើតឡើងនៅពាក់កណ្តាលនៃសតវត្សរ៍ទី១៨ ដោយមានលោកប្រធានាធិបតី ប៊ិនយ៉ាមីន ហ្វ្រែងឃ្លីន (Benjamin Franklin)។ នៅដើមសតវត្សរ៍ទី១៩ពាក្យ «បណ្ឌិត» (Ph.D. ឬ Dr.) ឬសាស្រ្តាចារ្យ (Professor) បានយកមកប្រើនៅពេលដែលមនុស្សទូទៅនិយាយ ឬសរសេរទៅកាន់បុគ្គលទាំងនោះ។ នៅប្រទេសអង់គ្លេស គេប្រើពាក្យ «Fellow» ក្នុងន័យដូចគ្នានឹងពាក្យ«Academician» ឧទាហរណ៍ដូចឃ្លាមួយដែលគេប្រើក្នុងភាសាអង់គ្លេស "Fellows of the Royal Society" មិនមែនហៅថា "Academician of the Royal Scoiety"ទេ។

ប្រវត្តិសាស្ត្រប្រទេសកម្ពុជា បានបញ្ជាក់ថា ពាក្យ «**បណ្ឌិត**» បានប្រើក្នុងអក្សរសាស្ត្ររួចស្រេចហើយតាំងពីសម័យចេនឡាមកម្ល៉េះ ដោយសម្គាល់តាមគោរមងារ[៤] «**រាជគុរុព្រាហ្មណ៍បរោហិត**»។ នៅសម័យអង្គរយើងឃើញមានពាក្យ«**បណ្ឌិត**» បានចារនៅក្នុងសិលាចារឹកជាច្រើនអំពី «**គុរុព្រាហ្មណ៍បណ្ឌិត**» នៅរវាងសតវត្សរ៍ទី៩ ដល់សតវត្សរ៍ទី១៣ ជាឧទាហរណ៍ **បណ្ឌិតទិវាករ បណ្ឌិតសិវសោម** ជាដើម។ យ៉ាងណាមិញ ពាក្យថា «**ព្រហ្មបណ្ឌិត**» ក៏ធ្លាប់មានការអះអាងពីការប្រើពាក្យនេះក្នុងសង្គមខ្មែរបុរាណ ដូចជា ព្រះវិមលធម្ម (**ព្រហ្មបណ្ឌិត រតន៍ ថោង**) ព្រះអាចារ្យបង្រៀនព្រះត្រៃបិដក និងអតីតចាហ្វាងសាលាបាលីជាន់ខ្ពស់ (២៤០៦-២៤៧០)។

នៅសម័យសង្គមរាស្ត្រនិយម ងារជា «**បណ្ឌិត**» ចាប់ផ្តើមមានតាមរយៈបញ្ញវន្តខ្មែរដែលបានបញ្ចប់ការសិក្សានៅបរទេស ជាពិសេសនៅប្រទេសបារាំងជាដើម។ ចំណែកប្រទេសកម្ពុជា មានត្រឹមតែ «**បណ្ឌិតកិត្តិយស**» គឺសម្តេចព្រះមហា សុមេធាធិបតី **ជួន ណាត ជោតញ្ញាណោ ព្រះសង្ឃរាជ គណៈមហានិកាយ**។ នៅសម័យសាធារណរដ្ឋ និងសម័យកម្ពុជាប្រជាធិបតេយ្យ (ប៉ុល ពត) អ្វីៗបានរលាយបាត់បង់អស់ទៅវិញ។ មន្ត្រីរាជការ បញ្ញវន្តខ្មែរ និងអ្នកចេះដឹងផ្សេងៗត្រូវរបប ប៉ុល ពត ស្រាវជ្រាវរកនិងយកទៅសម្លាប់ចោល ហើយអ្នកផ្សេងៗទៀត ត្រូវរស់នៅលាក់ឈ្មោះ និងប្រវត្តិ ដើម្បីគេចពីការចាប់ខ្លួនពីពួកកម្មាភិបាល ប៉ុល ពត។ ក្រោយឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨២ ក្រសួងអប់រំបានជ្រើស

---

[៤] វចនានុក្រមខ្មែរ ២០២២ របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិត្យសភាកម្ពុជាបានឱ្យនិយមន័យនៃពាក្យ«គោរមងារ» ឬ «គោរម្យងារ» ថាជា «*របៀបពាក្យដ៏ឧត្តមបន្ថែមតពីងារទៅទៀត ជាពាក្យសរសើរងារ, សម្រាប់ប្រើសរសេរចំពោះតែការចេញសំបុត្រដីកាធំៗ*»។

រើសនិស្សិតឱ្យទៅបន្តការសិក្សានៅក្រៅប្រទេស ថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងនិស្សិតមួយចំនួនទៀត អាចបន្តយកថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ ការបណ្តុះបណ្តាលធនធានមនុស្សថ្នាក់បណ្ឌិតនៅក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមកើតឡើងតាំងពីឆ្នាំ២០០៣ នៅរាជបណ្ឌិត្យសភាកម្ពុជា រហូតមកដល់បច្ចុប្បន្ននេះ។

ចំណែក«**បណ្ឌិតសភាចារ្យ**» សម្គាល់ទៅលើបុគ្គលដែលជាសមាជិកពេញសិទ្ធិនៃស្ថាប័នបណ្ឌិត្យសភាមួយ ផ្នែកសិល្បៈ (Arts) អក្សរសិល្ប៍ (Literature) ឬផ្នែកវិទ្យាសាស្ត្រ (Sciences)។ ចំពោះបញ្ញវន្តកម្រិតនេះ ត្រូវមានកម្រិតវប្បធម៌ថ្នាក់បណ្ឌិត ដោយមានការបោះពុម្ពសៀវភៅនិងស្នាដៃស្រាវជ្រាវមួយចំនួន។ សមាជិកភាព គឺអាចជាបញ្ញវន្តមកពីស្ថាប័នរដ្ឋ និងឯកជនដែលមានបទពិសោធន៍ជាអ្នកស្រាវជ្រាវ និងជាវាគ្មិនក្នុងសន្និសីទឬសិក្ខាសាលា ប៉ុន្តែនៅតាមបណ្តាប្រទេសមួយចំនួន គេប្រើងារនេះសំដៅលើឋានៈ«**កិត្តិយស**»វិញ។

ឋានៈជា«**បណ្ឌិតសភាចារ្យ**» ក៏អាចប្រើចំពោះឋានៈក្នុងការងារ ហើយក៏អាចសម្គាល់ទៅលើសមាជិកភាពរបស់បុគ្គលក្នុងស្ថាប័នខ្លះដូចជានៅតាមស្ថាប័នបណ្ឌិត្យសភាជាតិវិទ្យាសាស្ត្រ (National Academy of Science) ជាដើម។ នៅក្នុងប្រទេសមួយចំនួនដែលបណ្ឌិត្យសភា (Academy) មានសុពលភាពនិងឥទ្ធិពលមួយផ្នែកទាក់ទងទៅនឹងបណ្ឌិត្យសភាជាតិនៃជីវិត (National Academy of Life) ជាពិសេសនៅប្រទេសស្ថិតនៅក្រោមឥទ្ធិពលនៃប្រទេសធំៗ មានសហភាពសូវៀតជាដើម បានប្រើពាក្យ«**បណ្ឌិតសភាចារ្យ**» (Academician) ដើម្បីផ្តល់កិត្តិយសសម្រាប់ឋានៈកិត្តិយស «Honorific Title»។

ការបញ្ចូលសមាជិកភាពនិងឋានៈរបស់បុគ្គលម្នាក់ជា«**បណ្ឌិតសភាចារ្យ**» (Academician) តែងមានលក្ខខណ្ឌខុសគ្នាពីប្រទេសមួយ

ទៅប្រទេសមួយ។ ប៉ុន្តែជាទូទៅ គេតម្រូវឱ្យមាននូវលក្ខខណ្ឌចាំបាច់មួយចំនួនគឺ

- ត្រូវគោរពតាមលក្ខខន្តិកៈដែលបានកំណត់
- ត្រូវជាប់ឈ្មោះក្នុងកិច្ចប្រឡងឬសរសេរតាមឯកទេស
- ត្រូវមាន«បណ្ឌិតសភាចារ្យ» (Academician) ពីរនាក់ដើម្បីឧទ្ទេសនាម និងដែលបានស្គាល់ច្បាស់លាស់អំពីកម្រិតវប្បធម៌ និងឯកទេសរបស់បេក្ខជនថ្មីនោះ
- ត្រូវមានភស្តុតាងជាក់លាក់បញ្ជាក់អំពីសកម្មភាពហ្មឹកហ្វឺននៅក្នុងស្ថាប័នឯកទេសរបស់ខ្លួន
- ត្រូវមានភស្តុតាងជាឯកសារឬស្នាដៃតាមឯកទេស
- ត្រូវមានឯកសារបែបវិទ្យាសាស្ត្រ ដូចជា និក្ខេបបទ (Thesis) ឬ អត្ថបទស្រាវជ្រាវ (Research Papers) ដើម្បីឱ្យគណៈកម្មាការពិនិត្យនិងវាយតម្លៃ
- ត្រូវមានការបោះពុម្ពផ្សាយសៀវភៅមួយចំនួន។

សង្គមអ្នកប្រាជ្ញនិងសង្គមបញ្ញវន្តខ្លះ ដូចជានៅប្រទេសអង់គ្លេសប្រើពាក្យ "Fellow" សម្រាប់សម្គាល់លើកម្រិតវប្បធម៌ និងឋានៈរបស់«**បណ្ឌិតសភាចារ្យ**»។ ការបញ្ចូលបេក្ខភាពម្នាក់ឱ្យមានឋានៈជា*បណ្ឌិតសភាចារ្យកិត្តិយស* (Honorary Fellow or Honorary Academician) ទៅក្នុងចំណោមសង្គមបញ្ញវន្តឬសង្គមឯកទេសណាមួយនោះ អាចធ្វើទៅបានដោយបុគ្គលនោះត្រូវមានស្នាដៃឬទេពកោសល្យ គួរឱ្យកត់សម្គាល់ គួរឱ្យគោរពក្នុងការងារប្រតិបត្តិជាក់ស្តែង ដែលជាស្នាដៃជំនាញឯកទេសក្នុងកម្រិតក្រសួង សង្គម ប្រទេស និងអន្តរជាតិ ជាដើម។ លើសពីនេះទៅទៀត ត្រូវមានឥស្សរជនម្នាក់មានកេរ្តិ៍ឈ្មោះល្អ និង

ទទួលកិត្តិយសពីសង្គមជាតិជាអ្នកសរសេរអះអាង និងជាសាក្សី ដើម្បីគាំទ្រដល់បេក្ខភាពរបស់បេក្ខជននោះ។

### ៣.៣- សញ្ញាប័ត្រកិត្តិយស

អ្នកដឹកនាំមួយចំនួនក្នុងពិភពលោកដែលមានឯកទេសខាងអប់រំ បានសម្រេចផ្តល់សញ្ញាប័ត្រកិត្តិយសជូនដល់ឥស្សរជនមួយចំនួន។ សញ្ញាប័ត្រទាំងនោះ គឺមិនសំដៅទៅលើកម្រិតការបណ្តុះបណ្តាលថ្នាក់បណ្ឌិតទេ យ៉ាងហោចណាស់ក៏អាចជាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ដែរ។ ក្នុងករណីពិសេស គេអាចផ្តល់ជូនដល់បុគ្គលណាម្នាក់ ដែលមិនបានទទួលការបណ្តុះបណ្តាលពីវិទ្យាស្ថានសិក្សាណាមួយពីមុនមក តែបានបម្រើការងារជាច្រើននៅក្នុងសង្គម។ ជារៀងរហូតមក សាកលវិទ្យាល័យមួយចំនួនបានផ្តល់សញ្ញាប័ត្របណ្ឌិតកិត្តិយស ឬសញ្ញាប័ត្រកិត្តិយសផ្សេងៗ ដោយផ្អែកលើលក្ខណវិនិច្ឆ័យ និងការវាយតម្លៃអំពីប្រវត្តិរូបរបស់បេក្ខជន។ គណៈកម្មការវាយតម្លៃនេះ ត្រូវមានសមត្ថភាពផ្សេងៗខាងកិច្ចការបណ្ឌិត្យសភា បទពិសោធន៍ និងការទទួលស្គាល់ពីសង្គមជាតិនិងអន្តរជាតិ ឧត្តមគតិ ឥស្សរិយយស និងមានគុណសម្បត្តិបរិបូណ៌។

ដូច្នេះការវាយតម្លៃនេះ មានសារសំខាន់ណាស់ចំពោះសញ្ញាប័ត្រដែលបុគ្គលម្នាក់ទទួលបាន។ វាមានតម្លៃស្មើរស្មើទៅនឹងសញ្ញាប័ត្រដែលបុគ្គលម្នាក់បានបញ្ចប់ការសិក្សាពីវិទ្យាស្ថានសិក្សាណាមួយដែរ។ កត្តាទាំងនេះស្ថិតក្រោមក្របខ័ណ្ឌច្បាប់ និងទម្លាប់របស់វិទ្យាស្ថាននីមួយៗពីប្រទេសមួយទៅប្រទេសមួយ។ រាល់ការសម្រេចរបស់គណៈកម្មការវាយតម្លៃ ត្រូវផ្អែកជាសំខាន់ទៅលើការប្រឹងប្រែងរបស់បេក្ខជនតាមឯកទេសនីមួយៗ។ សម្អាងលើកត្តាទាំងអស់នេះ ការផ្តល់សញ្ញាប័ត្រកិត្តិយស គឺត្រូវតែផ្អែកលើស្នាដៃរបស់បេក្ខជនតែម្តង។ ម៉្យាងវិញទៀត បទពិសោធន៍

ក្នុងជីវិតរបស់បេក្ខជនក៏ជាកត្តាចាំបាច់ផងដែរទាក់ទងនឹងគុណបំណាច់ក្នុងការបម្រើសង្គមជាតិ។

គណៈកម្មការវាយតម្លៃ និងផ្តល់សញ្ញាប័ត្រកិត្តិយស ត្រូវផ្អែកតាមផ្លូវច្បាប់ក្នុងការទទួលស្គាល់របស់ប្រទេសនីមួយៗ។ ក្នុងលក្ខណៈដែលស្ថាប័នបានទទួលសិទ្ធិនេះហើយ តម្រូវឱ្យជ្រើសរើសយកបុគ្គលណាដែលមានសមត្ថភាពនិងលក្ខណសម្បត្តិ ដូចខាងក្រោមៈ

១- កម្រិតវប្បធម៌

២- រយៈពេលបទពិសោធន៍ក្នុងជីវិត

៣- សញ្ញាប័ត្រក្នុងប្រទេសនិងក្រៅប្រទេស

៤- លិខិតបញ្ជាក់ការចូលរួមជាសមាជិកក្នុងស្ថាប័នផ្សេងៗ

៥- សញ្ញាប័ត្រឬបណ្ណសរសើរពីបរទេស

៦- គ្រឿងឥស្សរិយយសដែលសាមីជនទទួលបាន

៧- ស្នាដៃបោះពុម្ពផ្សព្វផ្សាយក្នុងកម្រិតបុគ្គលឬជាសាធារណៈ។

## ៤- ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ

នៅព្រឹកថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ដោយពិនិត្យឃើញពីតួនាទីចម្បងរបស់ក្រុមបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា លោកជំទាវបណ្ឌិតសភាចារ្យ **ខ្លួត ធីតា** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា បានដឹកនាំអង្គប្រជុំក្រុមបណ្ឌិតសភាចារ្យ ដោយមូលមតិគ្នា ដើម្បីរៀបចំបែបបទសំណើបង្កើតលេខាធិការដ្ឋានរបស់ក្រុមបណ្ឌិតសភាចារ្យ។ រហូតមកដល់ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ រាជបណ្ឌិត្យសភាកម្ពុជា បានដាក់សំណើសុំបង្កើតលេខាធិការដ្ឋានរបស់ក្រុមបណ្ឌិតសភាចារ្យ សម្រាប់កិច្ចដំណើរការរបស់ក្រុមបណ្ឌិតសភាចារ្យនិងជាសេនាធិការស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា ដាក់ជូនទៅរាជរដ្ឋាភិបាល តាមរយៈឯកឧត្តម

បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា។ រហូតមកដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ រាជរដ្ឋាភិបាលសម្រេចចេញអនុក្រឹត្យ លេខ១២៩ អនក្រ.បក ស្តីពីការបង្កើតលេខាធិការដ្ឋានរបស់ក្រុមបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភា-កម្ពុជាសម្រាប់កិច្ចដំណើរការរបស់ក្រុមបណ្ឌិតសភាចារ្យនិងជាសេនាធិ-ការស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា មានរចនាសម្ព័ន្ធដឹកនាំដោយប្រធាន១រូប និងអនុប្រធាន២រូប។

មួយឆ្នាំបន្ទាប់ ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ លេខ នស/រកត/០៨១៧/៩៩២ ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងដំណើរការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ។ **សម្តេចអគ្គមហាសេនាបតីតេជោ បណ្ឌិតសភាចារ្យ ហ៊ុន សែន ជាប្រធានកិត្តិយសនៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ** ហើយក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ មានប្រធានមួយរូបនិងអនុប្រធាន២រូប ជ្រើសរើសចេញពីក្នុងចំណោមសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភា-កម្ពុជា មានចំនួនកំណត់មិនលើសពី៧៩រូប។ ប្រធានរាជបណ្ឌិត្យសភា-កម្ពុជា បំពេញតួនាទីជាអនុប្រធានប្រចាំការនៃក្រុមប្រឹក្សាបណ្ឌិតសភា-ចារ្យ និងជាសេនាធិការរដ្ឋបាល ជូនក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ។

ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ មានតួនាទីសំខាន់រួមចំណែកក្នុងការរៀបចំប្រមូលផ្តុំធនធានបញ្ញាជន និងឥស្សរជនឆ្នើមជាតិអន្តរជាតិ ដែលមានស្នាដៃនិងគុណបំណាច់ក្នុងវិស័យសិក្សាស្រាវជ្រាវនិងចំពោះប្រទេសជាតិកម្ពុជា និងដំណើរការដោយ**លេខាធិការដ្ឋានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ** មានរចនាសម្ព័ន្ធ ភារកិច្ចច្បាស់លាស់ ជាសេនាធិការស្រាវជ្រាវជូនដល់ក្រុមបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា។

## ៥- គោរមងារនៃរាជបណ្ឌិត្យសភាកម្ពុជា

នៅឆ្នាំ២០១៨ រាជបណ្ឌិត្យសភាកម្ពុជាបានរៀបចំតាក់តែង និង ស្នើព្រះរាជក្រឹត្យ ស្ដីពីក្របខ័ណ្ឌគោរមងារនៃរាជបណ្ឌិត្យសភាកម្ពុជា។ ព្រះរាជក្រឹត្យនេះ មានគោលបំណងសំខាន់ផ្ដល់នូវកិត្តិយសជូនដល់វរជន មានស្នាដៃរួមចំណែកប្រកបដោយពុទ្ធិបញ្ញាញាណ និងគុណានុភាពដល់ការអភិរក្ស និងការអភិវឌ្ឍក្នុងវិស័យវិទ្យាសាស្ត្រសេដ្ឋកិច្ច សង្គម និងវប្បធម៌នៃព្រះរាជាណាចក្រកម្ពុជា។ ព្រះរាជក្រឹត្យនេះមានគោលដៅកំណត់ពីប្រភេទ និងកម្រិតគោរមងារលក្ខណសម្បត្តិនៃស្នាដៃ និងការវាយតម្លៃដើម្បីទទួលបានគោរមងារ សិទ្ធិ និងភារកិច្ចរបស់ឥស្សរជនដែលទទួលបានការផ្ដល់គោរមងារនៃរាជបណ្ឌិត្យសភាកម្ពុជា។

យោងតាមព្រះរាជក្រឹត្យ លេខ នស/រកត/០១១៨/០៩៧ ស្ដីពីក្របខ័ណ្ឌគោរមងារនៃរាជបណ្ឌិត្យសភាកម្ពុជា ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ ស្ដីពីគោរមងារនៃរាជបណ្ឌិត្យសភាកម្ពុជា និងបទបញ្ជាផ្ទៃក្នុង លេខ០០១ កប. ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ក្រុមប្រឹក្សា-បណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា គោរមងារនៃរាជបណ្ឌិត្យ-សភាកម្ពុជា មានខ្លឹមសារនិងអត្ថន័យ ដូចខាងក្រោម៖

### ៥.១- គោរមងារវិទ្យាសាស្ត្រ

គោរមងារវិទ្យាសាស្ត្រ មានបី គឺ *អគ្គមហាបណ្ឌិតសភាចារ្យទិសាបាមោក្ខ អគ្គបណ្ឌិតសភាចារ្យ និងបណ្ឌិតសភាចារ្យ*។

**«អគ្គមហាបណ្ឌិតសភាចារ្យទិសាបាមោក្ខ»** ជាគោរមងារវិទ្យាសាស្ត្រខ្ពស់បំផុតនៃរាជបណ្ឌិត្យសភាកម្ពុជា ដែលត្រូវផ្ដល់ជូនឥស្សរជនកំពូលនៃព្រះរាជាណាចក្រកម្ពុជាតែមួយរូបគត់។

**«អគ្គបណ្ឌិតសភាចារ្យ»** ជាគោរមងារវិទ្យាសាស្ត្រដ៏ឧត្តុង្គឧត្តមនៃរាជបណ្ឌិត្យសភាកម្ពុជា ដែលត្រូវផ្តល់ជូនតែប្រធានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា។

**«បណ្ឌិតសភាចារ្យ»** ជាគោរមងារវិទ្យាសាស្ត្រ នៃរាជបណ្ឌិត្យសភាកម្ពុជា ផ្តល់ជូនបញ្ញវន្តដែលបានតែងតាំងជាសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា ទៅតាមលក្ខខណ្ឌកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ៥.២- គោរមងារកិត្តិយស

គោរមងារកិត្តិយសនៃរាជបណ្ឌិត្យសភាកម្ពុជា មានចំនួនប្រាំពីរផ្អែកទៅលើគុណវុឌ្ឍិ ស្នាដៃ និងសមិទ្ធផលជូនជាតិមាតុភូមិដោយឡែកពីគ្នា មានដូចខាងក្រោម៖

**«កិត្តិព្រឹទ្ធបណ្ឌិត»** ជាគោរមងារកិត្តិយសខ្ពស់បំផុតនៃរាជបណ្ឌិត្យសភាកម្ពុជា សម្រាប់ផ្តល់ជូនតែវរជនខ្មែរដែលមានគុណបំណាច់ និងស្នាដៃធំធេងចំពោះប្រទេសជាតិ ក្នុងការធ្វើឱ្យរស់ឡើងវិញ និងអភិវឌ្ឍនូវសង្គម សេដ្ឋកិច្ច និងវប្បធម៌ជាតិ ព្រមទាំងមានការទទួលស្គាល់ជាអន្តរជាតិ លើវិស័យមនុស្សធម៌ និងការលើកតម្កើងសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស ហើយគោរមងារនេះត្រូវបានផ្តល់ជូនវរជនជាតិឬឥស្សរជនជាន់ខ្ពស់របស់ជាតិចំនួនតែ៣រូបប៉ុណ្ណោះ។

**«កិត្តិបរិក្សបណ្ឌិត»** ជាគោរមងារដ៏ឧត្តុង្គឧត្តមនៃរាជបណ្ឌិត្យសភាកម្ពុជា ផ្តល់ជូនដល់វរជនឬឥស្សរជនជាន់ខ្ពស់របស់ជាតិ ដែលបានធ្វើការបម្រើជាតិចាប់ពី៤០ឆ្នាំឡើងទៅ មានគុណបំណាច់និងស្នាដៃក្នុងការដឹកនាំគ្រប់គ្រង និងថែរក្សាឧត្តម

ប្រយោជន៍ជាតិលើវិស័យវិទ្យាសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ មនុស្សធម៌ អប់រំ បណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្ស។ គោរមងារនេះត្រូវកំណត់ផ្តល់ជូនវរជនជាតិឬឥស្សរជនជាន់ខ្ពស់របស់ជាតិចំនួនត្រឹម៤រូបប៉ុណ្ណោះ។

«**កិត្តិសេដ្ឋាបណ្ឌិត**» ជាគោរមងារដ៏ឧត្តុង្គឧត្តមនៃរាជបណ្ឌិត្យសភាកម្ពុជា ផ្តល់ជូនវរជនឬឥស្សរជនជាន់ខ្ពស់របស់ជាតិដែលបានធ្វើការបម្រើជាតិចាប់ពី៣០ឆ្នាំឡើងទៅមានគុណបំណាច់និងស្នាដៃចំពោះប្រទេសជាតិលើវិស័យសេដ្ឋកិច្ចហិរញ្ញវត្ថុ និងការអភិវឌ្ឍ។ គោរមងារនេះត្រូវកំណត់ផ្តល់ជូនវរជនជាតិឬឥស្សរជនជាន់ខ្ពស់របស់ជាតិចំនួនត្រឹម៥រូបប៉ុណ្ណោះ។

«**កិត្តិសង្គហបណ្ឌិត**» ជាគោរមងារដ៏ឧត្តុង្គឧត្តមនៃរាជបណ្ឌិត្យសភាកម្ពុជា ផ្តល់ជូនវរជនឬឥស្សរជនជាន់ខ្ពស់របស់ជាតិដែលបានធ្វើការបម្រើជាតិចាប់ពី៣០ឆ្នាំឡើងទៅ មានគុណបំណាច់ និងស្នាដៃចំពោះប្រទេសជាតិលើវិស័យសង្គមកិច្ចវប្បធម៌ និងមនុស្សធម៌។ គោរមងារនេះត្រូវកំណត់ផ្តល់ជូនវរជនជាតិឬឥស្សរជនជាន់ខ្ពស់របស់ជាតិចំនួនត្រឹម៥រូបប៉ុណ្ណោះ។

«**កិត្តិនីតិកោសលបណ្ឌិត**» ជាគោរមងារដ៏ឧត្តុង្គឧត្តមនៃរាជបណ្ឌិត្យសភាកម្ពុជា ផ្តល់ជូនវរជនឬឥស្សរជនជាន់ខ្ពស់របស់ជាតិ ដែលបានធ្វើការបម្រើជាតិចាប់ពី៣០ឆ្នាំឡើងទៅ មានគុណបំណាច់និងស្នាដៃ ចំពោះប្រទេសជាតិលើវិស័យច្បាប់ យុត្តិធម៌ និងតុលាការ។ គោរមងារនេះត្រូវកំណត់ផ្តល់ជូនវរជនជាតិឬឥស្សរជនជាន់ខ្ពស់របស់ជាតិចំនួនត្រឹម៥រូបប៉ុណ្ណោះ។

«**កិត្តិឧទ្ទេសបណ្ឌិត**» ជាគោរមងារដ៏ឧត្តុង្គឧត្តមនៃរាជបណ្ឌិត្យសភាកម្ពុជា ផ្ដល់ជូនវរជនឬឥស្សរជនជាន់ខ្ពស់របស់ជាតិ ដែលមានគុណបំណាច់និងស្នាដៃ ចំពោះប្រទេសជាតិលើវិស័យសិក្សាធិការ និងសង្គមវប្បធម៌។ គោរមងារនេះត្រូវកំណត់ផ្ដល់ជូនវរជនជាតិឬឥស្សរជនជាន់ខ្ពស់របស់ជាតិចំនួនត្រឹម១៨រូបប៉ុណ្ណោះ។

«**កិត្តិបណ្ឌិត**» ជាសញ្ញាប័ត្រកិត្តិយសដ៏ឧត្តុង្គឧត្តមនៃរាជបណ្ឌិត្យសភាកម្ពុជា។ រាជបណ្ឌិត្យសភាកម្ពុជាទទួលបន្ទុកលើការផ្ដល់និងចេញសញ្ញាប័ត្រកិត្តិយសនេះជូនវរជនឬឥស្សរជនជាន់ខ្ពស់ជាតិ និងអន្តរជាតិ ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់គុណបំណាច់និងស្នាដៃជាប្រយោជន៍ចំពោះជាតិមាតុភូមិក្នុងការអភិវឌ្ឍសង្គម វប្បធម៌ សាសនា និងសេដ្ឋកិច្ចជាតិ និងជាបុគ្គលដែលមានការទទួលស្គាល់ពីមហាជនថែមទៀត។

វរជនឬឥស្សរជនទទួលបានគោរមងារនៃរាជបណ្ឌិត្យសភាកម្ពុជាមានឯកសណ្ឋាន ស្លាកឈ្មោះ និងសញ្ញារាជបណ្ឌិត្យសភាកម្ពុជាបំពាក់លើឯកសណ្ឋានសម្រាប់ប្រើប្រាស់នៅក្នុងពិធីផ្លូវការផ្សេងៗ។ គោរមងារនីមួយៗមានតម្លៃអស់មួយជីវិត និងត្រូវបញ្ចប់ទៅវិញក្នុងករណីមិនគោរពតាមក្រមសីលធម៌គោរមវន្តឬត្រូវតុលាការផ្ដន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋដោយគ្មានការព្យួរទោស។

### ៥.៣- សមាជិកបណ្ឌិតសភានៃរាជបណ្ឌិត្យសភាកម្ពុជា

យោងតាមអនុក្រឹត្យ លេខ០៧ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨ សមាជិកបណ្ឌិតសភានៃរាជបណ្ឌិត្យសភាកម្ពុជា មានសមាជិកពេញសិទ្ធិ សមាជិកបម្រុង សមាជិកសមាគមិក និងសមាជិក

កិត្តិយស ដែលមានសេចក្តីខ្លឹមសារ លក្ខណសម្បត្តិ និងគុណវុឌ្ឍិ មានខ្លឹមសារដូចខាងក្រោម៖

«**សមាជិកពេញសិទ្ធិ**» ជាបញ្ញវន្តមានសញ្ញាប័ត្របណ្ឌិត សម្រេចបាននូវរបកគំហើញថ្មីក្នុងវិស័យវិទ្យាសាស្ត្រឬដែលសម្រេចបាននូវស្នាដៃនវានុវត្តបច្ចេកទេសឬបច្ចេកវិទ្យាដែលផ្តល់គុណប្រយោជន៍ធំធេងដល់សង្គមជាតិ និងមានបទពិសោធន៍ការងារយ៉ាងតិច១០ឆ្នាំ ក្រោយទទួលបានសញ្ញាប័ត្របណ្ឌិតឬមានគុណសម្បត្តិធំធេងក្នុងការរៀបចំ និងដឹកនាំគោលនយោបាយអភិវឌ្ឍន៍សង្គមជាតិ។ សមាជិកពេញសិទ្ធិត្រូវជ្រើសរើសចេញពីក្នុងចំណោមសមាជិកបម្រុងដែលបានបោះពុម្ពសៀវភៅយ៉ាងតិចចំនួនពីរ និងបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវនៅក្នុងកាលិកបត្រស្រាវជ្រាវវិទ្យាសាស្ត្រជាតិឬអន្តរជាតិយ៉ាងតិចចំនួនពីរបន្ថែមទៀតក្រោយជាប់ជាសមាជិកបម្រុង ដែលទទួលស្គាល់ដោយក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ។ សមាជិកពេញសិទ្ធិមានចំនួនកំណត់សរុបមិនលើសពី៧៥រូប ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ និងមានគោរមងារវិទ្យាសាស្ត្រជា«បណ្ឌិតសភាចារ្យ»។

«**សមាជិកបម្រុង**» ជាបញ្ញវន្តមានសញ្ញាប័ត្របណ្ឌិតដែលកំពុងបំពេញការងារក្នុងក្របខ័ណ្ឌឯកទេសរបស់ខ្លួនយ៉ាងតិច ១០ឆ្នាំក្រោយទទួលបានសញ្ញាប័ត្រថ្នាក់បណ្ឌិត និងបានបោះពុម្ពផ្សាយស្នាដៃជាសៀវភៅវិទ្យាសាស្ត្រសង្គមឬវិទ្យាសាស្ត្រពិតយ៉ាងតិចចំនួន៣ និងបានចូលរួមបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវក្នុងកាលិកបត្រស្រាវជ្រាវវិទ្យាសាស្ត្រជាតិ ឬអន្តរជាតិ

យ៉ាងតិចចំនួនប្រាំ ដែលទទួលស្គាល់ដោយក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ និងដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ។

«**សមាជិកសមាគមិក**» ជាបញ្ញវន្តមានសញ្ញាប័ត្របណ្ឌិត ជ្រើសរើសចេញពីក្នុងចំណោមជនជាតិខ្មែរឬជនជាតិបរទេស ដែលបានជួយឧបត្ថម្ភចំពោះការពង្រឹង និងការអភិវឌ្ឍការស្រាវជ្រាវវប្បធម៌ វិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រពិត ជាគុណប្រយោជន៍ដល់ប្រទេសកម្ពុជា ដែលទទួលស្គាល់ដោយក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ និងតាមសំណើពីសមាជិកពេញសិទ្ធិណាម្នាក់ឬពីសាមីខ្លួន ដោយទទួលបានការធានាពីសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា យ៉ាងតិចបីនាក់ និងដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ។

«**សមាជិកកិត្តិយស**» ត្រូវជ្រើសរើសចេញពីមជ្ឈដ្ឋានអ្នកមានកិត្តិនាមល្បីល្បាញជាជនជាតិខ្មែរឬជនជាតិបរទេស ដែលបានចូលរួមចំណែកឧបត្ថម្ភ និងគាំទ្រជាប្រចាំទៅលើការស្រាវជ្រាវវប្បធម៌ វិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រពិត ដែលមានគុណប្រយោជន៍ដល់ប្រទេស តាមសំណើពីសមាជិកពេញសិទ្ធិណាម្នាក់ឬពីសាមីខ្លួន ដោយមានការធានាពីបណ្ដាសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា យ៉ាងតិចបីនាក់ និងដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ។

សមាជិកសមាគមិក និងសមាជិកកិត្តិយស ត្រូវរួមចំណែកដល់ការស្រាវជ្រាវវប្បធម៌និងវិទ្យាសាស្ត្រ ព្រមទាំងជួយឧបត្ថម្ភគាំទ្រដល់ការអភិវឌ្ឍរាជបណ្ឌិត្យសភាកម្ពុជា។

នីតិវិធីជ្រើសរើសសមាជិកបណ្ឌិតសភានៃរាជបណ្ឌិត្យសភាកម្ពុជាធ្វើឡើងដោយក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ ដែលមានលេខាធិការដ្ឋាន

ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ ជាសេនាធិការរៀបចំបែបបទនិងនីតិវិធីទទួលពាក្យស្នើសុំ និងរៀបចំសំណុំឯកសារទទួលបានសម្រាប់ដាក់ជូនទៅក្រុមបណ្ឌិតសភាចារ្យ ដែលជាគណៈកម្មាធិការពិនិត្យនិងវាយតម្លៃរបស់ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ ដោយអនុលោមតាមការកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុង លេខ០០១ កប. ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា ។

## សមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា

| **ល.រ.** | **គោត្តនាម-នាម** | **ឯកទេស** | **ថ្ងៃតែងតាំង** |
|---|---|---|---|
| ១ | សម្តេចអគ្គមហាសេនាបតីតេជោ បណ្ឌិតសភាចារ្យ **ហ៊ុន សែន** | វិទ្យាសាស្ត្រនយោបាយ | ០៦/០៤/២០១០ |
| ២ | ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** | វិទ្យាសាស្ត្រសង្គមនិងនយោបាយ | ០៣/០៧/២០១៧ |
| ៣ | ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន** | វិទ្យាសាស្ត្រសេដ្ឋកិច្ច | ០៣/០៧/២០១៧ |
| ៤ | ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** | វិទ្យាសាស្ត្រនយោបាយ | ២៨/០៦/២០១៦ |
| ៥ | លោកជំទាវបណ្ឌិតសភាចារ្យ **ខ្លូត ធីតា** | ទស្សនវិជ្ជា | ២៣/០៣/២០០១ |
| ៦ | ឯកឧត្តមបណ្ឌិតសភាចារ្យ **ស៊ន សំណាង** | ប្រវត្តិសាស្ត្រ | ២៣/០៣/២០០១ |
| ៧ | ឯកឧត្តមបណ្ឌិតសភាចារ្យ **រស់ ចន្ត្រាបុត្រ** | វិទ្យាសាស្ត្រនយោបាយ | ២៣/០៣/២០០១ |

| | | | |
|---|---|---|---|
| ៨ | ឯកឧត្តមបណ្ឌិតសភាចារ្យ **ស៊ុំ ឈុំប៊ុន** | អក្សរសាស្ត្រ | ២៣/០៣/២០០១ |
| ៩ | ឯកឧត្តមបណ្ឌិតសភាចារ្យ **សោម សុម្មុនី** | អក្សរសាស្ត្រ | ២៣/០៣/២០០១ |
| ១០ | បណ្ឌិតសភាចារ្យ **ឃីង ហុកឌី** | អក្សរសាស្ត្រ | ២១/០៥/២០០២ |
| ១១ | បណ្ឌិតសភាចារ្យ **ម៉ក់ ភឿន** | ប្រវត្តិវិទ្យា | ២១/០៥/២០០២ |
| ១២ | បណ្ឌិតសភាចារ្យ **ថោងឆែល** | អក្សរសាស្ត្រ | ២១/០៥/២០០២ |
| ១៣ | ឯកឧត្តមបណ្ឌិតសភាចារ្យ **ព្រុំ ម៉ុល** | ភាសាវិទ្យា | ២១/០៥/២០០២ |
| ១៤ | ឯកឧត្តមបណ្ឌិតសភាចារ្យ **សំ សោភាន់** | វេជ្ជសាស្ត្រ | ២១/០៥/២០០២ |
| ១៥ | ឯកឧត្តមបណ្ឌិតសភាចារ្យ **តិច សំណាង** | គុបតែងលម្អ និង ស្ថាបត្យកម្ម | ២២/០៩/២០០៣ |
| ១៦ | ឯកឧត្តមបណ្ឌិតសភាចារ្យ **ឆយ អូន** | ភូមិវិទ្យា សេដ្ឋកិច្ច | ២៥/០៦/២០០៧ |
| ១៧ | ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី** | វិទ្យាសាស្ត្រ សេដ្ឋកិច្ច | ០៥/០៨/២០១៧ |
| ១៨ | ឯកឧត្តមបណ្ឌិតសភាចារ្យ **ច័ន្ទ សំណព្វ** | ភាសាវិទ្យានិង អក្សរសាស្ត្រ | ១០/០៨/២០១៧ |
| ១៩ | ឯកឧត្តមបណ្ឌិតសភាចារ្យ **នេត បារ៉ុម** | វិទ្យាសាស្ត្រគីមី | ១៨/០៤/២០១៨ |
| ២០ | ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** | វិទ្យាសាស្ត្រ សេដ្ឋកិច្ច | ១៨/០៤/២០១៨ |

| | | | |
|---|---|---|---|
| ២១ | ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** | វិទ្យាសាស្ត្រអប់រំ | ១៨/០៤/២០១៨ |
| ២២ | លោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** | វិទ្យាសាស្ត្រចំណីអាហារ (មីក្រូជីវសាស្ត្រ) | ១៨/០៧/២០២០ |
| ២៣ | ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក វ៉ាប៊ុន** | វិទ្យាសាស្ត្រសេដ្ឋកិច្ច | ១៨/០៧/២០២០ |
| ២៤ | ឯកឧត្តមបណ្ឌិតសភាចារ្យ **ច័ន្ទ សារុន** | វិទ្យាសាស្ត្រកសិកម្ម | ១៨/០៧/២០២០ |
| ២៥ | ឯកឧត្តមបណ្ឌិតសភាចារ្យ **ជូ ទិជិត្ត** | វិទ្យាសាស្ត្រសេដ្ឋកិច្ច | ១៨/០៧/២០២០ |
| ២៦ | ឯកឧត្តមបណ្ឌិតសភាចារ្យ **ច័ន្ទ រ័ត្ន** | គណិតវិទ្យា | ១៨/០៧/២០២០ |
| ២៧ | ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ស៊ីផាន់ណា** | នីតិសាស្ត្រ | ១៣/១០/២០២២ |
| ២៨ | ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ាប ប៊ុណ្ណា** | គណិត-រូបវិទ្យា | ០១/០៦/២០២៣ |
| ២៩ | លោកជំទាវបណ្ឌិតសភាចារ្យ **ចេក សុថា** | វិទ្យាសាស្ត្រគីមី | ០១/០៦/២០២៣ |
| ៣០ | ឯកឧត្តមបណ្ឌិតសភាចារ្យ **ឆេង វណ្ណារិទ្ធ** | វិទ្យាសាស្ត្រសេដ្ឋកិច្ច | ០១/០៦/២០២៣ |

## ៦- អាវបណ្ឌិតសភាចារ្យ

អាវបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា មានទម្រង់ និងខ្លឹមសារដូចខាងក្រោម៖

### ៦.១- អំពីទម្រង់អាវបណ្ឌិតសភាចារ្យ

អាវបណ្ឌិតសភាចារ្យ មានទម្រង់បែប អាវព្រះថោជ័ជាជ័ជាត ជាប្រភេទអាវវែងកតាំង មានសម្រុងមួយជំហរមនុស្សគ្របពីលើអាវក្នុង ហើយមានទំហំទូលាយ មានឡេវខាងមុខពណ៌មាសប្រាំពីរគ្រាប់ ដែលជារូបសញ្ញានៃរាជបណ្ឌិត្យសភាកម្ពុជា។ នៅតួអាវនៃជងខ្លួននិងដៃ មានរចនា ដោយប៉ាក់ក្បាច់អង្គរពណ៌មាសយ៉ាងប្រណិត។ ស្របតាមជងខ្លួនអមសងខាងឡេវអាវពីលើដល់ក្រោមមានលម្អដោយក្បាច់ចង្វាយអង្គរក្នុងទម្រង់វង់ហៀនបញ្ឈរពណ៌មាស និងហ៊ុមដោយខ្សែតូចឆ្មារពីរជាន់ដែលនៅផ្នែកកណ្ដាលខ្សែនោះ រចនាដោយចង្វាយក្បាច់អង្គរវង់ហៀនដែរ តែមានទម្រង់តូច។ ចំណែកនៅលើដៃអាវវិញ រាងបំពង់ធំ ជីបផ្នត់ស្មាបីជាន់គ្របដល់ចុងដៃ ហើយលម្អដោយក្បាច់រចនាពណ៌មាសហ៊ុមព័ទ្ធវង្វង់ដៃអាវទាំងស្រុងដែលមានពីរសង្កាត់គឺ៖

***ទី១- សង្កាត់នៅផ្នែកដើមដៃ*** មានទំហំទទឹងក្បាច់ទំហំ ៨,៥ស.ម. រចនាដោយក្បាច់បីប្រភេទប្រាំជួរ គឺ ក្បាច់អង្គរទម្រង់គ្របកឈូកចំពីមុខនៅកណ្ដាលគេ ដែលជាអ័ក្សនៃស៊ីមេទ្រី អមដោយខ្សែពណ៌មាសក្រាស់ក្បាច់អង្គរ ទម្រង់គ្របកឈូកចំហៀង និងទម្រង់កន្ទុយហង្ស អមសងខាងក្បាច់កណ្ដាល ដោយខ្សែតូចល្មម និងចង្វាយក្បាច់អង្គរក្រពុំ ដែលមានរាងមូលប្រៀបដូចជា លេខ១ខ្មែរ ឬ គូទខ្យង នៅអមសងខាងក្បាច់ទាំងពីរខាងលើនេះ ដោយខ្សែពណ៌មាសតូចឆ្មារ។



អាវបណ្ឌិតសភាចារ្យ
សម្រាប់បំពាក់ជូន
សមាជិកពេញសិទ្ធិនៃ
រាជបណ្ឌិត្យសភាកម្ពុជា

***ទី២-សង្កាត់នៅផ្នែកចុងដៃអាវ*** មានទទឹងក្បាច់ទំហំ ៨,៥ស.ម. រចនាដោយចង្វាយក្បាច់អង្គរ ក្នុងទម្រង់វង់ហៀន និងអមដោយចង្វាយក្បាច់អង្គរវង់ហៀន ទម្រង់តូច។ ចំណែកនៅផ្នែកខ្នងអាវវិញ ក្រោមកអាវមានជីបច្រើនផ្នត់ ដើម្បីឱ្យអាវនេះទូលាយក្រោម។

***ទី៣-សាច់ផ្ទៃអាវ*** គឺជាសូត្រខ្មែរថ្លូរ៣។

## ៦.២- ខ្លឹមសារនៃអាវបណ្ឌិតសភាចារ្យ

អាវបណ្ឌិតសភាចារ្យ គឺជានិមិត្តកម្មមួយសម្រាប់សម្គាល់និងផ្តល់ជូនដល់ឥស្សរជនជាអ្នកវិទ្យាសាស្ត្រជាន់ខ្ពស់នៃរាជបណ្ឌិត្យសភាកម្ពុជា។ អាវនេះ ប្រើប្រាស់ក្នុងពិធីវិទ្យាសាស្ត្រធំៗ ដោយភ្ជាប់នូវស្លាកសម្គាល់ឈ្មោះបណ្ឌិតសភាចារ្យ និងសញ្ញានៃរាជបណ្ឌិត្យសភាកម្ពុជាផងដែរ។ អាវនេះធ្វើពីកំណាត់សំពត់សូត្រដែលជាផលិតផលរបស់ខ្មែរ (សូត្រខ្មែរ) ដោយប្រើប្រាស់រចនាលម្អដោយក្បាច់ខ្មែរ ហៅ **ក្បាច់អង្គរ** ជាពិសេស ប្រើក្បាច់មេនៃចង្វាយអង្គរជាមូលដ្ឋានដែលបង្ហាញពីស្នាដៃសិល្បៈខ្មែរដ៏រុងរឿងនាសម័យមហាអង្គរក្នុងអតីតកាលនៃយើង។

- **អំពីពណ៌អាវ**

អាវបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជាកំណត់យកពណ៌ **ព្រីងទុំ** ជាមូលដ្ឋាននៃអត្តសញ្ញាណវិទ្យាសាស្ត្រ។ **ពណ៌ព្រីងទុំ** គឺជាពណ៌ធម្មជាតិដែលយកតាមឈ្មោះផ្លែរុក្ខជាតិមួយប្រភេទឈ្មោះ **ផ្លែព្រីង** ដែលដើមវាដុះលើទឹកដីយើងតាំងពីបរម្បុរាមកម្ល៉េះ។ យោងតាមវចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ **ជួន ណាត** បានពន្យល់ថា **ព្រីង** ជាឈ្មោះឈើមួយប្រភេទមានផ្លែជាអាហារ។ រុក្ខជាតិព្រីងមានច្រើនយ៉ាងគឺ **ព្រីងចន្ទន៍ ព្រីងចន្លុះ ព្រីងដោះក្របី ព្រីងបាយ...**។ល។ ពាក្យ **ព្រីង** នេះ មកពីពាក្យ **ជម្ពូ (ជម្ពូផល ជម្ពូព្រឹក្ស)** ដែលជាឈ្មោះដើមរុក្ខជាតិដុះតាមមាត់ស្ទឹងមួយហៅ **ស្ទឹងជម្ពូ** នៅប្រទេសឥណ្ឌា។ ការកំណត់ហៅឈ្មោះ **ស្ទឹងជម្ពូ** មកពីមានដើមព្រីងធំសម្បើមដុះនៅនាភ្នំ**សុមេរុ** ហើយមានផ្លែធំៗកាលបើផ្លែទុំជ្រុះចុះមក លុះដល់រលួយក៏ហូរជ្រោះចូលទៅក្នុងស្ទឹងនោះកករដីក្បែរខាងទាំងពីរជ្រាបទឹកផ្លែព្រីងនោះលុះត្រូវខ្យល់បក់យូរៗទៅក៏ខះស្ងួតក្លាយជា **មាស** វិសេសមួយយ៉ាងហៅថា **មាសជម្ពូនទ**

(មាសជម្ពូនុទ ឬជម្ពូនទៈ)។ ពាក្យ ជម្ពូនទ ជាឈ្មោះ មាស វិសេសមួយប្រភេទ កើតអំពីកករដីដែលជ្រាបជោកដោយទឹកផ្លែព្រីងប្រចាំទ្វីប (ជម្ពូទ្វីប) គឺជាមាសបរិសុទ្ធឥតមានមន្ទិល មានសាច់ល្អបំផុតជាងមាសទាំងពួង សូម្បីព្រះសម្មាសម្ពុទ្ធ ក៏ទ្រង់ត្រាស់សរសើរដែរ។ រីឯ ផ្លែជម្ពូ មានច្រើនយ៉ាងគឺ ជម្ពូស ជម្ពូសព្រឿង ជម្ពូខៀវ ជម្ពូល័ខ និង ជម្ពូក្រហម។ ដូច្នេះ ពណ៌ព្រីង ហៅ ពណ៌ជម្ពូ មានន័យថា ពណ៌ព្រីងទុំ គឺមានពណ៌ក្រហមលាយខ្មៅច្រើន និងបង្កប់ពណ៌ខៀវខ្លះដែរ។

## អំពីក្បាច់របនាពណ៌មាសលើអាវ

ក្បាច់ដែលភ្ជាប់នឹងអាវនេះជាមេក្បាច់អង្គរ ដែលបង្ហាញពីភាពថ្កុំថ្កើងនៃវប្បធម៌ សិល្បៈដែលតំណាងអត្តសញ្ញាណជាតិខ្មែរ។ ក្បាច់អង្គរភាគច្រើនសម្រាប់លម្អលើសំណង់ធុនធ្ងន់ដែលសាងឡើងពីថ្ម ស៊ីម៉ងត៍ ឬឈើដូចជា ប្រាសាទបុរាណ វាំង វត្ត មន្ទីររាជការធំៗ។ ក្បាច់អង្គរមានទម្រង់បីសំខាន់ គឺ ក្បាច់អង្គរទម្រង់ត្របកឈូកចំពីមុខ ក្បាច់អង្គរទម្រង់ត្របកឈូកចំហៀង ឬ កន្ទុយហង្ស និងក្បាច់អង្គរទម្រង់ផ្កាច័ន (ក្បាច់ដកចន្ទន៍អង្គរ)។

អាវបណ្ឌិតសភាចារ្យ យើងយកក្បាច់អង្គរមួយចំនួនមកប្រើដែលមានក្បាច់អង្គរទម្រង់ត្របកឈូកចំពីមុខ គឺជាមេក្បាច់យ៉ាងសំខាន់ដែលអាចបំបែកឱ្យល្អិតល្អន់បានច្រើន ក្បាច់អង្គរទម្រង់ហៀន គឺជាក្បាច់ដែលបំបែកចេញពី ក្បាច់អង្គរទម្រង់ត្របកឈូកចំពីមុខ ចេញជាបីសន្លឹកដាច់ពីគ្នាបង្កើតជា ត្របកឈូកចំពីមុខ និង ចំហៀងសងខាងជាសន្លឹកក្បាច់អង្គរទម្រង់ហៀន ក្បាច់អង្គរទម្រង់ត្របកឈូកចំហៀង ឬទម្រង់កន្ទុយហង្ស គឺជាក្បាច់ដែលបំបែកចេញពីត្របកឈូកចំពីមុខប្រើជាមេចង្វាយនៃក្បាច់អង្គរ ក្បាច់អង្គរក្រពុំ គឺជាមេក្បាច់អង្គរ បន្ទាប់ពី **ត្របកឈូកចំពីមុខ** និងត្របកឈូកចំហៀង ដែលមានរាងមូលប្រៀបដូចជា លេខ១ខ្មែរ ឬ គូទខ្យង។

## អំពីការរចនាលើទ្បេវអាវ

អាវបណ្ឌិតសភាចារ្យប្រើឡេវ ចំនួន៧គ្រាប់ ដែលមានរូបសញ្ញានៃរាជបណ្ឌិត្យសភាកម្ពុជា។ អត្ថន័យ និងខ្លឹមសារសំខាន់ៗមាន៖

- តំណាង **ថ្ងៃ៧មករា** ជាថ្ងៃរំដោះប្រទេសកម្ពុជាចេញពីរបបកម្ពុជាប្រជាធិបតេយ្យ(របបប្រល័យពូជសាសន៍ប៉ុល ពត)។
- តំណាង **ព្រះបាទជ័យវរ្ម័នទី៧** ជាអង្គក្សត្រដែលមានបញ្ញាញាណខ្ពង់ខ្ពស់ក្នុងការដឹកនាំអាណាចក្រខ្មែរបានរីកចម្រើនដល់កំពូលនាសម័យមហានគរនៃយើង។
- តំណាង **មហាសមុទ្រទាំង៧** នៃចក្រវាល គឺមហាសមុទ្រប៉ាស៊ីហ្វិចខាងជើង មហាសមុទ្រប៉ាស៊ីហ្វិចខាងត្បូង មហាសមុទ្រអាត្លង់ទិចខាងជើង មហាសមុទ្រអាត្លង់ទិចខាងត្បូង មហាសមុទ្រអាកទិច មហាសមុទ្រឥណ្ឌា និងមហាសមុទ្រអង់តាកទិច។
- តំណាង **សិល្បៈច្បងទាំង៧** មាន អក្សរសិល្ប៍ ស្ថាបត្យកម្ម ចម្លាក់ គំនូរ តន្ត្រី របាំ និងភាពយន្ត។
- តំណាង **សេរីភាពសិល្បៈទាំង៧** នៃការអប់រំចំណេះដឹងជាមូលដ្ឋាននាសម័យបុរាណ មាន វោហាសាស្ត្រ វេយ្យាករណ៍ គ្រាមភាសា គណិតសាស្ត្រ តារាសាស្ត្រ ភូមិសាស្ត្រ និងសិល្បៈតន្ត្រី។
- តំណាង **ញាតិសន្តានទាំង៧** រាប់ក្នុងពូជពង្សខ្មែរមានតាទួត យាយទួត ជីតាជីដូន ឪពុកម្តាយ ខ្លួនយើង កូន ចៅ ចៅទួត។
- តំណាង **ថ្ងៃទាំង៧ប្រចាំសប្តាហ៍** កំណត់ពីជោគរាសីរបស់មនុស្សគ្រប់រូប។

# ផ្នែកទី២
# គុណកថា ប្រវត្តិរូប សកម្មភាពការងារ និង សមិទ្ធផលបម្រើជាតិមាតុភូមិរបស់ ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន

## ១- គុណកថា

១- លោក **អ៊ុក រ៉ាប៊ុន** សញ្ជាតិខ្មែរ កើតនៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៥១ នៅភូមិកំពង់ចំឡង ឃុំកំពង់ចំឡង ស្រុកស្វាយរៀង (បច្ចុប្បន្នស្រុកស្វាយជ្រំ) ខេត្តស្វាយរៀង។ លោកឪពុក **អ៊ុក សេម** និងអ្នកម្តាយ **កែវ សំ** (លោកទាំងពីរបានចែកឋានទៅហើយ) ដែលមានបងប្អូនប្រុសស្រីចំនួន៨នាក់ ដោយលោកជាកូនទី៤ និងមានទីលំនៅអចិន្ត្រៃយ៍នៅភូមិគយត្របែក ដែលពេលនោះ ស្ថិតនៅជាតំបន់ជាយក្រុងនៅឡើយ ហើយបច្ចុប្បន្នជាភូមិរពង បន្លែ សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង។ ភរិយាឈ្មោះ **គីម រ៉ាទី** បានចែកឋានហើយ និងមានកូនចំនួន៤នាក់ ស្រី២នាក់ និងប្រុស២នាក់ (កូនស្រីច្បងស្លាប់ក្នុងរបបប៉ុល ពត)។

២- **តាំងពីចាប់ផ្តើមចូលរៀនថ្នាក់កុមារដ្ឋាន នៅសាលាបឋមសិក្សាស្វាយរៀងក្រុង ឆ្នាំសិក្សា ១៩៥៧-១៩៥៨** លោក **អ៊ុក រ៉ាប៊ុន** តែងតែទទួលបានលទ្ធផលសិក្សាល្អ និងបានបន្តឡើងថ្នាក់ជានិច្ចរៀងរាល់ឆ្នាំ រហូតប្រឡងជាប់ពេញសិទ្ធិបានចូលរៀនបន្តនៅវិទ្យាល័យព្រះសូរិយោវង្ស (បច្ចុប្បន្នវិទ្យាល័យស្វាយរៀង) នៃខេត្តស្វាយរៀង ក្នុងឆ្នាំ១៩៦៣។ កាលនោះ សិស្សដែលប្រឡង

ជាប់ពេញសិទ្ធិត្រូវបង់វិភាគទាន១០០០រៀល រីឯសិស្សដែលប្រឡងជាប់បម្រុងត្រូវបង់៣០០០រៀល ទើបអាចចូលរៀនបាន។ ក្នុងនាមជាគ្រួសារក្រីក្រ លោកឪពុកតែងតែទូន្មានបង្គប់ដោយការលើកទឹកចិត្តថា «**ឪគ្មានកេរចែកឱ្យទេ គឺមានតែឱ្យសាលារៀនហ្នឹងហើយជាកេរ**»។

៣- **ដោយមានមហិច្ឆតា និងការប្តេជ្ញាចិត្តខ្ពស់ ព្រមទាំងមានការខិតខំព្យាយាមអត់ធ្មត់ និងស្វះស្វែងធ្វើស្វ័យសិក្សាបន្ថែម និងដោយមានការជួយជ្រោមជ្រែងពីសាស្ត្រាចារ្យ និងមិត្តភក្តិផង** ទោះបីជាគ្មានលទ្ធភាពថវិកាគ្រប់គ្រាន់សម្រាប់ទិញសៀវភៅអាន និងបង់ថ្លៃរៀនឈ្នួលពេលល្ងាចបន្ថែមយ៉ាងណាក៏ដោយ ក៏លោក **អ៊ុក រ៉ាប៊ុន** មិនត្រឹមតែបានប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ(ឌីប្លូម)នៅឆ្នាំ១៩៦៧ ដោយជោគជ័យ និងបានបន្តរៀនថ្នាក់ទី២ទំនើបជាតិនៅវិទ្យាល័យព្រះសុរិយោវង្សដដែលប៉ុណ្ណោះទេ លោកថែមទាំងជាសិស្សពូកែ ហើយបានប្រឡងផ្ដោះយកសញ្ញាប័ត្រស្នាតកប័ត្រភាគទី១ (បាក់អង) នៅឆ្នាំ១៩៦៨ ដោយជោគជ័យដូចក្ដីប្រាថ្នា។ មិនតែប៉ុណ្ណោះ លោកបានទទួលជ័យលាភីក្នុងការប្រឡងជ្រើសរើសគរុសិស្សនៅឆ្នាំ១៩៦៨ ដដែលនេះទៀតផង។

៤- **ដោយគោរពតាមដំបូន្មាន«ធ្វើការផងរៀនផង»របស់ម្ដាយ និងដោយស្ថានភាពគ្រួសារក្រលំបាកផង** លោក **អ៊ុក រ៉ាប៊ុន** ក៏បានសម្រេចចិត្តចូលរៀនជា គរុសិស្សនៅមហាវិទ្យាល័យគរុកោសល្យខាងជើង ដែលកាលនោះស្ថិតនៅខាងលិចវិទ្យាល័យព្រះស៊ីសុវត្ថិ ក្នុងបំណងរកការងារធ្វើដើម្បីបានប្រាក់ចំណូល

ជួយផ្គត់ផ្គង់គ្រួសារ។ ទោះដោយយ៉ាងណាក៏ដោយ ការសម្រេចចិត្តនេះ មិនបានបញ្ឈប់មហិច្ឆតាក្នុងការរៀនសូត្ររបស់លោកនោះទេ។ នៅក្នុងឆ្នាំនោះ ដោយខ្វះលទ្ធភាពឧបត្ថម្ភពីសំណាក់ក្រុមគ្រួសារ លោកត្រូវស្នាក់អាស្រ័យនៅកុដិលេខ២៨ របស់ព្រះគ្រូ **ហ៊ី ជា** ស្ថិតនៅខាងជើងព្រះវិហារទល់មុខទីប៉ាឆានៃវត្តបទុមវត្តី ហើយខិតខំព្យាយាមសម្របខ្លួនជាមួយស្ថានភាពរស់នៅតាមយថាកម្មរហូតដល់ពេលខ្លះខ្វះលុយទិញ«បាយស៊ីក្លូ» ហូបម្តងម្កាលក៏មាន ឃ្លាតឆ្ងាយពីរង្វង់គ្រួសារដោយម្ចាស់ការខ្លួនឯងដើម្បីរៀននៅមហាវិទ្យាល័យគរុកោសល្យផង និងស្វ័យសិក្សានូវមុខវិជ្ជាទាំងឡាយនៃថ្នាក់ទីបញ្ចប់ផង។ ដោយអត់លុយបង់ថ្លៃរៀនឈ្នួល ម្ល៉ោះហើយទើបស្ទើររៀងរាល់អាទិត្យ លោកតែងខំសង្វាតទៅកាន់វិទ្យាល័យឯកជនមួយស្ថិតនៅម្តុំខាងជើងវិទ្យាល័យព្រះយុគន្ធគឺវិទ្យាល័យវឌ្ឍនវិជ្ជា ឈររោបឬជួនកាលអង្គុយខាងក្រៅថ្នាក់រៀនដើម្បីត្រងត្រាប់ស្តាប់ការពន្យល់មេរៀនពីសាស្ត្រាចារ្យពិសេសមេរៀនរូបវិទ្យា និងគណិតវិទ្យា។ កាលណាមានពេលទំនេរ មិនថាពេលថ្ងៃ ឬពេលល្ងាចទេ លោកតែងដើរចំប្រប់សាចុះសាឡើងតាមតូបលក់សៀវភៅនៅផ្សារចាស់និងបណ្ណាគារនានា ហើយរំពៃបើករកមើលអំពីវិធីស្រាយបញ្ជាក់នូវលំហាត់មេរៀនទាំងឡាយមានចែងក្នុងសៀវភៅកំណែប្លែកៗដែលគេដាក់បង្ហាញលក់នៅទីនោះ។ អាស្រ័យហេតុនេះ ហើយ ទើបលោកមានសមត្ថភាពអំណោយផលទទួលបានសញ្ញាប័ត្រពីរគឺ **«សញ្ញាប័ត្របញ្ចប់ការសិក្សាជាគរុសិស្សពីមហាវិទ្យាល័យគរុកោសល្យផង និងសញ្ញាប័ត្រស្នាតកប័ត្រភាគទី២ (បាក់ឌុប)**

**ផង»** ក្នុងឆ្នាំតែមួយ គឺឆ្នាំ១៩៦៩។ បន្ទាប់មកលោកបានចាប់ផ្ដើមអាជីពដំបូងរបស់ខ្លួនក្នុងវ័យ១៨ឆ្នាំ ជាគ្រូបង្រៀនបឋមសិក្សានៅខេត្តស្វាយរៀងក្នុងឆ្នាំសិក្សា ១៩៦៩-១៩៧០ ដែលជាមុខរបរមួយទទួលបានការផ្ដល់តម្លៃ និងកិត្តិយសពីសង្គមជាតិទៀតផង។

៥- **អាស្រ័យដោយការប្រណិប័តន៍យ៉ាងខ្ជាប់នូវឱវាទ «យកសាលារៀនជាកេរ» របស់ឪពុក** និង**«ធ្វើការផងរៀនផង» របស់ម្ដាយជាមួយនឹងមហិច្ឆតា និងការប្ដេជ្ញាចិត្តខ្ពស់** លោក **អ៊ុក វ៉ាប៊ុន** ទទួលបានជ័យលាភីម្ដងទៀតក្នុងការប្រឡងជ្រើសរើសនិស្សិតសាស្ត្រាចារ្យនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៧០។ លោកបានចូលរៀននៅមហាវិទ្យាល័យគរុកោសល្យជាលើកទី២ សម្រាប់រយៈពេល២ឆ្នាំ (១៩៧០-១៩៧២) ហើយត្រូវប្ដូរអាជីពពីគ្រូបង្រៀនបឋមសិក្សាទៅជាសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិផ្នែករូបវិទ្យា-គីមី។ ដោយយោងទៅតាមលទ្ធផលនៃការសិក្សាក្នុងវគ្គបណ្ដុះបណ្ដាលពីរឆ្នាំនេះ លោកត្រូវបានចាត់តាំងឱ្យចេញទៅបង្រៀននៅវិទ្យាល័យទេពប្រណម្យក្នុងខេត្តកណ្ដាលដែលមានចម្ងាយ៣៨គ.ម. ពីភ្នំពេញតាមផ្លូវជាតិលេខ៥។ ក្នុងបំណងបង្កើននិងពង្រីកពុទ្ធិ ជាពិសេសចំណេះដឹងខាងវិទ្យាសាស្ត្រសង្គម និងសេដ្ឋកិច្ច ជាមួយនឹងការព្យាយាមនិងអត់ធ្មត់ខ្ពស់នោះ ទោះបីជាស្ថិតក្នុងលក្ខខណ្ឌនៃការរស់នៅដ៏លំបាកយ៉ាប់យ៉ឺននាសម័យកាលក្រោយឆ្នាំ១៩៧០ ក៏ដោយ លោកបានតស៊ូបន្តធ្វើជាសាស្ត្រាចារ្យរូបវិទ្យា-គីមីផង និងជានិស្សិតរៀននៅផ្នែកវិទ្យាសាស្ត្រ

សេដ្ឋកិច្ច នៅមហាវិទ្យាល័យច្បាប់និងវិទ្យាសាស្ត្រសេដ្ឋកិច្ចផង នៅទីក្រុងភ្នំពេញ រហូតដល់ឆ្នាំ១៩៧៥។

៦- **នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥** វេលាថ្ងៃជ្រេបន្តិច លោក **អ៊ុក វ៉ាប៊ុន** និងក្រុមគ្រួសារត្រូវបានមនុស្ស២នាក់ ស្លៀកពាក់ឯកសណ្ឋានពណ៌ខ្មៅ អាវក្រៅខោ ក្រមាបង់ក ដៃកាន់កាំភ្លើងវែងជាកងទ័ពរបស់អង្គការប៉ុល ពត ចូលទៅគំរាមបង្ខំឱ្យចាកចេញពីផ្ទះស្ថិតនៅម្តុំខាងកើតផ្សារដេប៉ូ ដោយយកទៅជាប់នឹងខ្លួនតែបង្វិចខោអាវ ចានឆ្នាំងនិងអង្ករបន្តិចបន្តួចប៉ុណ្ណោះ ដូចប្រជាពលរដ្ឋទាំងឡាយដទៃទៀតនៃក្រុងភ្នំពេញដែរ។ តាមបទបញ្ជារបស់ពួកអង្គការ លោក **អ៊ុក វ៉ាប៊ុន** ត្រូវចេញតាមវិថីទេពផនទៅខាងលិចរហូតដល់មហាវិថីម៉ៅ សេទុង បត់ស្តាំឆ្ពោះទៅកាន់មហាវិថីសហព័ន្ធរុស្ស៊ីរួចធ្វើដំណើរទៅទិសខាងលិច។ លោក **អ៊ុក វ៉ាប៊ុន** ដើរយឺតៗជាមួយហ្វូងមនុស្សច្រើនណែនពេញទ្រូងមហាវិថី។ នៅវេលាព្រលប់ថ្ងៃលិច លោកទើបតែដើរដល់ត្រឹមសួនច្បារខាងមុខផ្សារពោធិ៍ចិនតុងប៉ុណ្ណោះ។ បន្ទាប់ពីហូបបាយរួចហើយ យប់នោះលោក **អ៊ុក វ៉ាប៊ុន** ដេកនៅក្រោមដើមឈើធំមួយស្ថិតនៅចុងខាងកើតសួនច្បារ។ លុះព្រឹកឡើងលោកបន្តដំណើរទៅឈប់សម្រាកក្នុងវត្តសុភាឃួនខាងលិចព្រលានយន្តហោះ ហើយស្នាក់នៅទីនោះអស់រយៈពេលជាងមួយអាទិត្យទើបធ្វើដំណើរតាមផ្លូវជាតិលេខ៣ស្នាក់នៅជាបន្តបន្ទាប់តាមដងផ្លូវដោយមិនទាន់កំណត់ក្នុងចិត្តថាទៅទីណាច្បាស់លាស់នៅឡើយ។ លុះដល់ប្រហែលជិតពាក់កណ្តាលខែឧសភាទើបលោក **អ៊ុក វ៉ាប៊ុន** សម្រេចចិត្តថាត្រូវនាំគ្នាទៅ

ស្រុកកំណើត ដោយចាប់ផ្ដើមចេញដំណើរពីម្ដុំភ្នំបត់រការ ដើរកាត់វាលស្រែនិងភូមិនានាឆ្ពោះទៅខាងកើតតម្រង់ទៅរកទន្លេបាទី ហើយស្នាក់នៅក្នុងភូមិខាងត្បូងប្រាសាទបុរាណមួយរយៈខ្លីសិនព្រោះពេលនោះមានភ្លៀងកក់ខែហើយ។ ចេញពីទន្លេបាទីលោក **អ៊ុក វ៉ាប៊ុន** មកសម្រាកមួយយប់នៅកណ្ដាលវាលជាយភូមិប៉ែកខាងជើងនៃភ្នំស្អាង។ នៅយប់នោះ មានទឹកសន្សើមធ្លាក់ច្រើនបណ្ដាលឱ្យកូនស្រីរបស់លោកដែលមានអាយុជាង២ខួបមានអាការៈក្ដៅខ្លួនខ្លាំងបង្កចេញជាជំងឺកញ្ជ្រឹល ស រុំរ៉ែ។ លុះព្រលឹមឡើងលោកបន្តដំណើរឆ្លងទន្លេបាសាក់ដើរកាត់តាមភូមិទុយយោប្រាសាទដែលជាភូមិសម្បូរទៅដោយត្រីបឹងបំផុតឆ្ពោះទៅកាន់ផ្លូវជាតិលេខ១ត្រង់ម្ដុំឃុំគគីធំ។ ក្នុងដំណើរបន្តលោកត្រូវនាំគ្នាជិះទូកឆ្លងទន្លេអ្នកលឿង រួចត្រូវដើរច្រើនថ្ងៃទើបទៅដល់ខេត្តស្វាយរៀង នៅដើមខែមិថុនា។ មកដល់ស្វាយរៀងលោក **អ៊ុក វ៉ាប៊ុន** បានជួបក្រុមគ្រួសារខាងប្រពន្ធរួចនាំគ្នាទៅស្នាក់នៅជាមួយប្រជាជនចាស់ (ឬអ្នកជាក់ក្រាញព្រោះអ្នកនោះនៅខាងតំបន់រំដោះតាំងពីមុនមក) ម្ដុំខាងជើងវត្តជ្រៃក្ដោង ភូមិតានូឃុំចំបក់ ស្រុកស្វាយជ្រំ។ បួនប្រាំថ្ងៃក្រោយមក អង្គការប៉ុល ពតបាននាំយករូបលោកបញ្ជូនឱ្យទៅរៀនសូត្រលត់ដំខ្លួនក្នុងកន្លែងឃុំឃាំងមនុស្សនៅវត្តស្លា ឃុំឈើទាល ស្រុកស្វាយជ្រំ។ នៅទីនោះលោកបានជួបឪពុកក្មេកជាគ្រូបង្រៀនដែលអង្គការបានយកមកឃុំឃាំងតាំងពីកំលុងខែឧសភាម្ល៉េះ។ ចំណែកឯក្រុមគ្រួសារលោកក៏ស្រុះស្រួលនាំគ្នាធ្វើដំណើរទៅរស់នៅក្នុងសហករណ៍ភូមិកោះដូនសយ ឃុំប្រេស ស្រុកចន្ទ្រា ខេត្តស្វាយរៀង ដែលជា

ស្រុកកំណើតឪពុកក្មេកលោក។ នៅពាក់កណ្ដាលខែសីហា អង្គការបានដោះលែងអ្នកដែលជាប់ឃុំឃាំងនៅវត្តស្លាទាំងអស់។ បន្ទាប់មក លោក **អ៊ុក វ៉ាយ៉ុន** និងឪពុកក្មេកត្រូវបានអង្គការដាក់ទិសឱ្យមករស់នៅឯភូមិតាន្ទ ឃុំចំបក់វិញ។ ដោយបានទទួលដំណឹងអំពីទីកន្លែងដែលក្រុមគ្រួសារលោកកំពុងរស់នៅច្បាស់លាស់ហើយ ឪពុកនិងកូនបានស្នើសុំអនុញ្ញាតពីអង្គការរួចចេញដើររាប់សិបគីឡូម៉ែត្រដោយមានលិខិតបើកផ្លូវនៅជាប់នឹងខ្លួនផង រហូតដល់បានជួបក្រុមគ្រួសារ ប្រពន្ធកូនរួមរស់ជុំគ្នាក្នុងក្ដីភ័យបារម្ភទុក្ខព្រួយជាប់ជានិច្ច ព្រោះមានងារគេហៅថាជាប្រជាជនថ្មី ឬប្រជាជន១៧មេសា ដែលរងការប្រមាញ់តាមដានរកចាប់កំហុសពីអង្គការភ្នែកម្នាស់លើសកម្មភាព និងការនិយាយស្ដីគ្រប់ជំហាន គ្រប់ទីកន្លែង និងគ្រប់ពេលវេលាទាំងអស់។ ទុក្ខជាន់លើទុក្ខ ក្នុងកំលុងពេលដែលលោក **អ៊ុក វ៉ាយ៉ុន** រស់នៅយ៉ាងលំបាកវេទនា ហូបតែបបររាវ រាងកាយទ្រុឌទ្រោម ស្គមស្គាំង គ្មានសាប៊ូប្រើ សម្លៀកបំពាក់ចាស់រេចរឹលប្រៀបបាននឹងកន្ទប មួយថ្ងៃៗខិតខំធ្វើការហាត់ពត់លត់ដំសម្របខ្លួនទៅតាមការដាក់ទិសរបស់អង្គការ ក្នុងអារម្មណ៍ទុក្ខព្រួយភ័យតក់ស្លុតខ្លាចតែអង្គការចាប់យកទៅប្រល័យជីវិតនាពេលណាមួយនោះ កូនស្រីរបស់លោកបានជួបនូវរឿងអកុសលគួរឱ្យសង្វេកក្រៃលែង។ ដោយគ្មានថ្នាំសង្កូវសម្រាប់ព្យាបាល គ្មានអាហារហូបគ្រប់គ្រាន់ ស្ថានភាពជំងឺរបស់កូនបានវិវត្តកាន់តែធ្ងន់ធ្ងរដុនដាបទៅជាលំដាប់រហូតដល់ថ្ងៃអាទិត្យ ទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ កុមារី **អ៊ុក ចិន្ដានាថ** បានទទួលមរណភាពយ៉ាងអាណោច

អាធម្មជាទីបំផុត។ ដោយមើលឃើញពីវិនាសកម្មបំផ្លិចបំផ្លាញជាតិកាន់តែរីករាលដាលខ្លាំងឡើងៗនិងមិនអាចទ្រាំទ្រនឹងគំនាបព្រមទាំងការធ្វើទុក្ខបុកម្នេញកាន់ តែសាហាវឃោរឃៅ នៅសល់តែការមកដល់នូវពេលវេលាដែលអង្គការត្រូវយកទៅប្រហារជីវិតតែប៉ុណ្ណោះ នោះនៅចុងឆ្នាំ១៩៧៧ លោកក៏បានប្តេជ្ញាចិត្តទាំងប្រថុយប្រថានប្រកបដោយគ្រោះថ្នាក់បំផុត រត់គេចខ្លួនឆ្លងព្រំដែនទៅរស់នៅប្រទេសវៀតណាម រហូតដល់ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ទើបវិលត្រឡប់មករស់នៅទីក្រុងភ្នំពេញនៃមាតុប្រទេសវិញ។

៧- **ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩** លោក **អ៊ុក វ៉ាច៊ុន** បានចូលបម្រើការងាររដ្ឋ ដោយបានចាប់ផ្តើមពីការរួមចំណែករៀបចំបង្កើត និងដាក់ឱ្យដំណើរការក្រសួងគមនាគមន៍ ដឹកជញ្ជូន និងប្រៃសណីយ៍តាំងពីដំណាក់កាលដំបូងដែលពេលនោះទទួលបានត្រឹមតែរបបឧបត្ថម្ភពោតក្រហមស្ងោរមួយថ្ងៃពីរពេលដែលចម្អិនចែកគ្នានៅកន្លែងធ្វើការផ្ទាល់តែប៉ុណ្ណោះ។ នៅក្នុងឆ្នាំ១៩៨០ លោកបានចូលរួមបេសកកម្មរបស់គណៈកម្មាធិការរំដោះស្បៀងនិងសម្ភារៈពីកំពង់ផែកំពង់សោមមកក្រុងភ្នំពេញ ដឹកនាំបញ្ជាផ្ទាល់ដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលកាលនោះ សម្តេចជាអនុប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងជាប្រធានគណៈកម្មាធិការនេះ។ ដោយសារសមត្ថភាពនិងការខិតខំតស៊ូព្យាយាមក្នុងការងារគួបផ្សំនឹងចំណេះដឹងច្រើន ជាពិសេស ចំណេះដឹងខាងភាសាបារាំង រុស្ស៊ី វៀតណាម អង់គ្លេស លោកបានកសាងស្នាដៃជាច្រើនជូន

ក្រសួង ហើយក៏ទទួលបានការតែងតាំងជាអនុប្រធានមន្ទីរនៅឆ្នាំ១៩៨១។ បន្ទាប់មក ដោយសារលោកជាបញ្ញវន្តមួយរូបប្រកបដោយចំណេះវិជ្ជាគួបផ្សំនឹងស្នាដៃឆ្នើមមានទេពកោសល្យពីកំណើត ព្រមទាំងនិស្ស័យការងារផងនោះ និងជាពិសេសដោយមើលឃើញអំពីសមត្ថភាពនិងសក្តានុពលរបស់លោកដែលប្រទេសជាតិកំពុងត្រូវការនោះ ថ្នាក់ដឹកនាំក៏បានចាត់តាំងឱ្យលោកផ្លាស់ទៅបម្រើការងារនៅក្រសួងផែនការវិញ។

៨- **ក្រោយពីបានផ្លាស់ទៅបម្រើការងារនៅក្រសួងផែនការមក** លោក **អ៊ុក រ៉ាប៊ុន** បានចូលរួមយ៉ាងសកម្មក្នុងការងាររៀបចំផែនការរដ្ឋ ស្តារ និងកសាងសេដ្ឋកិច្ច សង្គមកិច្ច ដែលជាផែនការប្រមូលផ្តុំ និងមានលក្ខណៈជាអាជ្ញាបញ្ជា និងដោយអនុលោមតាមក្រឹត្យក្រមនៃប្រព័ន្ធ**សេដ្ឋកិច្ចផែនការគួបផ្សំនឹងទីផ្សារ** ក្នុងបរិបទនៃការរស់ឡើងវិញរបស់មាតុភូមិកម្ពុជា។ នៅក្នុងដំណាក់កាលនៃការអនុវត្តសេដ្ឋកិច្ចផែនការគួបផ្សំទីផ្សារកម្ពុជាមានសមាសភាគសេដ្ឋកិច្ច៣ គឺ (១) សមាសភាគសេដ្ឋកិច្ចរដ្ឋ, (២) សមាសភាគសេដ្ឋកិច្ចសមូហភាព និង (៣) សមាសភាគសេដ្ឋកិច្ចគ្រួសារ។ នៅចុងឆ្នាំ១៩៨១ នៅក្នុងតួនាទីរបស់លោកជាអនុប្រធាននាយកដ្ឋានផែនការទូទៅ លោកបានចូលរួមចំណែកក្នុងការកសាង**សេចក្តីព្រាងច្បាប់ផែនការ ស្តីពីសេដ្ឋកិច្ច-សង្គមកិច្ចប្រចាំឆ្នាំ១៩៨២** ជាផែនការសេដ្ឋកិច្ចលើកដំបូងដែលបានអនុម័ត និងបានដាក់ឱ្យអនុវត្តសម្រាប់រយៈពេលមួយឆ្នាំ។ កាលនោះនៅរៀងរាល់ចុងឆ្នាំ ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលជាស្ថាប័ននីតិប្រតិបត្តិ ត្រូវដាក់ជូនរដ្ឋសភាជាស្ថាប័ននីតិប្បញ្ញត្តិនូវ**សេចក្តី**

**ព្រាងច្បាប់ផែនការ ស្ដីពីសេដ្ឋកិច្ច-សង្គមកិច្ចប្រចាំឆ្នាំ** ដែលខ្លឹមសារសំខាន់ គឺការត្រួតពិនិត្យលទ្ធផលនៃការអនុវត្តផែនការក្នុងឆ្នាំកំពុងដំណើរការ និងការកំណត់ទិសដៅ គោលដៅ ភារកិច្ច និងវិធានការសម្រាប់អនុវត្តឆ្នាំបន្ទាប់។ យន្តការនៃផែនការូបនីយ-កម្មសេដ្ឋកិច្ចរបៀបនេះ បានដំណើរការរហូតដល់មានការបោះ-ឆ្នោតជាសកលនាឆ្នាំ១៩៩៣។

៩- **ដោយសារស្នាដៃការងារ និងសមត្ថភាពខាងភាសា និងមុខជំនាញ និងភាពជាអ្នកដឹកនាំរបស់លោកនៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៨៦** លោក **អ៊ុក រ៉ាប៊ុន** បានទទួលការទុកចិត្ត និងបានតែងតាំងជាអនុរដ្ឋមន្ត្រីក្រសួងផែនការ។ តួនាទីនេះ រឹតតែជំរុញឱ្យលោកខិតខំប្រឹងប្រែងទ្វេដងថែមទៀត ក្នុងការបង្កើនពុទ្ធិ និងពង្រីកចំណេះដឹងទូទៅឱ្យបានកាន់តែទូលំទូលាយ ជាពិសេសមុខជំនាញសេដ្ឋកិច្ច និងនយោបាយ។ នៅឆ្នាំដដែលនោះ លោកក៏ត្រូវចាត់តាំងឱ្យចូលរៀនក្នុងវគ្គសិក្សាវិទ្យាសាស្ត្រនយោបាយជាន់ខ្ពស់រយៈពេលវែងថែមទៀតផង។

១០- **សមត្ថភាព ជំហរស្មោះត្រង់ និងភាពហ្មត់ចត់ក្នុងការងាររបស់លោកកាន់តែបានទទួលស្គាល់ ហើយនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៨៧** លោក **អ៊ុក រ៉ាប៊ុន** ត្រូវតែងតាំងជាអនុប្រធានខុទ្ទកាល័យមជ្ឈិមបក្ស និងជាជំនួយការផ្ទាល់របស់ **សម្តេចអគ្គ-មហាពញាចក្រី ហេង សំរិន** ទទួលជួយក្នុងកិច្ចការសេដ្ឋកិច្ច ដែលកាលនោះ **សម្តេច** ជាប្រធានក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា និងជាអគ្គលេខាធិការនៃគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍កម្ពុជា។ ក្នុងតួនាទីនោះហើយដែល

លោកបានរួមចំណែកក្នុងការរៀបចំតាក់តែងធ្វើ**សេចក្តីព្រាងគោលនយោបាយកសាងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ** តាមរយៈការដាក់ឱ្យដំណើរការនូវសមាសភាគសេដ្ឋកិច្ចចំនួនពីរបន្ថែមទៀត គឺសមាសភាគសេដ្ឋកិច្ចឯកជន និងសមាសភាពគសេដ្ឋកិច្ចចម្រុះរដ្ឋ-ឯកជន ទៅលើសមាសភាគសេដ្ឋកិច្ចចំនួនបី (សមាសភាគសេដ្ឋកិច្ចគ្រួសារ សេដ្ឋកិច្ចសមូហភាព និងសេដ្ឋកិច្ចរដ្ឋ) ដែលកំពុងមានអត្ថិភាពនាពេលនោះ។ ហេតុនេះហើយបានជាចាប់តាំងពីឆ្នាំ១៩៨៩ មក ប្រព័ន្ធសេដ្ឋកិច្ចផែនការគួបផ្សំនឹងទីផ្សារដែលការរៀបចំផែនការមានលក្ខណៈជាអាជ្ញាបញ្ជា (Imperative Plan) បានកែទម្រង់ទៅជាប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ដែលបានរៀបចំផែនការបែបចង្អុលបង្ហាញ (Indicative Plan) វិញ ហើយយន្តការថ្មីក៏បានបើកទូលាយឱ្យដំណើរការកាន់តែខ្លាំងក្លា និងយ៉ាងឆាប់រហ័សជាមួយនឹងសហត្ថិភាពប្រកបដោយសុខដុមនីយកម្ម និងកិច្ចប្រតិបត្តិការព្រមគ្នារវាងសមាសភាគសេដ្ឋកិច្ចប្រាំគឺ **សមាសភាគសេដ្ឋកិច្ចគ្រួសារ សេដ្ឋកិច្ចសមូហភាព សេដ្ឋកិច្ចរដ្ឋ សេដ្ឋកិច្ចឯកជន និងសេដ្ឋកិច្ចចម្រុះរដ្ឋ-ឯកជន**រហូតមក។

១១- **ដោយសារស្នាដៃក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ គួបផ្សំនឹងបទពិសោធន៍ការងាររបស់លោក នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩០** លោក **អ៊ុក រ៉ាប៊ុន** បានផ្ទេរការងារទៅធ្វើជាអនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងទទួលភារកិច្ចឱ្យរៀបចំតាក់តែង **«សេចក្តីព្រាងច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម»** ដែលបានអនុម័ត និងដាក់ឱ្យអនុវត្ត ដើម្បីបើកផ្លូវឱ្យយន្តការសេដ្ឋកិច្ចទីផ្សារអាចដំណើរការបានកាន់តែល្អប្រសើរ ស្របតាម

ការវិវត្តរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ចជាតិនាពេលនោះ។ ឈរលើមូលដ្ឋាននៃច្បាប់នេះ ហើយដែលច្បាប់ពាណិជ្ជកម្ម បណ្តាគោលការណ៍ និងគោលនយោបាយជាច្រើនទៀតក្នុងវិស័យ សេដ្ឋកិច្ចត្រូវបានរៀបចំអនុម័ត និងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់។ បទពិសោធន៍ក្នុងការងារជាក់ស្តែងទាំងនេះជាមួយនឹងមហិច្ឆតា និងបណ្តាំ«**យកសាលារៀនជាកេរ និងធ្វើការផងរៀនផងរបស់ឪពុកម្តាយ**» គឺពិតជាបានក្លាយជាកត្តាជំរុញយ៉ាងស័ក្តិសិទ្ធិ ដែលធ្វើឱ្យគំនិតគិតប៉ងសរសេរនិក្ខេបបទរបស់លោក បានលេច ចេញកាន់តែច្បាស់រហូតលោកធ្វើបានសម្រេចក្នុងការតាក់តែង និក្ខេបបទថ្នាក់បណ្ឌិត ឯកទេសវិទ្យាសាស្ត្រសេដ្ឋកិច្ចនៅឆ្នាំ១៩៩០ ក្រោមប្រធានបទស្តីពី«**ផែនការូបនីយកម្មក្នុងបរិបទដែលកម្ពុជាមានច្រើនសមាសភាគសេដ្ឋកិច្ច**» ដែលខ្លឹមសារនិក្ខេបបទនេះ គឺ ជាជំហានមូលដ្ឋានក្នុងការកសាងសេដ្ឋកិច្ចទីផ្សារនៅកម្ពុជា ដោយប្រែក្លាយការធ្វើផែនការជាលក្ខណៈចង្អុលបង្ហាញ (Indicative plan) ជំនួសការធ្វើផែនការបែបប្រមូលផ្តុំនិងជា លក្ខណៈអាជ្ញាបញ្ជា (Imperative plan)។

១២- **អាស្រ័យដោយមានបទពិសោធន៍ក្នុងពេលបំពេញការងារជាក់ស្តែងប្រចាំថ្ងៃរបស់ខ្លួនចន្លោះឆ្នាំ១៩៨១-១៩៨៦ នៅក្រសួងផែនការផង** (គប្បីចងចាំថានៅឆ្នាំ១៩៨១ រដ្ឋសភាបានអនុម័ត ជាលើកដំបូងនូវច្បាប់ផែនការសេដ្ឋកិច្ចរដ្ឋឆ្នាំ១៩៨២ដែលមាន លក្ខណៈប្រមូលផ្តុំ និងជាច្បាប់សម្រាប់អនុវត្តនៅឆ្នាំ១៩៨២) មួយអន្លើដោយគួបផ្សំនឹងការទទួលបាននូវចំណេះវិជ្ជាជាន់ខ្ពស់ ពីការសិក្សានៅចន្លោះឆ្នាំ១៩៨៦-១៩៨៧ ផង ព្រមទាំងដោយ

ធ្លាប់បានចូលរួមចំណែកក្នុងការសរសេរតែងសេចក្តីព្រាងដើម នៃបណ្តាឯកសារ (ដោយស្មារតីគោរពយ៉ាងខ្ជាប់ខ្ជួនតាមការ ចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំ) សម្រាប់ដាក់ឆ្លងសន្និបាតកម្មា-ភិបាលទូទាំងប្រទេសលើកទី២នាខែមេសា ឆ្នាំ១៩៨៩ ផងនោះ (ពាក់ព័ន្ធនឹងការកំណត់ដាក់ចេញនូវគោលការណ៍កែទម្រង់ ស៊ីជម្រៅសំខាន់ៗ ដើម្បីបង្កលក្ខណៈឱ្យសមាសភាគសេដ្ឋកិច្ច ឯកជន ឬសមាសភាគសេដ្ឋកិច្ចទីផ្សារដែលកំពុងមានអត្ថិភាព គួបផ្សំគ្នាជាមួយសមាសភាគដទៃស្រាប់រួចមកហើយ អាច ធ្វើសកម្មភាពបានកាន់តែទូលំទូលាយទៀតស្របតាមស្មារតី នៃមាត្រា១២នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៨១) លោក **អ៊ុក រ៉ាប៊ុន** បានប្រមូលផ្តុំនូវពុទ្ធិទាំងឡាយដែលបានសន្សំបង្គរទុកក្នុងខួរ ក្បាលរបស់លោក ដើម្បីចងក្រងជានិក្ខេបបទថ្នាក់បណ្ឌិត ស្តីពី ផែនការូបនីយកម្មក្នុងបរិបទ ដែលកម្ពុជាមានច្រើនសមាសភាគ សេដ្ឋកិច្ច (គឺសមាសភាគសេដ្ឋកិច្ចគ្រួសារ សេដ្ឋកិច្ចសមូហភាព សេដ្ឋកិច្ចរដ្ឋ សេដ្ឋកិច្ចឯកជន និងសេដ្ឋកិច្ចចម្រុះរដ្ឋ-ឯកជន)។ បន្ទាប់ពីបានឆ្លងកាត់ការវាយតម្លៃពីគណៈមេប្រយោគស្រេច បាច់រួចមក លោកបានទទួលជ័យលាភីជា «**បណ្ឌិត**» ខាងផ្នែក សេដ្ឋកិច្ច (Doctor of Philosophy in Economics) នៅ ឆ្នាំ១៩៩០ ។

ក្នុងនិក្ខេបបទ ការវិភាគចាប់ផ្តើមឡើងពីពេលបច្ចុប្បន្ន (ឆ្នាំ១៩៩០ជាឆ្នាំការពារនិក្ខេបបទ) ដែលកម្ពុជាកំពុងអនុវត្តតាម ប្រព័ន្ធសេដ្ឋកិច្ចផែនការគួបផ្សំទីផ្សារស្របទៅនឹងរចនាសម្ព័ន្ធនៃ ផលិតផលក្នុងស្រុកសរុប(ផសស) ដែលមានមាតិកាចំនួន៣ គឺ

វិស័យសេដ្ឋកិច្ចរដ្ឋ វិស័យសេដ្ឋកិច្ចសម្ូហភាព និងវិស័យសេដ្ឋកិច្ចឯកជន (គឺសម្រាប់សមាសភាគសេដ្ឋកិច្ចផ្សេងៗ ទៀតដែលកំពុងមានអត្ថិភាពក្រៅពីសមាសភាគសេដ្ឋកិច្ចទាំងពីរនេះ)។

និក្ខេបបទនេះ វិភាគបកស្រាយបញ្ហាក់អំពីយន្តការទាំងឡាយសម្រាប់បម្រើសេដ្ឋកិច្ចកម្ពុជានាពេលអនាគតក្នុងបរិបទនៃប្រព័ន្ធសេដ្ឋកិច្ចមួយមានច្រើនសមាសភាគ។ ប្រសិនបើសេដ្ឋ-កិច្ចកម្ពុជាត្រូវធ្វើបរិវត្តកម្ម បំប្លែងពីប្រព័ន្ធសេដ្ឋកិច្ចផែនការគួបផ្សំទីផ្សារ ឆ្លងកាត់សម័យអន្តរកាលជាជំហានៗយូរអង្វែងឆ្ពោះទៅកាន់ប្រព័ន្ធសេដ្ឋកិច្ចផែនការ ដែលមានសមាសភាគសេដ្ឋ-កិច្ចតែពីរប៉ុណ្ណោះ គឺ សេដ្ឋកិច្ចរដ្ឋ និងសេដ្ឋកិច្ចសម្ូហភាព នោះរចនាសម្ព័ន្ធនៃផលិតផលក្នុងស្រុកសរុប (ផសស) ត្រូវនៅសល់មាតិកាចំនួនតែពីរបន្ទាត់ដែរ គឺមួយសម្រាប់វិស័យសេដ្ឋកិច្ចរដ្ឋ និងមួយទៀតសម្រាប់វិស័យសេដ្ឋកិច្ចសម្ូហភាព។ ក្នុងន័យនេះ ផែនការូបនីយកម្មសេដ្ឋកិច្ច ត្រូវមានលក្ខណៈជារបបផែនការប្រមូលផ្តុំជាច្បាប់ ជាផែនការអាជ្ញាបញ្ជា(Imperative Plan) ដែលស្ថាប័ននីតិប្រតិបត្តិត្រូវដាក់ឆ្លងសេចក្តីព្រាងច្បាប់ ស្តីពីផែនការសេដ្ឋកិច្ចសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិជារៀងរាល់ឆ្នាំ។ យ៉ាងណាមិញ ដើម្បីឱ្យស្របទៅនឹងបរិបទនៃការជំរុញលើកទឹកចិត្តឱ្យច្រើនសមាសភាគដំណើរការយ៉ាងសកម្មដូចគ្នានោះ សេដ្ឋកិច្ចកម្ពុជាត្រូវទទួលយកនូវការកែទម្រង់ស៊ីជម្រៅដល់ឫសគល់ទូលំទូលាយគ្រប់ជ្រុងជ្រោយពីប្រព័ន្ធសេដ្ឋកិច្ចផែនការគួបផ្សំទីផ្សារឱ្យក្លាយទៅជាប្រព័ន្ធសេដ្ឋកិច្ចទីផ្សារដែលមានសមាស-ភាគសេដ្ឋកិច្ចច្រើន (សេដ្ឋកិច្ចគ្រួសារ សេដ្ឋកិច្ចសម្ូហភាព

សេដ្ឋកិច្ចរដ្ឋ សេដ្ឋកិច្ចឯកជន និងសេដ្ឋកិច្ចចម្រុះរដ្ឋ-ឯកជន) ស្របទៅនឹងរចនាសម្ព័ន្ធនៃផលិតផលក្នុងស្រុកសរុប (ផសស) ដែលមានមាតិកាចំនួន៣ គឺវិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម។

ក្នុងករណីនេះ ទោះបីជាត្រូវដាក់ឆ្លងស្ថាប័ននីតិបញ្ញត្តិក៏ដោយ ក៏ផែនការសេដ្ឋកិច្ចនេះ ពុំមានលក្ខណៈជាអាជ្ញាបញ្ញាទេ ពោលគឺជាការប្រកាន់យករបបផែនការចង្អុលបង្ហាញ (Indicative Plan) នៃសេដ្ឋកិច្ចទីផ្សារដោយយកម៉ាក្រូសេដ្ឋកិច្ចធ្វើជាឧបករណ៍ចម្បងសម្រាប់គ្រប់គ្រងការវិវត្តនៃខឿនសេដ្ឋកិច្ចជាតិ។

១៣- **សមត្ថភាពជំនាញ ស្នាដៃការងារ បទពិសោធន៍តាក់តែងច្បាប់ និងការដឹកនាំស្ថាប័ន ជាពិសេសភាពស្មោះត្រង់ និងភក្ដីភាពក្នុងការបម្រើជាតិ និងប្រជាជន** បានជួយឱ្យលោកកាន់តែទទួលបានឋានៈ និងមុខងារកាន់តែសំខាន់ក្នុងការរួមចំណែកស្តារ និងកសាងប្រទេសជាតិក្នុងរបត់ថ្មីនៃប្រវត្តិសាស្ត្រកម្ពុជា។ នៅឆ្នាំ១៩៩៣ លោក **អ៊ុក រ៉ាប៊ុន** មិនត្រឹមតែបានជាប់ឆ្នោតជាតំណាងរាស្ត្រនៃគណបក្សប្រជាជនកម្ពុជាប្រចាំមណ្ឌលកំពង់ឆ្នាំង ដែលជាសមាជិកសភាធម្មនុញ្ញប៉ុណ្ណោះទេ លោកថែមទាំងត្រូវបានជ្រើសរើសជាសមាជិកបម្រុងនៃគណៈកម្មការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញទៀតផង។ នៅពេលនោះហើយ ដែលលោកបានរួមចំណែកផ្តល់ធាតុចូលមួយចំនួន ជាពិសេស ជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ ចែងអំពីសេដ្ឋកិច្ចក្នុងបរិបទដែលព្រះរាជាណាចក្រកម្ពុជា អនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ។ បន្ទាប់មកលោកក៏បាន

ក្លាយជាតំណាងរាស្ត្រ សមាជិករដ្ឋសភានីតិកាលទី១ និងលោកត្រូវបានជ្រើសតាំងជាប្រធានគណៈកម្មការហិរញ្ញវត្ថុ និងធនាគារ (គណៈកម្មការទី៣) នៃរដ្ឋសភា។ ក្នុងតួនាទីដ៏សំខាន់នេះហើយដែលលោកមានឱកាសក្នុងការប្រើប្រាស់ចំណេះដឹង និងបទពិសោធន៍របស់លោក ដែលបានខិតខំសន្សំនិងដុសខាត់កន្លងមកជាពិសេសនៅក្នុងផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ ច្បាប់ និងនយោបាយក្នុងការដឹកនាំ និងសម្របសម្រួលការងារគណៈកម្មការទី៣ ឱ្យទទួលបានជោគជ័យពេញមួយអាណត្តិរហូតដល់ឆ្នាំ១៩៩៨។ ជាក់ស្តែងដូចជា ការងារពិនិត្យ សម្របសម្រួល និងធ្វើកំណត់បង្ហាញលើទិដ្ឋភាពទម្រង់ និងខ្លឹមសារនៃសេចក្តីព្រាងច្បាប់សម្រាប់ដាក់ជូនរដ្ឋសភាត្រួតពិនិត្យពិភាក្សា និងអនុម័តនូវបណ្តាអត្ថបទច្បាប់ ដូចជា **ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិ** ជាដើម ដែលសុទ្ធសឹងជាច្បាប់សំខាន់និងចាំបាច់ ដើម្បីអនុញ្ញាតឱ្យយន្តការនៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារនៅកម្ពុជាអាចដំណើរការពេញលេញបាន។ សមិទ្ធផលដែលសម្រេចបានតាមរយៈការកែទម្រង់របស់អតីតរដ្ឋកម្ពុជាទាំងនេះ គឺមិនមែនកើតឡើងដោយឯកឯង និងក្នុងភាពចៃដន្យនោះទេ គឺពិតជាមានប្រភពចេញពីការគិតគូរប្រកបដោយទស្សនវិស័យ និងគតិបណ្ឌិតគួបផ្សំនឹងការដឹកនាំដ៏ត្រឹមត្រូវ ភ្លឺស្វាង ម៉ឺងម៉ាត់ និងសកម្មបំផុតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ចាប់តាំងពីឆ្នាំ១៩៨៥ តរៀងមក។ ឈរលើមូលដ្ឋាននេះហើយ ទើបកម្ពុជាអាចបោះជំហានទៅមុខជាបណ្តើរៗ

ប្រកបដោយភាពច្បាស់លាស់ រឹងមាំ និងខ្លាំងក្លាពីមួយដំណាក់កាលទៅមួយដំណាក់កាលរហូតដល់សព្វថ្ងៃ។

១៤- **ដោយមើលឃើញថាជាធនធានមួយរូប ដែលបានកសាងស្នាដៃសំខាន់ៗជាច្រើនកន្លងមកនោះទើបនៅឆ្នាំ១៩៩៨ ពោលគឺនៅក្នុងនីតិកាលទី២ របស់រដ្ឋសភា** នៅក្នុងបរិបទដែលកម្ពុជាបានឈានមកដល់ដំណាក់កាលថ្មី នៃសន្តិភាពពេញលេញតាមរយៈ «គោលនយោបាយឈ្នះ-ឈ្នះ» របស់**សម្តេចអគ្គមហាសេនាបតីតេជោ បិតាស្ថាបនិកសន្តិភាពកម្ពុជា ហ៊ុន សែន** និងតម្រូវការនៃការកែទម្រង់វិស័យសាធារណៈ ជាពិសេសលើការងារគ្រប់គ្រងរដ្ឋបាលសាធារណៈនិងហិរញ្ញវត្ថុសាធារណៈ លោក **អ៊ុក រ៉ាប៊ុន** ត្រូវបានតែងតាំងជាសមាជិករាជរដ្ឋាភិបាល និងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បន្ទាប់មកពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៣ លោកត្រូវបានតែងតាំងជារដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ជាទីប្រឹក្សាផ្ទាល់នាយករដ្ឋមន្ត្រីផង និងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផង។ ចំណេះដឹងនិងបទពិសោធន៍ដែលលោកទទួលបានក្នុងសាលា និងក្នុងសមរភូមិការងារផ្ទាល់ជាង៣០ឆ្នាំ ព្រមទាំងការទទួលបាននូវការបណ្តុះបណ្តាលបន្ថែមលើមុខជំនាញការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅសាកលវិទ្យាល័យហាវ៉ាដ (Harvard University) សហរដ្ឋអាម៉េរិក បានបង្កលក្ខណៈឱ្យលោកបម្រើការងារក្នុងតួនាទីជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានយ៉ាងល្អ និងប្រកបដោយប្រសិទ្ធភាព ពិសេសការងារដឹកនាំនិងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចហិរញ្ញវត្ថុសាធារណៈ ថវិកាជាតិ ទ្រព្យសម្បត្តិរដ្ឋ ការងារឯកជនូប-

នីយកម្ម និងការងារកែលម្អការអនុវត្តគណនេយ្យជាតិ ដែលសុទ្ធសឹងជាកិច្ចការដឹកនាំគ្រប់គ្រង សម្របសម្រួលសកម្មភាពសេដ្ឋកិច្ចជាតិឱ្យប្រព្រឹត្តទៅយ៉ាងស៊ីចង្វាក់ និងប្រកបដោយសង្គតិភាពស្របទៅតាមតម្រូវការក្នុងបរិបទថ្មីនៃសង្គមកម្ពុជា។ ទន្ទឹមនឹងនេះ លោកបានរួមចំណែកជាច្រើនទាំងគំនិតទស្សនៈ ព្រមទាំងអនុសាសន៍នានា ដែលជាធាតុចូលដ៏សំខាន់ក្នុងការងារតាក់តែងចងក្រងចក្ខុវិស័យ គោលនយោបាយ យុទ្ធសាស្ត្រ និងវិធានការសំខាន់ៗនានាជាច្រើនក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងបានប្រកាសដាក់ឱ្យអនុវត្តចាប់តាំងពីចុងឆ្នាំ២០០៤ រហូតដល់ពេលបច្ចុប្បន្ននេះ។ ជាក់ស្តែង លោកគឺជាអ្នកដឹកនាំផ្ទាល់ក្នុងការរៀបចំ**ច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីអស្សាមិករណ៍** ព្រមទាំងជាអ្នកចូលរួមចំណែកជំរុញការងារអភិបាលកិច្ចល្អ ជាពិសេសលើការរៀបចំធ្វើវិចារណកម្មចំណូលនិងចំណាយថវិកាជាតិប្រចាំឆ្នាំ ទាំងក្នុងពេលកសាងថវិកា និងក្នុងពេលអនុវត្ត ថវិកាដែរ ការជំរុញការអនុវត្តប្រព័ន្ធថវិកាថ្មី និងប្រព័ន្ធពន្ធដារថ្មី។ លើសពីនេះទៅទៀត លោកបានបំពេញតួនាទីជាជំនួយការអម**ឯកឧត្តមកិត្តិបវិរក្សបណ្ឌិត គាត ឈន់** អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការរៀបចំ និងឆ្លងច្បាប់និងលិខិតបទដ្ឋានជាច្រើន ដូចជា **ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ** (១៩៩៨ ដល់ឆ្នាំ២០១៣) **ច្បាប់ស្តីពីធានារ៉ាប់រង** (២០០០) **ច្បាប់ស្តីពីសវនកម្ម** (២០០១) **ច្បាប់ស្តីពីវិសោធនកម្មលើច្បាប់សារពើពន្ធ** (២០០៣) **ច្បាប់គយ** (២០០៧)

**ច្បាប់ស្ដីពីសម្បទាន** (២០០៧) **ច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ** (២០០៨) **ច្បាប់ស្ដីពីអស្សាមិករណ៍** (២០១០) **ច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** (២០១១)។ល។

១៥- **ស្នាដៃ បទពិសោធន៍ និងសមត្ថភាពដឹកនាំ របស់លោកដែលបានលេចធ្លោ និងកាន់តែបានទទួលស្គាល់ជាសាធារណៈ**ធ្វើឱ្យលោកទទួលបានសេចក្ដីទុកចិត្ត និងបានតែងតាំងជារដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើមនីតិកាលទី៥ (២០១៣) របស់រដ្ឋសភា។ លោកបានចាប់ផ្ដើមជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៣-២០១៨ ដោយផ្ដោតលើការបង្កើនតម្លៃបន្ថែមលើផលិតផលកសិកម្ម ការនាំចេញអង្ករនិងកសិផលមានសក្ដានុពលមួយចំនួន ការចិញ្ចឹមសត្វនិងវារីវប្បកម្ម និងជាពិសេសការជំរុញលើកទឹកចិត្តដល់ការវិនិយោគវិស័យកសិឧស្សាហកម្ម ក្នុងគោលដៅបង្កើនផលិតភាពកសិកម្ម ទំនើបកម្មកសិកម្ម និងលើកកម្ពស់ពាណិជ្ជូបនីយកម្មកសិកម្ម។ ដើម្បីសម្រេចបានតាមគោលនយោបាយនេះ លោក **អ៊ុក រ៉ាប៊ុន** បានដាក់ចេញនូវកម្មវិធីជាយុទ្ធសាស្ត្រសំខាន់ចំនួន ៥ គឺ (១) ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិធុរកិច្ច, (២) ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ, (៣) ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម, (៤) ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ និង(៥) ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងការអភិវឌ្ឍធនធានមនុស្ស។

**១៦- ទន្ទឹមនឹងនេះ** លោក **អ៊ុក រ៉ាប៊ុន** បានផ្តល់អាទិភាពខ្ពស់ដល់ការងារគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច ដោយបានចូលរួមជាមួយនឹងគណៈកម្មការអន្តរក្រសួងក្នុងការត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច និងការរៀបចំគោលនយោបាយកែទម្រង់ការគ្រប់គ្រង និងការប្រើប្រាស់ដីធ្លី ដែលជាលទ្ធផល គឺរយៈពេលនៃការកាន់កាប់ដីសម្បទានសេដ្ឋកិច្ចត្រូវបានកាត់បន្ថយមកនៅក្រោមរយៈពេល៥០ឆ្នាំ និងការផ្តល់ដីសម្បទានសេដ្ឋកិច្ចត្រូវបានបញ្ឈប់។ លោកបានជំរុញការអនុវត្តយន្តការត្រួតពិនិត្យការអនុវត្តគោលការណ៍ និងកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន និងបានដោះស្រាយបញ្ហា និងការប្រឈមនានាជាបន្តបន្ទាប់រហូតមានការដកហូតយកដីមកវិញពីក្រុមហ៊ុនណាដែលមិនអនុវត្តតាមគោលការណ៍ និងមិនគោរពតាមកិច្ចសន្យា ហើយរក្សាដីនោះទុកសម្រាប់ផ្តល់ជាដីសម្បទានសង្គមកិច្ចជូនប្រជាពលរដ្ឋវិញ។ ជាមួយគ្នានេះ លោកក៏បានផ្តួចផ្តើមគំនិតឱ្យមានការបង់ថ្លៃតាមផ្ទៃក្រឡាលើដីសម្បទាន ដែលបានទទួលគោលការណ៍អនុញ្ញាតឱ្យរុករាន និងកាប់ឆ្ការធ្វើអាជីវកម្មរួចហើយ។

**១៧- លើសពីនេះទៅទៀត** លោក **អ៊ុក រ៉ាប៊ុន** បានផ្តល់អាទិភាពលើការរៀបចំបង្កើតច្រកចេញចូលតែមួយ ការកែទម្រង់ការគ្រប់គ្រងព្រៃឈើ ការរៀបចំសេចក្តីព្រាងច្បាប់ដើម្បីដាក់ការងារព្រៃឈើមកស្ថិតនៅក្រោមមន្ទីរកសិកម្ម រាជធានីខេត្តវិញ ការរៀបចំយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា និងការរៀបចំតាក់តែងច្បាប់ស្តីពីបសុសត្វ។ លោកបានយកចិត្តទុកដាក់ក្នុងការពង្រឹង

សមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស ជាពិសេស ការបង្កើតអគ្គនាយកដ្ឋានបសុសត្វ ហើយនិងការបណ្តុះបណ្តាលធនធានមនុស្សនៅគ្រប់កម្រិត ដើម្បីធានាស័ក្តិសិទ្ធភាព ប្រសិទ្ធភាព គណនេយ្យភាព តម្លាភាព និងចីរភាពទាំងក្នុងការងារដឹកនាំគ្រប់គ្រង និងប្រតិបត្តិ។

១៨- **នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៦** លោក **អ៊ុក រ៉ាប៊ុន** បានផ្លាស់មកដឹកនាំជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ហើយបន្ទាប់មកលោកត្រូវបានតែងតាំងជាថ្មីនៅឆ្នាំ២០១៨ នីតិកាលទី៦ របស់រដ្ឋសភា តាមរយៈព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥។ ក្នុងឋានៈជាប្រធានស្ថាប័ន លោកបានកំណត់ចក្ខុវិស័យនៃការអភិវឌ្ឍជនបទយ៉ាងច្បាស់លាស់ គឺការកាត់បន្ថយភាពក្រីក្រតាមរយៈការលើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជាជនជនបទទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីធានាឱ្យប្រជាជននៅជនបទទទួលបានការអភិវឌ្ឍប្រហាក់ប្រហែលនឹងទីប្រជុំជនដែរ។ ទស្សនទាននេះ មិនត្រឹមតែស្របទៅនឹងចក្ខុវិស័យ គោលនយោបាយ យុទ្ធសាស្ត្រ និងគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានដាក់ចេញ និងដឹកនាំអនុវត្តដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប៉ុណ្ណោះទេ ថែមទាំងជាចក្ខុវិស័យអភិវឌ្ឍន៍ជនបទដ៏សំខាន់ និងចាំបាច់មិនអាចខ្វះបានក្នុងការរួមចំណែកធ្វើឱ្យចក្ខុវិស័យ «**បញ្ចប់ភាពក្រីក្រ និងប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០**» របស់រាជរដ្ឋាភិបាលអាចសម្រេចបានតាមគោលដៅទៀតផង។

១៩- **ក្នុងន័យនេះ និងស្របតាមចក្ខុវិស័យកម្ពុជា ២០៣០ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា ២០១៦-២០៣០ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ លោក អ៊ុក រ៉ាប៊ុន** បានដឹកនាំរៀបចំតាក់តែងគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទសម្រាប់រយៈពេល១០ឆ្នាំ(២០២១-២០៣០) ដោយបានដាក់ចេញចក្ខុវិស័យប្រកបដោយមហិច្ឆតា គឺ «**ការកសាងសង្គមជនបទស៊ីវីល័យនៅឆ្នាំ២០៣០**»។ ចក្ខុវិស័យនេះមានគោលបំណងក្នុងការលើកកម្ពស់សុខុមាលភាពនិងសុខសុវត្ថិភាពជនបទប្រកបដោយវឌ្ឍនភាព ដោយផ្តោតលើការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ការអភិវឌ្ឍធនធាន និងការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌរស់នៅជនបទ តាមរយៈការអភិវឌ្ឍសហគមន៍ជនបទ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ជនបទ និងការអភិវឌ្ឍគោលនយោបាយ និងអភិបាលកិច្ចជនបទក្នុងគោលដៅធានាឱ្យជនបទកម្ពុជានៅឆ្នាំ២០៣០ មានជីវភាពរស់នៅសមរម្យមានសុខភាពមាំមួន មានសហគមន៍ថ្លៃថ្នូរ មានផ្លូវខ្វាត់ខ្វែង និងមាននយោបាយត្រឹមត្រូវសមស្រប និងអភិបាលកិច្ចល្អ។ មហិច្ឆតានៃគោលនយោបាយនេះ គឺក្នុងគោលដៅអភិវឌ្ឍតំបន់ជនបទកម្ពុជា ដើម្បីឈានទៅបញ្ចប់ភាពអត់ឃ្លាន បញ្ចប់ភាពក្រីក្រ បញ្ចប់ការខ្វះទឹកប្រើប្រាស់ និងបញ្ចប់ការខ្វះអនាម័យ ហើយធានាបានសន្តិសុខស្បៀង ធានាការតភ្ជាប់បណ្តាញផ្លូវ និងគមនាគមន៍សមស្រប ធានាឱ្យមានសេវាសាធារណៈមូលដ្ឋានសមស្រប ធានាការកាត់បន្ថយគម្លាតរវាង

ទីក្រុង និងជនបទ ជានាបន្សាំនិងបង្កើតភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ជានាការទាញយកប្រយោជន៍ជាអតិបរមាពីការរីកចម្រើននៃបច្ចេកវិទ្យា និងឌីជីថលូបនីយកម្ម ជាពិសេសក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤ ដើម្បីឆ្ពោះទៅរកអនាគតរុងរឿងនិងសុខុមាលភាពសង្គមទាំងមូល ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា និងចក្ខុវិស័យកម្ពុជាឆ្ពោះទៅរកប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

២០- **ដើម្បីកំណត់ទិសដៅសម្រាប់អនុវត្តការងារ** លោករដ្ឋមន្ត្រី **អ៊ុក រ៉ាប៊ុន** បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ (២០១៩-២០២៣) របស់ស្ថាប័ន ដោយផ្តោតការយកចិត្តទុកដាក់លើសសរស្តម្ភសំខាន់៤ គឺ (១) អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍, (២) កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ, (៣) ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ និង (៤) ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ។

២១- លោក **អ៊ុក រ៉ាប៊ុន** បានបន្តផ្តល់អាទិភាពខ្ពស់ដល់ការបង្កើនការតភ្ជាប់បណ្តាញផ្លូវគមនាគមន៍នៅតំបន់ជនបទ (បច្ចុប្បន្នមានប្រវែងសរុបប្រមាណ៤៨ ០០០គ.ម.)។ លោកបានខិតខំកៀរគរធនធានពីដៃគូអភិវឌ្ឍន៍មកបំពេញបន្ថែមជាមួយថវិការដ្ឋ ដើម្បីស្ថាបនាផ្លូវថ្មី និងការកែលម្អផ្លូវជនបទ ពីផ្លូវដីទៅជាផ្លូវក្រាលក្រួសក្រហម ពីផ្លូវក្រាលក្រួសក្រហមទៅជាផ្លូវក្រាលកៅស៊ូ និងផ្លូវក្រាលបេតុងដែលធន់នឹងបម្រែបម្រួលអាកាសធាតុ។ ប្រជាជនមានភាពងាយស្រួលក្នុងការធ្វើចរាចរណ៍បានគ្រប់ទីកន្លែង

គ្រប់រដូវកាល កាត់បន្ថយពេលវេលា និងកាត់បន្ថយការចំណាយសម្រាប់ការធ្វើដំណើរ និងការដឹកជញ្ជូនកសិផល និងទំនិញនានា។ ស្របពេលជាមួយគ្នានោះ លោកក៏បានគិតគូរស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបវន្តដទៃទៀត ដូចជា អណ្តូងទឹក ស្រះទឹក ប្រព័ន្ធត្រងទឹកភ្លៀង និងរក្សាទុកទឹកភ្លៀងតាមគ្រួសារ ប្រព័ន្ធចែកចាយទឹក បង្គន់អនាម័យសម្រាប់ប្រជាជនជនបទផងដែរ។

២២- **ទន្ទឹមនឹងនេះ ស្ថានភាពនៃការបញ្ឈប់ការបន្ទោបង់** ពាសវាលពាសកាលក៏មានវឌ្ឍនភាពខ្លាំងក្លាគួរជាទីមោទនៈផងដែរ រហូតដល់មានការទទួលស្គាល់ និងការចាប់អារម្មណ៍នៅលើវេទិកាអន្តរជាតិនានាទៀតផង។ លោក **អ៊ុក រ៉ាប៊ុន** បានកំណត់គោលដៅលុបបំបាត់ការបន្ទោបង់ពាសវាលពាសកាលឱ្យអស់ពីភូមិ ឃុំ ស្រុក ខេត្ត និងចុងក្រោយពីទូទាំងប្រទេសតែម្តង។ បច្ចុប្បន្ន មានការចេញប្រកាសនីយប័ត្របញ្ជាក់ការបញ្ចប់ការបន្ទោបង់ពាសវាលពាសកាលដល់បណ្តាខេត្ត៦ រួចហើយ គឺខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង និងខេត្តកែប។ លើសពីនេះទៅទៀត លោកជាអ្នកបង្កើតឱ្យមានក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទថ្នាក់ក្រោមជាតិ ដែលយន្តការនេះបាន និងកំពុងដំណើរការប្រកបដោយប្រសិទ្ធភាពក្នុងការកៀរគររកការគាំទ្រទាំងធនធាន ហិរញ្ញវត្ថុ និងបច្ចេកទេស ដើម្បីចូលរួមអនុវត្តផែនការសកម្មភាពនៅថ្នាក់ខេត្ត ស្រុក និងឃុំ។

២៣- **ក្នុងគោលដៅដើម្បីបង្កើនប្រាក់ចំណូលបន្ថែមប្រចាំគ្រួសារ** លោក **អ៊ុក រ៉ាប៊ុន** បានយកចិត្តទុកដាក់ជំបូងបង្អស់លើការ

បណ្តុះបណ្តាលវិជ្ជាជីវៈឱ្យបានដល់អ្នកកំពុងរស់នៅមូលដ្ឋានពិសេសយុវជន ដើម្បីផ្តល់លទ្ធភាពឱ្យពួកគេអាចរកការងារធ្វើ ឬប្រកបមុខរបរនៅនឹងកន្លែង។ លោកបានជំរុញការលើកកម្ពស់សេដ្ឋកិច្ចជនបទនៅក្នុងសហគមន៍ជនបទតាមរយៈការបណ្តុះបណ្តាលបំប៉នសមត្ថភាព ការបង្កើតការងារមុខរបរ សហគ្រិនភាព។ ទន្ទឹមនឹងនេះ លោកបានដាក់ចេញនូវវិធានការអភិរក្សប្រពៃណី ភាសា និងអត្តសញ្ញាណ វប្បធម៌ ទំនៀមទម្លាប់ជនជាតិដើមភាគតិច ហើយតំបន់ជនបទដែលមានជនជាតិដើមភាគតិចរស់នៅត្រូវបានអភិវឌ្ឍដូចគ្នានឹងតំបន់ជនបទដទៃដែរ។

២៤- **ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងស្ថាប័ន** លោក **អ៊ុក រ៉ាប៊ុន** ឱ្យតម្លៃខ្ពស់លើការចាត់តាំងមន្ត្រីក្រោមឱវាទឱ្យទៅចូលរួមក្នុងវគ្គសិក្សា ធ្វើកម្មសិក្សា និងចូលរួមក្នុងកិច្ចប្រជុំនានាទាំងនៅក្នុងប្រទេសទាំងទៅក្រៅប្រទេស។ លោកតែងគិតគូរដល់ការលើកកម្ពស់សមត្ថភាពធនធានមនុស្សឱ្យបំពេញភារកិច្ចប្រកបដោយចំណេះដឹង ចំណេះធ្វើទាន់សម័យទំនើប ដោយបញ្ជ្រាបការអនុវត្តនូវបច្ចេកវិទ្យាឌីជីថលស្របតាមបរិបទបដិវត្តន៍ឧស្សាហកម្មទី៤។ លោកគាំទ្រនិងចូលរួមជំរុញការងារកែទម្រង់សំខាន់ៗនិងចាំបាច់របស់រាជរដ្ឋាភិបាល ជាអាទិ៍ក្នុងការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ លោកបានផ្ទេរមុខងារជួសជុលផ្លូវថ្នល់ និងមុខងារសាងសង់បង្គន់អនាម័យទៅឱ្យរដ្ឋបាលថ្នាក់ស្រុកជាបណ្តើរៗ។ លោកតែងចាត់ទុកការងារយេនឌ័រជាការងារមួយដ៏មានសារសំខាន់នៅក្នុងបរិបទសកល ហើយបានផ្តល់លទ្ធភាពឱ្យ

ស្ត្រីទទួលបាននូវការអភិវឌ្ឍសមត្ថភាព ព្រមទាំងផ្តល់ឱកាសឱ្យស្ត្រីជាច្រើនរូបទទួលបានតួនាទីដឹកនាំការងារនៅក្នុងស្ថាប័នផង។

២៥- **លោករដ្ឋមន្ត្រី អ៊ុក រ៉ាប៊ុន បានខិតខំទាក់ទាញ និងបង្កលក្ខណៈងាយស្រួលដល់បណ្តាដៃគូទ្វេភាគី ពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ ដើម្បីឱ្យតួអង្គទាំងនេះអាចចូលរួមក្នុងការងារអភិវឌ្ឍន៍ជនបទជាមួយរាជរដ្ឋាភិបាល។** ជាក់ស្តែង លោកបាននិងកំពុងធ្វើការយ៉ាងជិតស្និទ្ធនិងយ៉ាងសកម្មជាមួយបណ្តាដៃគូទ្វេភាគីសំខាន់ៗដូចជា ជាមួយភាគីចិន អាល្លឺម៉ង់ បារាំង ឥណ្ឌា និងកូរ៉េខាងត្បូងជាដើម ព្រមទាំងជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិពហុភាគី និងបណ្តាអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិជាច្រើនទៀត។ ប្រការនេះ បាននិងកំពុងធ្វើឱ្យមានការចាប់អារម្មណ៍ និងវាយតម្លៃខ្ពស់ចំពោះកម្ពុជានៅក្នុងវេទិកាអន្តរជាតិ ពិសេសលើការងារទឹកស្អាត និងអនាម័យ។ នៅឆ្នាំ២០១៩ លោកបានសម្របសម្រួលដើម្បីឱ្យកម្ពុជាបានចូលជាសមាជិកនៃគណៈកម្មាធិការភាពជាដៃគូសកលនៃអនាម័យ និងទឹកសម្រាប់ទាំងអស់គ្នា (Sanitation and Water for All) ដែលជាយន្តការភាពជាដៃគូសកលរបស់អង្គការសហប្រជាជាតិ ដើម្បីពង្រឹងភាពជាដៃគូរវាងរដ្ឋាភិបាលនឹងទីភ្នាក់ងារអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍សង្គមស៊ីវិល វិស័យឯកជន និងស្ថាប័នសិក្សាស្រាវជ្រាវក្នុងគោលបំណងឈានទៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពស្តីអនាម័យ និងទឹកសម្រាប់ទាំងអស់គ្នា។ ប្រការដ៏គួរឱ្យកត់សម្គាល់នោះគឺក្រោមការដឹកនាំរបស់លោក ស្ថានភាពផ្គត់ផ្គង់ទឹកស្អាត និង

អនាម័យជនបទមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ កិត្តិយស មួយដ៏ប្រសើរចំពោះកម្ពុជាយើង នាខែតុលា ឆ្នាំ២០២០ គណៈ-កម្មាធិការសម្របសម្រួលភាពជាដៃគូសកលនៃអនាម័យ និងទឹក សម្រាប់ទាំងអស់គ្នា បានបោះឆ្នោតជ្រើសតាំងរូបលោកឱ្យធ្វើជា តំណាងបណ្តាប្រទេសតំបន់អាស៊ីខាងកើតនិងប៉ាស៊ីហ្វិក ដែល មានសមាជិកចំនួន៧ប្រទេស (កម្ពុជា វៀតណាម ឡាវ ឥណ្ឌូនេស៊ី ម៉ុងហ្គោលី ទីម័រខាងកើត និងភីអិនជី) នៅក្នុងគណៈកម្មាធិការ សម្របសម្រួល។

២៦- **លើការងាររួមចំណែកបង្ការ និងទប់ស្កាត់ការរីករាតត្បាតនៃជំងឺ កូវីដ-១៩** លោក **អ៊ុក រ៉ាប៊ុន** បានអនុវត្តតាមសារាចរណែនាំ របស់រាជរដ្ឋាភិបាលកម្ពុជា ដោយម៉ឺងម៉ាត់ និងហ្មត់ចត់បំផុត ដោយបានណែនាំដល់គ្រប់អង្គភាពក្រោមឱវាទ ជាពិសេស នាយកដ្ឋានថែទាំសុខភាពជនបទ និងមន្ទីរអភិវឌ្ឍន៍ជនបទនៅ រាជធានី ខេត្ត ឱ្យរៀបចំសកម្មភាពឆ្លើយតបប្រកបដោយ ស័ក្តិសិទ្ធិភាព ប្រសិទ្ធភាព និងសហការឱ្យបានយ៉ាងជិតស្និទ្ធ ជាមួយគណៈកម្មការប្រយុទ្ធប្រឆាំងការរីករាលដាលជំងឺកូវីដ-១៩ ដៃគូអភិវឌ្ឍន៍ និងអាជ្ញាធរពាក់ព័ន្ធ។ ទន្ទឹមនឹងនេះ លោកបាន ណែនាំ ដល់ក្រុមការងារបច្ចេកទេសអំពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ថ្នាក់ដឹកនាំក្រសួង និងក្រុមការងាររាជរដ្ឋា-ភិបាលចុះមូលដ្ឋានតាមស្រុក និងឃុំ ឱ្យចុះទៅដល់សហគមន៍ ផ្ទាល់ (ដោយគោរពនិងអនុវត្តឱ្យបានហ្មត់ចត់ និងម៉ឺងម៉ាត់ បំផុតតាមវិធានសុខាភិបាលដើម្បីចៀសវាងឱ្យរួចផុតពីការឆ្លង) ដើម្បីសួរសុខទុក្ខ និងសំណេះសំណាល អប់រំដល់ប្រជាពលរដ្ឋ

អំពីរោគរាតត្បាតកូវីដ-១៩ ពិសេសអប់រំពីភាពចាំបាច់នៃការធ្វើចត្តាឡីស័កចំពោះអ្នកដែលទើបត្រឡប់មកពីក្រៅប្រទេស ឬពីតំបន់ដែលមានការឆ្លងជំងឺកូវីដ-១៩។ លោកបានសហការជាមួយអាជ្ញាធរស្រុក ឃុំ-សង្កាត់ ដើម្បីអប់រំផ្សព្វផ្សាយតាមខ្នងផ្ទះដោយប្រើផ្ទាំងរូបភាពរបៀបលាងដៃជាមួយសាប៊ូ និងវិធានការការពារជំងឺកូវីដ-១៩ (៣ការពារ ៣កុំ) បិទផ្ទាំងរូបភាពតាមផ្លូវតាមទីសាធារណៈ មណ្ឌលសុខភាព សាលារៀន និងនៅតាមសាលាឃុំសង្កាត់។ លោកបានប្រើបច្ចេកវិទ្យាឌីជីថលក្នុងការប្រជុំតាមអនឡាញរវាងអង្គភាពក្រោមឱវាទ និងជាមួយស្ថាប័ននានាទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ដើម្បីចូលរួមផ្តួចផ្តើមជំរុញសកម្មភាពនៃការបណ្តុះអក្ខរកម្មបច្ចេកវិទ្យា ទៅក្នុងកិច្ចការរដ្ឋបាលសាធារណៈផង និងដើម្បីបញ្ចៀសហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ ដែលបណ្តាលមកពីការជួបប្រាស្រ័យគ្នាផ្ទាល់ផង។ លើសពីនេះ លោកបានផ្តល់មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទនៅខេត្តកំពង់ស្ពឺជូនរដ្ឋបាលខេត្ត សម្រាប់ប្រើប្រាស់ធ្វើជាកន្លែងទទួលធ្វើចត្តាឡីស័កដល់អ្នកដែលទើបតែត្រឡប់មកពីក្រៅប្រទេស។

២៧- **លោក អ៊ុក រ៉ាប៊ុន តែងតែបរិច្ចាគទ្រព្យធនផ្ទាល់ខ្លួននិងផ្តួចផ្តើមគំនិតបំផុសឱ្យមានការចូលរួមពីក្រុមគ្រួសារ សហការី និងញាតិមិត្ត ព្រមទាំងសប្បុរសជននានាក្នុងការចូលរួមចំណែកជួយសង្គមនិងការងារមនុស្សធម៌។** សមិទ្ធិជាច្រើនដែលលោកកសាងមានអគារបណ្ណាល័យមួយនៅវិទ្យាល័យស្វាយរៀង អគារសិក្សាមួយខ្នងមានប្រាំបន្ទប់ និងរបងនៅសាលាបឋមសិក្សាតាជ័យ

និងអគារសិក្សាមួយខ្នងទៀតនៅអនុវិទ្យាល័យតាជ័យ អគារសិក្សាមួយខ្នង ទីចាត់ការ និងរបងនៅសាលាបឋមសិក្សាកំពង់ចំឡង ក្នុងឃុំកំពង់ចំឡង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ នៅស្រុករលាប្អៀរនៃខេត្តកំពង់ឆ្នាំង លោករួមចំណែកកសាងពង្រីកបានអាងស្តុករក្សាទឹកនៅឃ្លាំងភូមិព្រៃខ្មែរ ឃុំរលាប្អៀរ។ ក្រៅពីនេះ លោកបានចូលរួមកសាងព្រះវិហារវត្តព្រែករាំង ក្នុងឃុំទឹកហូត ព្រះវិហារវត្តព្រះវិហារហ្លួងក្នុងឃុំរលាប្អៀរ ព្រះវិហារវត្តថ្មីក្នុងឃុំរលាប្អៀរ ព្រះវិហារវត្តព្រះរាមរង្សី ក្នុងឃុំជ្រៃបាក់ ព្រះវិហារវត្តភ្នំចំពុះ ក្នុងឃុំអណ្តូងស្នាយ ព្រះវិហារវត្តកងមាស ក្នុងឃុំគោកបន្ទាយ ព្រះវិហារវត្ត ឧទ្ទុមពរ ក្នុងឃុំស្វាយជ្រុំ ព្រះវិហារវត្តកំពង់រាំង ក្នុងឃុំស្វាយជ្រុំ ព្រះវិហារវត្តថ្មកែវក្នុងឃុំស្វាយជ្រុំ ព្រះវិហារ និងខ្លោងទ្វារវត្តអណ្តូងប្រេង សាលាបុណ្យនៅភូមិបឹងវែងក្នុងឃុំក្រាំងលាវ អគារសិក្សាមួយខ្នង«អគារឈ្នះ»មានប្រាំបន្ទប់នៅវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន រលាប្អៀរត្បូង ក្នុងឃុំអណ្តូងស្នាយ អគារសិក្សាមួយខ្នងមានប្រាំបន្ទប់នៅសាលាបឋមសិក្សាគ្រួសក្នុងឃុំរលាប្អៀរ របងសាលាបឋមសិក្សាជ្រៃបាក់ ឃុំជ្រៃបាក់។ នៅក្នុងស្រុកសាមគ្គីមានជ័យនៃខេត្តកំពង់ឆ្នាំង លោកបានចូលរួមកសាងព្រះវិហារវត្តខ្សាងខាងត្បូងព្រះវិហារ ខ្លោងទ្វារវត្តខ្សាងខាងជើងក្នុងឃុំស្វាយ ព្រះវិហារនិងខ្លោងទ្វារវត្តត្បែងខ្ពស់ ព្រះវិហារវត្តព្រះនារាយណ៍ក្នុងឃុំត្បែងខ្ពស់ ព្រះវិហារវត្តទេពអប្សរក្នុងឃុំក្រាំងល្វា ព្រះវិហារវត្តសិរីវង្សារាមក្នុងឃុំត្បែងខ្ពស់ ព្រះវិហារនិងខ្លោងទ្វារវត្តត្រពាំងហ្មទេសក្នុងឃុំស្វាយជុក ព្រះវិហារនិងខ្លោងទ្វារវត្តទួលព្រះវិហារក្នុងឃុំស្វាយជុក ព្រះវិហារនិង

ខ្លោងទ្វារវត្តប្រកសង្កែក្នុងឃុំស្វាយផុក ខ្លោងទ្វារវត្តប្រកស្តេចក្នុងឃុំស្វាយផុក ព្រះវិហារនិងខ្លោងទ្វារវត្តរលាំងនាគក្នុងឃុំស្វាយផុក ព្រះវិហារនិងខ្លោងទ្វារវត្តតាំងខ្មៅឃុំពាម ព្រះវិហារវត្តកេរ្តិ៍ស្មី និងឧបដ្ឋានសាលាក្នុងឃុំខ្នាផ្ទារ ព្រះវិហារ ខ្លោងទ្វារ និងរបងវត្តប្រកត្នោតក្នុងឃុំឈានឡើង ថែវនៅលើភ្នំព្រះធាតុក្នុងឃុំឈានឡើង។ នៅស្រុកបរិបូរណ៍នៃខេត្តកំពង់ឆ្នាំង លោកបានសាងសង់ខ្លោងទ្វារវត្តមួយចំនួនផងដែរ។ ក្រៅពីនេះ លោកក៏បានជួយសង់ផ្ទះដល់ជនក្រីក្រជាច្រើនខ្នង ជីកអណ្តូង ជីកប្រឡាយនាំទឹកមកសម្រាប់ប្រើប្រាស់ និងសម្រាប់ការបង្កបង្កើនផលជាច្រើនខ្សែនៅក្នុងខេត្តកំពង់ឆ្នាំងទៀតផង។

២៨- **ចំពោះជ័យលាភីខាងកម្រិតវប្បធម៌** លោក **អ៊ុក រ៉ាប៊ុន** បានទទួលសញ្ញាប័ត្របណ្ឌិតផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ( Doctor of Philosophy in Economics ) ពីសាកលវិទ្យាល័យសេដ្ឋកិច្ចជាតិនៃប្រទេសវៀតណាម ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩០។ ស្នាដៃជាច្រើនដែលលោកសម្រេចបានក្នុងការចូលរួមវិភាគទានកសាងសេដ្ឋកិច្ចកម្ពុជាបានកត់ត្រាទទួលស្គាល់ និងការវាយតម្លៃខ្ពស់តាមរយៈការផ្តល់សញ្ញាប័ត្របណ្ឌិតកិត្តិយស ផ្នែករដ្ឋបាលធុរកិច្ច Doctor Honoris Causa in Business Administration ពីសាកលវិទ្យាល័យកាលីហ្វ័រញ៉ាខាងត្បូងនៃសហរដ្ឋអាម៉េរិកនៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៩៥។ ដោយលោកមានកម្រិតវប្បធម៌ថ្នាក់បណ្ឌិត សាកលវិទ្យាល័យកាលីហ្វ័រញ៉ាខាងត្បូង បានជ្រើសរើសលោក **អ៊ុក រ៉ាប៊ុន** ធ្វើជាសាស្ត្រាចារ្យរង ប្រចាំសាខានៅកម្ពុជា។ លើស

ពីនេះទៀត លោកក៏មានវិជ្ជាជីវៈជាមេធាវីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។

២៩- **ជាការទទួលស្គាល់នូវវិភាគទាន និងគុណបំណាច់ជូនជាតិមាតុភូមិ** លោក **អ៊ុក រ៉ាប៊ុន** ទទួលបាននូវគ្រឿងឥស្សរិយយសចំនួន៣ (គ្រឿងឥស្សរិយយសជាតូបការនៃព្រះរាជាណាចក្រកម្ពុជា គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេរីវឌ្ឍន៍ និងគ្រឿងឥស្សរិយយសសុវត្ថារា ថ្នាក់មហាសេនា) និងមេដាយចំនួន៤ (មេដាយសុវត្ថារា ថ្នាក់ធិបឌិន្ទ មេដាយថ្នាក់សេនា មេដាយថ្នាក់អស្សប្ញទ្ធិ និងមេដាយមាស កសាងជាតិ)។

## ២- ជីវប្រវត្តិសង្ខេប

លោក **អ៊ុក រ៉ាប៊ុន** (OUK RABUN) កើតថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៥១ ទីកន្លែងកំណើត ភូមិកំពង់ចំឡង ឃុំកំពង់ចំឡង ស្រុកស្វាយរៀង ខេត្តស្វាយរៀង អាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ២៤១ ផ្លូវលេខ៥១ វិថីប៉ាស្ទ័រ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ស្ថានភាពគ្រួសាររៀបអាពាហ៍ពិពាហ៍ជាមួយអ្នកស្រី **គឹម រ៉ាទី** បានបែកឋានហើយ និងមានកូនចំនួន៤នាក់ គឺ **អ៊ុក ទិដ្ឋនាថ**(ស្លាប់), **អ៊ុក រ៉ាទីន**(ស្រី), **អ៊ុក ប្រជា**(ប្រុស) និង **អ៊ុក ពញ្ញា**(ប្រុស)។

### ក- ប្រវត្តិការសិក្សា

- ១៩៥៧-១៩៦៣ : សាលាបឋមសិក្សាស្វាយរៀងក្រុង
- ១៩៦៣-១៩៦៨ : វិទ្យាល័យព្រះសូរិយោវង្ស ខេត្តស្វាយរៀង
- ១៩៦៧ : សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ
- ១៩៦៨ : សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិភាគទី១

- ១៩៦៨-១៩៦៩ : មហាវិទ្យាល័យគរុកោសល្យខាងជើង
- រាជធានីភ្នំពេញ ជាគរុសិស្ស
- ១៩៦៩ : សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមភាគទី២ និង សញ្ញាប័ត្រគរុកោសល្យ ផ្នែកគ្រូបឋមសិក្សា
- ១៩៧០-១៩៧២ : មហាវិទ្យាល័យគរុកោសល្យ រាជធានី ភ្នំពេញ ជានិស្សិតសាស្ត្រាចារ្យ
- ១៩៧២ : សញ្ញាប័ត្រគរុកោសល្យ ផ្នែកសាស្ត្រាចារ្យ មធ្យម សិក្សាបឋមភូមិ ខាងរូបវិទ្យា-គីមី
- ១៩៧២-១៩៧៥ : មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច (ឆ្នាំទី៣ផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច)
- ១៩៨៨-១៩៩០ : មហាវិទ្យាល័យសេដ្ឋកិច្ចជាតិ ហាណូយ ប្រទេសវៀតណាម
- ១៩៩០ : សញ្ញាប័ត្របណ្ឌិត ផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ពីមហាវិទ្យាល័យសេដ្ឋកិច្ចជាតិ ហាណូយ ប្រទេសវៀតណាម
- ១៩៩៥ : សញ្ញាប័ត្របណ្ឌិតកិត្តិយស ពីសាកលវិទ្យាល័យ
- កាលីហ្វ័រញ៉ាខាងត្បូង សហរដ្ឋអាម៉េរិក
- ២០០៥ : លិខិតបញ្ជាក់ពីការសិក្សាអំពីកម្មវិធីប្រតិបត្តិលើការ គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពីសាលា ចន កេណ្ណឌី នៃ សាកលវិទ្យាល័យហាវ៉ាដ សហរដ្ឋអាម៉េរិក

## ខ- ប្រវត្តិការងារ

- ១៩៦៩-១៩៧០ : គ្រូបឋមសិក្សានៅសាលាបឋមសិក្សា ជេត ឡុង ក្នុងស្រុកស្វាយរៀង ខេត្តស្វាយរៀង

- ១៩៧២-១៩៧៥ : សាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិ នៅវិទ្យាល័យទេពប្រណម្យ ស្រុកពញាឮ ខេត្តកណ្តាល
- ១៩៧៩-១៩៨១ : អនុប្រធានមន្ទីរ ក្រសួងគមនាគមន៍ ដឹកជញ្ជូន និងប្រៃសណីយ៍
- ១៩៨១-១៩៨៦ : អនុប្រធាន និងជាប្រធាននាយកដ្ឋានផែនការទូទៅក្រសួងផែនការ
- ១៩៨៦-១៩៨៨ : អនុរដ្ឋមន្ត្រីក្រសួងផែនការ
- ១៩៨៨-១៩៩០ : អនុប្រធានខុទ្ទកាល័យមជ្ឈិមបក្ស
- ១៩៩០-១៩៩៣ : អនុរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម
- ១៩៩៣-១៩៩៨ : សមាជិកបម្រុងគណៈកម្មាធិការតាក់តែងរដ្ឋធម្មនុញ្ញ ប្រធានគណៈកម្មការហិរញ្ញវត្ថុ និងធនាគារ នៃរដ្ឋសភា និងជាតំណាងរាស្ត្រមណ្ឌលកំពង់ឆ្នាំង
- ១៩៩៨-២០០៨ : រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ឆ្នាំ២០០៨-ខែកញ្ញា ឆ្នាំ២០១៣ : ទីប្រឹក្សានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចាប់ពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ដល់ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ : រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ២០១៦-២០២៣ : រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ
- ចាប់ពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ : ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស, ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងជាប្រធានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ

- ខែកក្កដា ឆ្នាំ២០២០ ដល់បច្ចុប្បន្ន : សមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា។

## គ- មុខងារ និងតំណែងផ្សេងទៀត

ការងារក្រៅរាជរដ្ឋាភិបាល

- ១៩៩៦ : មេធាវី
- ទីប្រឹក្សានាយករដ្ឋមន្ត្រី។

## ឃ- ភាសា

- ភាសាបរទេស : អង់គ្លេស, បារាំង, រុស្ស៊ី, វៀតណាម។

## ង- គ្រឿងឥស្សរិយយស

- គ្រឿងឥស្សរិយយស និងមេដាយ ទទួលបានមានដូចជា៖
- ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១០ : គ្រឿងឥស្សរិយយស
- ជាតួបការ នៃព្រះរាជាណាចក្រកម្ពុជា
- ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៦ : គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេរីវឌ្ឍន៍
- ថ្ងៃទី៥ ខែតុលា ឆ្នាំ២០០១ : គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់មហាសេនា
- ថ្ងៃទី៩ ខែសីហា ឆ្នាំ២០០១ : គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់អស្សឫទ្ធិ
- ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៩៩ : គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ធិបឌិន្ទ
- មេដាយ ថ្នាក់សេនា និង
- មេដាយមាសកសាងជាតិ។

# ៣- សកម្មភាពការងារនិងសមិទ្ធផលបម្រើជាតិ

## សេចក្តីសម្រេចលេខ៩៥ សចតមឈ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៨៦ ស្តីពីការដំឡើងឋានៈ ស.ម. **អ៊ឹក វ៉ាប៊ុន** ជាអនុរដ្ឋមន្ត្រីក្រសួងផែនការ របស់គណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍កម្ពុជា



ភ្នំពេញ , ថ្ងៃទី 16 ខែ មករា ឆ្នាំ ១៩៨៦

លេខ : 95 សចតមឈ

28 1 86

126

សេចក្តីសម្រេច

[illegible]

ប្រការ ១ : [illegible]

១ - ស.ម [illegible]

២ - ស.ម អ៊ឹក - វ៉ាប៊ុន [illegible]

ប្រការ ២ : [illegible]

ហេង - សំរិន

# សេចក្ដីសម្រេចលេខ ១៧៧ សចតមឈ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៨៧ ស្ដីពីការផ្ទេរភារកិច្ចស.ម. **អ៊ុក វ៉ាប៊ុន** ពីអនុរដ្ឋមន្ត្រីក្រសួងផែនការ ឱ្យមកទទួលជាជំនួយការផ្ទាល់ ស.ម. អគ្គលេខា នៃគណៈកម្មាធិការមជ្ឈិមបក្ស



បក្សប្រជាជនបដិវត្តន៍កម្ពុជា
គណៈកម្មាធិការមជ្ឈិមបក្ស

លេខ: ១៧៧ សចតមឈ

ភ្នំពេញ, ថ្ងៃទី ០១ ខែ ១០ ឆ្នាំ ១៩៨៧

សេចក្ដីសម្រេច
ស្ដីពីការផ្ទេរភារកិច្ចកម្មាភិបាល

- ពិនិត្យលើរូបភាពការងារ និង លទ្ធភាពរបស់កម្មាភិបាល .
- យោងតាមបញ្ហាដែលប្រជុំការិយាល័យនយោបាយមជ្ឈិមបក្ស ថ្ងៃទី [illegible]

ការិយាល័យនយោបាយមជ្ឈិមបក្សសម្រេច :

ប្រការ ១ : ផ្ទេរភារកិច្ច ស.ម អ៊ុក វ៉ាប៊ុន ពីអនុរដ្ឋមន្ត្រីក្រសួងផែនការ មកទទួលជា ជំនួយការផ្ទាល់ ស.ម អគ្គលេខា នៃគណៈកម្មាធិការមជ្ឈិម បក្ស [illegible] ។

ប្រការ ២ : ក្រុមប្រឹក្សារដ្ឋ - ក្រុមប្រឹក្សារដ្ឋមន្ត្រី - ក្រសួងផែនការ - [illegible] មជ្ឈិមបក្ស - គណៈចាត់តាំងមជ្ឈិមបក្ស និង ស.ម អ៊ុក វ៉ាប៊ុន ត្រូវប្រតិបត្តិតាមសេចក្ដីសម្រេចនេះ ។

ជ. ការិយាល័យនយោបាយមជ្ឈិមបក្ស
អគ្គលេខា

កន្លែងទទួល
- ដូចប្រការ ២
- ឯកសារ

ហេង-សំរិន

ក្រឹត្យលេខ៤៣ ក្រ.ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋ សម្រេចផ្ទេរភារកិច្ចសមមិត្ត **អ៊ុក រ៉ាប៊ុន** ឱ្យមកទទួលជាជំនួយការផ្ទាល់សមមិត្តអគ្គលេខាគណៈកម្មាធិការមជ្ឈិមបក្ស



ក្រុមប្រឹក្សារដ្ឋ

លេខ ៤៣ ក្រ

23 10 87

1758

សាធារណរដ្ឋប្រជាមានិតកម្ពុជា
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រឹត្យ

ក្រុមប្រឹក្សារដ្ឋ
នៃ
សាធារណរដ្ឋប្រជាមានិតកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ សាធារណរដ្ឋប្រជាមានិតកម្ពុជា .
- បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃ សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២ .
- បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២ .
- តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី .

សំរេច

មាត្រា ១.- ត្រូវបានផ្ទេរភារកិច្ច សមមិត្ត អ៊ុក រ៉ាប៊ុន ពីអនុរដ្ឋមន្ត្រីក្រសួងផែនការ អោយមកទទួលជាជំនួយការផ្ទាល់សមមិត្តអគ្គលេខាគណៈកម្មាធិការមជ្ឈិមបក្ស ដោយរក្សាឋានៈ និង របបគោលនយោបាយដដែលតទៅដដែល ។

មាត្រា ២.- ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៨៧
ជ.ក្រុមប្រឹក្សារដ្ឋ
ប្រធាន

ហត្ថលេខា និង ត្រា : ចេង ស៊ីន

ដើម្បីចំលងចែក
អគ្គលេខាធិការក្រុមប្រឹក្សារដ្ឋ

ឃាង ខែន

កន្លែងទទួល :

- ខុទ្ទកាល័យ មជ្ឈិមបក្ស
- ខុទ្ទកាល័យ រដ្ឋសភា
- ខុទ្ទកាល័យ ក្រុមប្រឹក្សារដ្ឋមន្ត្រី
- ក្រសួងផែនការ
- សារព័ត៌មាន "ដើម្បីវិញ្ញាតិ"
- គ្រប់ក្រសួង និង ស្ថាប័នថ្នាក់លើ
- គ្រប់គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង
- រដ្ឋកិច្ច
- កាលប្បវត្តិ - ឯកសារ

# សេចក្ដីសម្រេចលេខ ៣២៦ សចតមឈ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៨៨ ស្ដីពីការប្រគល់ភារកិច្ច ជូនស.ម. **អ៊ុក វ៉ាប៊ុន** ឱ្យមកទទួលជាអនុប្រធានខុទ្ទកាល័យមជ្ឈិមបក្ស និងជាជំនួយការផ្ទាល់ ស.ម. អគ្គលេខា នៃគណៈកម្មាធិការមជ្ឈិមបក្ស



បក្សប្រជាជនបដិវត្តន៍កម្ពុជា
គណៈកម្មាធិការមជ្ឈិម

ភ្នំពេញ ថ្ងៃ ទី ០៤ ខែ ០៣ ឆ្នាំ ១៩៨៨

លេខ ៣២៦ សចតមឈ

សេចក្ដីសម្រេច
ស្ដីពីការប្រគល់ភារកិច្ចជូនកម្មាភិបាល

- ពិនិត្យលើតម្រូវការការងារ និង លទ្ធភាពរបស់កម្មាភិបាល ,
- ពិនិត្យមតិរបស់គណៈចាត់តាំងមជ្ឈិមបក្ស ,

ការិយាល័យនយោបាយមជ្ឈិមបក្សសម្រេច

ប្រការ ១ : ប្រគល់ភារកិច្ចជូន ស.ម អ៊ុក វ៉ាប៊ុន ឱ្យមកទទួលជាអនុប្រធានខុទ្ទកាល័យមជ្ឈិមបក្ស និង ជាជំនួយការផ្ទាល់ ស.ម អគ្គលេខា នៃ គណៈកម្មាធិការមជ្ឈិមបក្ស ។

ប្រការ ២ : ខុទ្ទកាល័យមជ្ឈិមបក្ស , គណៈចាត់តាំងមជ្ឈិមបក្ស , និង ស.ម អ៊ុក វ៉ាប៊ុន ត្រូវប្រតិបត្តិតាមសេចក្ដីសម្រេចនេះ ។

ត. ការិយាល័យនយោបាយមជ្ឈិមបក្ស
អគ្គលេខា
ហេង - សំរិន

កន្លែងបញ្ជូន :
- ដូចប្រការ ២
- ក្រសួងទីស្ដីការ
- ក្រសួងហិរញ្ញ.
- ឯកសារ .

សេចក្តីសម្រេចលេខ១១៣៥ សចតមឈ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩០
ស្តីពីការផ្ទេរភារកិច្ចជូនស.ម. **អ៊ុក រ៉ាប៊ុន** ពីអនុប្រធានខុទ្ទកាល័យ
មជ្ឈិមបក្សឱ្យមកជាអនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


បក្សប្រជាជនបដិវត្តន៍កម្ពុជា
គណៈកម្មាធិការមជ្ឈិម
លេខ ១១៣៥ ស.ច.ត.ម.ឈ

ភ្នំពេញ, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩០

សេចក្តីសម្រេច
ស្តីពីការ ផ្ទេរភារកិច្ច កម្មាភិ ១ រូប

- ពិនិត្យលើតម្រូវការការងារ និងសមត្ថភាពរបស់កម្មាភិបាល
- តាមសេចក្តីសម្រេចប្រជុំរបស់ការិយាល័យនយោបាយមជ្ឈិមបក្ស ថ្ងៃទី ១៧-០៩-១៩៩០ .

ការិយាល័យនយោបាយមជ្ឈិមបក្សសម្រេច :

ប្រការ ១ : ផ្ទេរភារកិច្ចសមមិត្ត អ៊ុក រ៉ាប៊ុន ពីអនុប្រធានខុទ្ទកាល័យមជ្ឈិមបក្ស ទៅធ្វើការជាអនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

ប្រការ ២ : ក្រុមប្រឹក្សារដ្ឋ ក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ខុទ្ទកាល័យមជ្ឈិមបក្ស គណៈតាំងចាត់មជ្ឈិមបក្ស និងសមមិត្ត អ៊ុក រ៉ាប៊ុន ត្រូវប្រតិបត្តិតាមសេចក្តីសម្រេចនេះ ។

ជ. ការិយាល័យនយោបាយមជ្ឈិមបក្ស
អគ្គលេខា
ហេង-សំរិន

កន្លែងទទួល :
- ដូចប្រការ ២
- ឯកសារ

លោក **អ៊ុក វ៉ាប៊ុន** ធ្វើបទបង្ហាញក្នុងសន្និបាតផែនការទូទាំងប្រទេស
ឆ្នាំ១៩៨២-១៩៨៣



លោក **អ៊ុក វ៉ាប៊ុន** បកប្រែភាសារុស្ស៊ីក្នុងបេសកកម្មនៅកំពង់ផែក្រុង
ព្រះសីហនុ នៅកិច្ចសន្ទនាគ្នារវាងឯកឧត្តម **ឃុន ឈី** រដ្ឋមន្ត្រីក្រសួង
គមនាគមន៍ ដឹកជញ្ជូន និងប្រៃសណីយ៍ និងលោក **សា វ៉េនក្ខ**
ប្រធានក្រុមជំនាញការសូវៀតប្រចាំក្រសួង





ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** ក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង
រវាងក្រសួងផែនការ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា និងក្រសួង
ផែនការនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (រូបខាងលើ )
និងកំពុងការពារច្បាប់ថវិកានៅព្រឹទ្ធសភា (រូបខាងក្រោម)





ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** និងពិធីចុះហត្ថលេខា កិច្ចសហប្រតិបត្តិការ ជាមួយរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន (រូបខាងលើ) ពិធីចុះហត្ថលេខាអនុសញ្ញាហិរញ្ញប្បទាននៃរដ្ឋាភិបាលបារាំង ស្តីពីគម្រោងការទ្រទ្រង់វិស័យមីក្រូហិរញ្ញវត្ថុ (រូបខាងក្រោម)



# សកម្មភាពការងារ និងសមិទ្ធផលសំខាន់ៗ
# របស់ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន
# រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងឯកឧត្តម Yuji Kumamaru ឯកអគ្គរាជទូតជប៉ុន ប្រចាំកម្ពុជា ឆ្នាំ២០១៣ (រូបខាងលើ) និងឯកឧត្តម Yukiya Amano អគ្គលេខាធិការ IAEA នាថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ (រូបខាងក្រោម)



## ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** និងថ្នាក់ដឹកនាំក្រសួង រៀបចំពិធី សូត្រមន្ត ចម្រើនព្រះបរិត្ត នាឱកាសបុណ្យចូលឆ្នាំខ្មែរ ប្រពៃណីជាតិខ្មែរ ឆ្នាំមមី ឆស័ក ព.ស.២៥៥៨ នាថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៤





# ពិធីសម្ពោធវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ-សត្វព្រៃ ក្រោមជំនួយរបស់សាធារណរដ្ឋកូរ៉េ នាថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៤






ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ
វិទ្យាស្ថានស្រាវជ្រាវជាតិ និងអភិវឌ្ឍវារីវប្បកម្ម សម្តេចតេជោ **ហ៊ុន សែន**
ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **អ៊ុក វ៉ាប៊ុន** នៅស្រុកស្អាង
ខេត្តកណ្តាល ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤













# ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការ ស្តីពីការបណ្តុះ
# បណ្តាលបច្ចេកទេសដាំឈើហូបផ្លែ និងបន្លែ រវាងសាលាជាតិកសិកម្ម
# ព្រែកលៀប និងក្រុមហ៊ុនសហប្រតិបត្តិការអន្តរជាតិ និងបច្ចេកវិទ្យា
# កសិកម្ម ហ្វ៉ូររើឌ ក្វាងស៊ី សាធារណរដ្ឋប្រជាមានិតចិន
# នាថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤






# ពិធីចុះហត្ថលេខាវិសោធនកម្ម១ នៃអនុស្សរណៈនៃការចាត់ចែង ការអនុវត្តកម្មវិធីឧបត្ថម្ភធនទាក់ទងខ្សែចង្វាក់តម្លៃកសិកម្មរវាងរដ្ឋាភិបាល កម្ពុជា និងអូស្ត្រាលី នាថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤






# ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** អញ្ជើញចែកស្រូវពូជដល់ប្រជាកសិករ កំលុងខែមិថុនា ឆ្នាំ២០១៤






FIDR







ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះទស្សនកិច្ចនៅកសិដ្ឋានបន្លែ នៅខេត្តកណ្ដាល ក្នុងទិវាស្បៀងអាហារពិភពលោក នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥



សកម្មភាពការងារផ្សេងៗ ក្នុងនាមជា
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ











# សកម្មភាពការងារនិងសមិទ្ធផលសំខាន់ៗ
# របស់ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន
# រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ




ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ដឹកនាំគណៈប្រតិភូចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអភិវឌ្ឍន៍ជនបទ អាស៊ាន លើកទី១០ ស្តីពី “ការអភិវឌ្ឍជនបទ និងលុបបំបាត់ភាពក្រីក្រ” នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី នាថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៧

## ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងជា ប្រធាន ក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋានខេត្តកំពង់ឆ្នាំងបានអញ្ជើញ ជាអធិបតីក្នុងពិធីប្រកាសចូលកាន់តំណែងរបស់ក្រុមប្រឹក្សាខេត្ត អាណត្តិទី៣ នាថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩






ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ អញ្ជើញធ្វើបទអន្តរាគមន៍ ស្តីពីសមិទ្ធផលនៃការអភិវឌ្ឍសង្គមនិងការកាត់បន្ថយភាពក្រីក្រនៅព្រះរាជាណាចក្រកម្ពុជាក្នុងវេទិកាអាស៊ាន-ចិនលើកទី១៣ នៅទីក្រុងណាននីង (Nanning) សាធារណរដ្ឋប្រជាមានិតចិន នាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩






## ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ក្នុងខួបទិវាអន្តរជាតិនារី ០៨ មីនា ឆ្នាំ២០២៣ ខួបទី១១៣ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ











ឯកឧត្តមបណ្ឌិតសភាចារ្យ
**អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួង
អភិវឌ្ឍន៍ជនបទ ថ្លែងក្នុង
កិច្ចប្រជុំស្តីពីទឹកស្អាតប្រចាំ
ឆ្នាំ២០២៣ នៅអង្គការ
សហប្រជាជាតិ កាលពីថ្ងៃ
ទី២២-២៤ ខែមីនា
ឆ្នាំ២០២៣

ពិធីសំណេះសំណាលរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន**
ជាអធិបតីក្នុងពិធីប្រកាសទទួលស្គាល់ជាផ្លូវការខេត្តកំពង់ស្ពឺជាខេត្តទី៤
ដែលទទួលបានជ័យលាភីជាខេត្តបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល
នាថ្ងៃទី៣ ខែមេសា  ឆ្នាំ២០២៣







ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** អមដំណើរសម្ដេចតេជោ **ហ៊ុន សែន** អញ្ជើញសម្ពោធដាក់ឱ្យប្រើប្រាស់ផ្លូវ ដែលកសាងដោយ ក្រសួងអភិវឌ្ឍន៍ជនបទ នៅខេត្តបន្ទាយមានជ័យ



ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ពិនិត្យការដ្ឋានស្ថាបនាផ្លូវជនបទ ប្រភេទ DBST ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង (២០/01/២០២៣)

ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ប្រធានក្រុមការងាររាជរដ្ឋាភិបាល
ចុះមូលដ្ឋានខេត្តកំពង់ឆ្នាំង ប្រគល់ផ្ទះចំនួន២ខ្នង ជូនចាស់ជរារស់នៅ
ក្នុងភូមិគ្រួស ឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង
នាថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣





ពិធីសំណេះសំណាលរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន**
ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមប្រឹក្សាស្តារ
អភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ និងឯកឧត្តម **ឆាយ ឫទ្ធិសែន**
រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ នាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣






## ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ក្នុងពិធីសិក្ខាសាលាចងក្រងសមាជិកចលនាភូមិ១ផលិតផល១ឆ្នាំ២០២៣ នៅទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣






ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** និងតំណាងអង្គការយូនីសេហ្វ ដើម្បីស្វែងរកកិច្ចសហប្រតិបត្តិការធ្វើឱ្យធ្លាក់ចុះនូវអត្រាជំងឺមិនឆ្លងនៅកម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣





ជំនួបរវាងឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ជាមួយលោក John Aylieff នាយកប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក នៃអង្គការកម្មវិធីស្បៀងអាហារពិភពលោក នារសៀលថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤

## ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** អញ្ជើញជួបសំណេះសំណាល ជាមួយបងប្អូនប្រជាកសិករនិងពិនិត្យសកម្មភាពអន្តរាគមន៍បូមទឹកស្រោចស្រពស្រូវប្រាំងនៅក្នុងឃុំគោកបន្ទាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤





## ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ទេសរដ្ឋមន្ត្រី
## ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ (ក.ក.ជ.) និងជា
## ប្រធានគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១ (គ.ជ.ភ១.ផ១.)
## អញ្ជើញជាអធិបតីក្នុងវេទិកាសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី៨០
## នាព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤






ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** អញ្ជើញចុះពិនិត្យការដ្ឋានសាងសង់ស្ពានព្រៃក្រាំង ស្ថិតក្នុងភូមិបាញ់ឆ្កោល ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង នាព្រឹកថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤



ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** អញ្ជើញចូលរួមរុក្ខទិវា ៩ កក្កដា ២០២៤ នៅភូមិបាញ់ឆ្កោល ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង



ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ចុះពិនិត្យការសាងសង់សាលារៀនមួយខ្នង ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ផ្តល់ជូនសិស្សរៀននៅសាលាបឋមសិក្សាអន្លង់អក ស្ថិតនៅក្នុងភូមិអន្លង់អក ឃុំកំពង់អូស ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង នាព្រឹកថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៤





# ឧបសម្ព័ន្ធ
# សញ្ញាប័ត្រ លិខិតបញ្ជាក់ ទទួលបានក្នុង
# វិស័យអប់រំ



MINISTRY OF EDUCATION AND TRAINING

Recognition of Degree
DOCTOR OF PHILOSOPHY
in Economics
To Uk Rabun
Born 27/01/1951 in Cambodia

MINISTER OF EDUCATION AND TRAINING
(Signed)

BỘ TRƯỞNG BỘ GIÁO DỤC VÀ ĐÀO TẠO

Căn cứ đề nghị của Hội đồng đánh giá luận án khoa học thành lập theo quyết định số 259 QĐ-SĐH ngày 17/5/1990 họp ngày 28/5/1990 tại Trường đại học Kinh tế quốc dân

CỘNG HÒA XÃ HỘI CHỦ NGHĨA VIỆT NAM
ĐỘC LẬP - TỰ DO - HẠNH PHÚC

BẰNG
PHÓ TIẾN SĨ KHOA HỌC

Số: 966

CÔNG NHẬN HỌC VỊ
PHÓ TIẾN SĨ KHOA HỌC
Kinh tế
Cho Uk Rabun
Sinh ngày 27/01/1951
tại Campuchia

BỘ TRƯỞNG
BỘ GIÁO DỤC VÀ ĐÀO TẠO



Southern California University
for Professional Studies

herewith certifies that
Dr. Ouk Rabun
Doctor of Philosophy in Business Administration
is
A Resident adjunct Professor
in Cambodia
on the First Day of April, Nineteen Hundred Ninety Five

Dean, International Department

President of the University

សញ្ញាបត្រថ្នាក់បណ្ឌិត ឯកទេសវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ១៩៩០
និងសញ្ញាបត្របណ្ឌិតកិត្តិយស ផ្នែករដ្ឋបាលធុរកិច្ច ឆ្នាំ១៩៩៥

UNIVERSITE PHNOM PENH

FACULTE DE PEDAGOGIE

N° 161

ATTESTATION DE REUSSITE

LE DOYEN DE LA FACULTE DE PEDAGOGIE

Certifie que M. Ouk Rabun អ៊ុក រ៉ាប៊ុន

né le 27 Janvier 1951

à Kompong Chamlang (Svay Rieng)

a été déclaré reçu à l'Examen du Diplôme de

PROFESSORAT SECONDAIRE DU PREMIER CYCLE

Session du 1er Juin 1972

Centre de la FACULTE DE PEDAGOGIE

Phnom-Penh, le 15 Juin 1972

OPTION : Physique Chimie

ឈៀង ស៊ុនគុម

Scanned with CamScanner

# HARVARD UNIVERSITY

## John F. Kennedy School of Government

## Executive Education

HARVARD UNIVERSITY | JOHN F. KENNEDY SCHOOL OF GOVERNMENT

This is to certify that

***Rabun Ouk***

has completed

Public Financial Management

July 10 - July 29, 2005

Faculty Chair

Director

# ព្រះរាជក្រឹត្យតែងតាំងជាសមាជិកពេញសិទ្ធិ

ព្រះរាជក្រឹត្យ

នស/រកត/០៧២០/៧៥៩

ស្តីពី

**ការតែងតាំងសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិត្យសភាកម្ពុជា**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជា**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧១៧/៥៨៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤ថ្មី, មាត្រា១០ថ្មី, មាត្រា១១ថ្មី, មាត្រា១២ថ្មី និងមាត្រា២០ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤, មាត្រា១០, មាត្រា១១, មាត្រា១២, មាត្រា១៤, មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា

១/២

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៩៩២ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៩៩៣ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ ស្តីពីការតែងតាំងសមាសភាពថ្នាក់ដឹកនាំក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១១៨/០៩៧ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៨ ស្តីពីក្របខណ្ឌគោរមងារនៃរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: តែងតាំង:

១- លោកជំទាវបណ្ឌិត **កឿន សុគុណា** ជាសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិត្យសភាកម្ពុជា មានគោរមងារជា **បណ្ឌិតសភាចារ្យ**

២- ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** ជាសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិត្យសភាកម្ពុជា មានគោរមងារជា **បណ្ឌិតសភាចារ្យ**

៣- ឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** ជាសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិត្យសភាកម្ពុជា មានគោរមងារជា **បណ្ឌិតសភាចារ្យ**

៤- ឯកឧត្តមបណ្ឌិត **ជូ ទិជិត្ត** ជាសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិត្យសភាកម្ពុជា មានគោរមងារជា **បណ្ឌិតសភាចារ្យ**

៥- ឯកឧត្តមបណ្ឌិត **ច័ន្ទ រ័ត្ន** ជាសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិត្យសភាកម្ពុជា មានគោរមងារជា **បណ្ឌិតសភាចារ្យ** ។

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នស.រកត.០៧២០.៧៥១

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០២០*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

២/២

## បទចម្រៀង «រាជបណ្ឌិត្យសភាកម្ពុជា»

### និពន្ធដោយ៖ បណ្ឌិត **ហ៊ឹម សុភី**(១)

**ពោលៈ**

**(រួម) រាជបណ្ឌិត្យសភា រាជបណ្ឌិត្យសភា កម្ពុជា មានជោគជ័យ (ប)៖ សូមគោរពសម្តេចនាយករដ្ឋ មន្ត្រី (ស)៖ និងភ្ញៀវកិត្តិយស ទាំងប្រុស ស្រី (ប)៖ បវរសួស្តី សិរី ខ្ពស់ឧត្តម....**

(ប)៖ រាជបណ្ឌិត្យសភាកម្ពុជា មូលផ្តុំ ជាទីប្រជុំអ្នកប្រាជ្ញ

(ស)៖ ខ្មែរ មានភារកិច្ចរក្សាថែ ស្រាវជ្រាវខ្ពង់ខ្ពស់ពូកែ នាំខ្មែរឆ្ពោះទៅមុខ

(ប)៖ រាជបណ្ឌិត្យសភាកម្ពុជា ជាថ្នាលមុខ និងជាខួរក្បាលរបស់រដ្ឋ គ្រប់វិស័យល្អពិតប្រាកដ សាងបញ្ញាញាណមិននឿយហត់ ហ្មត់ចត់ល្អកន្ទង់។

(ស)៖ ភារកិច្ចរបស់យើងខ្ញុំ រួមកម្លាំងជាធ្លុងតែមួយ

(ប)៖ បណ្តុះបណ្តាលអភិវឌ្ឍ ធនធានជាតិខ្មែរជាជំនួយ

(ស)៖ ស្តាបនាជាតិ (ប)៖ យើងលើស្ទួយ

(រួម)៖ មាតុភូមិអង្គរ រុងរឿង ថ្កុំថ្កើង រាជបណ្ឌិត្យសភាកម្ពុជា គ្មានប្រៀប មានមោទនភាពគ្រប់វិស័យ រួមកសាងជាតិ បានប្រឹងប្រែងព្យាយាមសម្រេច ជោគជ័យ ជូនជាតិ កម្ពុជា រួមកសាងជាតិ បានប្រឹងប្រែង ព្យាយាម សម្រេចជោគជ័យ ជូនជាតិ កម្ពុជា៕

(១) បណ្ឌិត **ហ៊ឹម សុភី** ជាអ្នកនិពន្ធទំនុកភ្លេងល្បីឈ្មោះមួយរូប និងជាសមាជិកបម្រុងនៃរាជបណ្ឌិត្យសភាកម្ពុជា ដែលបានបង្ហាញស្នាដៃផ្តើមជាច្រើន តាមរយៈទំនុកតន្ត្រីអូប៉េរ៉ា តន្ត្រីសម្រាប់របាំ តន្ត្រីសម្រាប់ខ្សែភាពយន្ត និងតន្ត្រីសម្រាប់ព្រឹត្តិការណ៍ធំៗនានា។

# បទចម្រៀង : រាជបណ្ឌិត្យសភាកម្ពុជា

The Royal Academy of Cambodia

បទភ្លេង និង ទំនុកច្រៀង

និពន្ធដោយ **ឯកឧត្តមបណ្ឌិត ហ៊ឹម សុភី**

ភ្នំពេញ ឆ្នាំ ២០០០ និង២០១៧




រក្សាសិទ្ធិដោយ បណ្ឌិត ហ៊ឹម សុភី © Copyright by Him Sophy



រក្សាសិទ្ធិដោយ បណ្ឌិត ហ៊ឹម សុភី © Copyright by Him Sophy

# ក្រុមការងាររៀបចំគុណកថា

## លេខាធិការដ្ឋានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ៖

| | |
|---|---|
| ១- លោក **ហេង វីរិទ្ធិ** | ប្រធានលេខាធិការដ្ឋាន |
| ២- លោកស្រីបណ្ឌិត **សុខ ឧស្សាហ៍** | អនុប្រធានលេខាធិការដ្ឋាន |
| ៣- លោក **ចាន់ វណ្ណី** | អនុប្រធានលេខាធិការដ្ឋាន |
| ៤- លោក **មឿង ចំរើន** | មន្ត្រីលេខាធិការដ្ឋាន |
| ៥- លោក **ឆោម ជុំរ៉ុង** | មន្ត្រីលេខាធិការដ្ឋាន |
| ៦- លោក **សេង សុធា** | មន្ត្រីលេខាធិការដ្ឋាន |
| ៧- កញ្ញា **ឆាយ បុប្ផា** | មន្ត្រីលេខាធិការដ្ឋាន |

## ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក វ៉ាប៊ុន៖

| | |
|---|---|
| ១- ឯកឧត្តម **គឹម វាសនា** | នាយកខុទ្ទកាល័យ |
| ២- លោក **គង់ បុណ្យ** | សមាជិកខុទ្ទកាល័យ |